សាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និង វិទ្យាសាស្ត្រសេដ្ឋកិច្ច

Université Royale de Droit et des Sciences Economiques

Royal University of law and economics

# សារណាបញ្ចប់ការសិក្សា

# នីតិវិធីនៃការជំនុំជម្រះសាជាថ្មី

ស្រាវជ្រាវពីថ្ងៃទី០៨ ខែមេសា ឆ្នាំ ២០២៤ ដល់ថ្ងៃទី១០ ខែសីហា ឆ្នាំ ២០២៤


ស្រាវជ្រាវដោយ

និស្សិតឈ្មោះ ៖ លោក **លឹម អគ្គារិទ្ធិរុង**

លោក **អ៊ុក ចឡ្យនៈ**

ណែនាំដោយ ៖

សាស្ត្រាចារ្យជំនួយ **ញឹក ចុឆ្ធី**


ថ្នាក់បរិញ្ញាបត្រ ៖ **នីតិសាស្ត្រ**

ជំនាន់ទី ២៤

ឆ្នាំចូលសិក្សា ២០២០

ឆ្នាំសរសេរសារណា ២០២៤

**សាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និង វិទ្យាសាស្ត្រសេដ្ឋកិច្ច**

Université Royale de Droit et des Sciences Economiques

Royal University of law and economics

# សារណាបញ្ចប់ការសិក្សា

# នីតិវិធីនៃការជំនុំជម្រះសាជាថ្មី

ស្រាវជ្រាវពីថ្ងៃទី០៨ខែមេសា ឆ្នាំ ២០២៤ ដល់ថ្ងៃទី១០ ខែសីហា ឆ្នាំ ២០២៤


ស្រាវជ្រាវដោយ

និស្សិតឈ្មោះ ៖ លោក **លឹម អន្តារិទ្ធិរុង**

លោក **អ៊ុក ចឡ្សន:**

ណែនាំដោយ ៖

សាស្ត្រាចារ្យជំនួយ **ញឹក ឆុធី**


ថ្នាក់បរិញ្ញាបត្រ ៖ **នីតិសាស្ត្រ**

ជំនាន់ទី ២៤

ឆ្នាំចូលសិក្សា ២០២០

ឆ្នាំសរសេរសារណា ២០២៤

# សេចក្តីថ្លែងអំណរគុណ

ខ្ញុំបាទឈ្មោះ **លឹម អង្គារិទ្ធិរុខ** និងឈ្មោះ **អ៊ុក ខន្ធរុន:** ជានិស្សិតឆ្នាំទី៤ ថ្នាក់បរិញ្ញាបត្រ នីតិសាស្ត្រ ជំនាន់ទី២៤ នៃសាកលវិទ្យាល័យនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច ។

**សូមគោរពប្រតិបត្តិ និងសូមសម្តែងនូវកតញ្ញូតាធម៌យ៉ាងជ្រាលជ្រៅជូនចំពោះ៖**

**លោកឪពុក អ្នកម្តាយ** ជាអ្នកមានគុណដែលបានផ្តល់កំណើត និងបានខិតខំអស់ពីកម្លាំងកាយចិត្ត ដោយពុំខ្លាចនឿយហត់ក្នុងការចិញ្ចឹមបីបាច់ថែរក្សា អប់រំ ទូន្មានប្រៀនប្រដៅ និងបាន បញ្ជូនពួកខ្ញុំទៅសិក្សា រៀនសូត្រ និងប្រព្រឹត្តតែអំពើល្អ ។ លោកឪពុក អ្នកម្តាយ ក៏បានធ្វើការឧបត្ថម្ភ គាំទ្រ ទាំងផ្នែកស្មារតី ធនធាន និងសម្ភារៈ តាំងពីកូនៗនៅវ័យកុមារ រហូតដល់ពេញវ័យ ហើយថែម ទាំងជម្រុញឱ្យយើងខ្ញុំមានឱកាសបានចូលសិក្សា ក្រេបជញ្ជក់ចំណេះដឹង តាំងពីកម្រិតមូលដ្ឋាន រហូតមកដល់ថ្នាក់បរិញ្ញាបត្រ ដែលនឹងត្រូវបញ្ចប់នាពេលដ៏ខ្លីខាងមុខនេះ ។

**យើងខ្ញុំសូមសម្តែងការដឹងគុណយ៉ាងជ្រាវជ្រៅផងដែរចំពោះ៖**

**ឯកឧត្តម សាកលវិទ្យាធិការ សាកលវិទ្យាធិការរង ថ្នាក់ដឹកនាំ លោក លោកស្រីសាស្ត្រាចារ្យ** នៃសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច ដែលបានផ្តល់កាសឱ្យយើងខ្ញុំ បានបង្ហាត់បង្រៀន អប់រំ ណែនាំ និងផ្តល់នូវឱវាទ រួមទាំងបទពិសោធន៍ល្អៗគ្រប់បែប យ៉ាងដល់យើងខ្ញុំ តាំងពីថ្នាក់ឆ្នាំសិក្សាមូលដ្ឋាន រហូតដល់ពេលបញ្ចប់ថ្នាក់បរិញ្ញាបត្រនេះ។

ជាពិសេស **លោកសាស្ត្រាចារ្យណែនាំ ញឹក ឧុឌ្ធី** ដែលបានចំណាយពេលវេលា ដ៏មានតម្លៃក្នុងកាលវិភាគដ៏មមាញឹក ប្រឹងប្រែងមិនខ្លាចនឿយហត់ក្នុងការចង្អុលបង្ហាញផ្លូវក្នុងការស្រាវជ្រាវរកឯកសារ និងជួយផ្តល់ឯកសារជំនួយដល់រូបយើងខ្ញុំ ព្រមទាំងជួយពិនិត្យពាក្យពេចន៍ អក្ខរាវិរុទ្ធ និងកែតម្រូវនូវរាល់កំហុសខុសឆ្គងដែលយើងខ្ញុំបានបង្កើតក្នុងការសរសេរសារណានេះដើម្បីធានាឱ្យបាននូវសមិទ្ធិផលមួយដែលមានគុណភាព ។

ខ្ញុំបាទឈ្មោះ **លឹម អង្គារិទ្ធិរុខ** និងឈ្មោះ **អ៊ុក ខន្ធរុន:** សូមគោរពជូនពរ និងលើកហត្ថទាំងទ្វេបួងសួងដល់ទេវតា សូមជួយតាមថែរក្សាលោក អ្នកមានគុណទាំងទ្វេ ឯកឧត្តម សាស្ត្រាចារ្យ លោក លោកស្រីសាស្ត្រាចារ្យ និងអ្នកបានជួយទំនុក បម្រុងក្នុងកិច្ចការស្រាវជ្រាវនេះ ឱ្យជួបប្រទះនូវពុទ្ធពរទាំងបួន ប្រការ គឺ អាយុ វណ្ណៈ សុខៈ និងពលៈ កុំបីឃ្លៀងឃ្លាតឡើយ និងសូមទទួលបានជោគជ័យលើគ្រប់ភារកិច្ច ។

# អារម្ភកថា

សារណាបញ្ចប់ការសិក្សា ជាសមិទ្ធផលថ្មីមួយសម្រាប់យើងខ្ញុំបន្ទាប់ពីបានសិក្សាអស់រយៈពេលជិត៤ឆ្នាំ នៅសាកលវិទ្យាល័យភូមិន្ទនីតិសាស្រ្ត និងវិទ្យាសាស្រ្តសេដ្ឋកិច្ច ។ ការសិក្សាថ្វីត្បិតតែទទួលបានផ្នែកទ្រឹស្តីច្រើន ប៉ុន្តែការអនុវត្តជាក់ស្តែងជាការចាំបាច់ ។ការសិក្សាទ្រឹស្តីយកទៅផ្ទៀបនឹងការអនុវត្តមានសារៈសំខាន់ណាស់ក្នុង ការសិក្សាស្រាវជ្រាវ ថាតើការអនុវត្តស្របទៅតាមច្បាប់ដែរឬទេ ។ខ្លឹមសារទាំងមូលនៃសារណានេះ ផ្តោតសំខាន់ ទៅលើទាំងផ្នែកទ្រឹស្តី និងព្យាយាមបញ្ចូលនូវការអនុវត្តជាក់ស្តែង ។ ចំពោះការសរសេរសារណាបញ្ចប់ការសិក្សានេះ យើងខ្ញុំទាំងពីរនាក់ មានគោលបំណងរួមមួយ គឺដើម្បីអភិវឌ្ឍចំណេះដឹងបន្ថែមទៅលើអ្វីដែលបានសិក្សាកន្លងមក ព្រមទាំងដើម្បីចងក្រងទុកស្នាដៃមួយទុកសំរាប់ឱ្យនិស្សិតជំនាន់ក្រោយសិក្សា ស្វែងយល់ និងស្រាវជ្រាវបន្ថែម ។ ហេតុនេះហើយ ទើបយើងខ្ញុំទាំងពីរនាក់ បានសម្រេចចិត្ត ក្នុងការជ្រើសរើសយកនូវប្រធានបទមួយគឺ "**នីតិវិធីនៃការជំនុំជម្រះសាលាឋ្មី**" ដើម្បីតាក់តែងធ្វើជាសារណាបញ្ចប់ការសិក្សា ។

ក្នុងការចង់ក្រងជាសារណាបញ្ចប់ការសិក្សានេះ បានទាមទារឱ្យមានការខិតខំប្រឹងប្រែងដោយភាពអត់ ធ្មត់និងមានទំនួលខុសត្រូវខ្ពស់ ដើម្បីជម្នះនូវរាល់ឧបសគ្គ និងការលំបាកផ្សេងៗ ដោយយើងខ្ញុំបានត្រូវធ្វើការ ស្រាវជ្រាវយ៉ាងស៊ីជម្រៅ អំពីការអនុវត្តនីតិវិធីនៅក្នុងប្រព័ន្ធតុលាការ ឱ្យមានភាពយល់ច្បាស់ បំផុតតាមដែរអាចធ្វើទៅបាន ដើម្បីជាគំនិតសម្រាប់ខ្លឹមសារសារណា។ យ៉ាងណាមិញ គោលបំណងនៃការខិតខំប្រឹងប្រែងនេះ គឺសង្ឃឹមថាសារណាមួយនេះនឹងបានផ្តល់ជាចំណេះដឹងបន្ថែមមួយទៀត សម្រាប់យើងខ្ញុំដែលជាអ្នកស្រាវជ្រាវ ក៏ដូចជាការផ្តល់នូវឯកសារមួយ សម្រាប់អ្នកសិក្សាស្រាវជ្រាវផ្សេងទៀតដែលបានជ្រើសរើសនូវប្រធានបទប្រហាក់ប្រហែលនេះ និងសម្រាប់ជាដើមទុនជូនទៅដល់អ្នកដែលចង់យល់ដឹងពីការអនុវត្តច្បាប់នៅក្នុងប្រព័ន្ធតុលាការនៃព្រះរាជាណាចក្រកម្ពុជា។ តាមរយៈការប្តេជ្ញាចិត្ត និងការខិតខំប្រឹងប្រែងអស់ពីសមត្ថភាព របស់យើងខ្ញុំទាំងពីរនាក់ បូករួមទាំងការជួយណែនាំពីសំណាក់លោកគ្រូដឹកនាំថែមទៀតនោះ ជាលទ្ធផល សារណាបញ្ចប់ការសិក្សាមួយនេះ មានរួមបញ្ចូលនូវខ្លឹមសារល្អប្រសើរជាច្រើន។

ជាទីបញ្ចប់ យើងខ្ញុំទាំងពីរនាក់ សូមអភ័យទោសទុកជាមុន និងសូមស្នើសុំនូវក្តីអនុគ្រោះអធ្យាស្រ័យពីសំណាក់ អ្នកស្រាវជ្រាវ និងសាស្រ្តាចារ្យនានាចំពោះរាល់កំហុសឆ្គងផ្សេងៗដូចជា អក្ខរាវិរុទ្ធ និងខ្លឹមសារដែលកើតមានឡើងដោយអចេតនា។ ឆ្លៀតក្នុងឱកាសនេះ យើងខ្ញុំទាំងពីរនាក់ សូមស្វាគមន៍រាល់មតិរិះគន់ស្ថាបនាកែលម្អ ក៏ដូចជាដំបូន្មានល្អៗទាំងអស់ពីគ្រប់មជ្ឈដ្ឋាន សម្រាប់ជាទុនក្នុងការកែលម្អ និងអភិវឌ្ឍចំណេះដឹងលើ ការស្រាវជ្រាវក្រោយៗទៀតកាន់តែមានភាពល្អប្រសើរ និងមានភាពត្រឹមត្រូវ។ យើងខ្ញុំសូមអរព្រះគុណ និងអរគុណទុកជាមុន សម្រាប់ការបញ្ចេញមតិសម្រាប់កែលម្អនានាមកលើស្នាដៃមួយនេះ។

# មាតិកា

ទំព័រ

**សេចក្តីផ្តើម**........................................................................................................១

១.លំនាំបញ្ហានៃការស្រាវជ្រាវ........................................................................................១

២. ចំណោទបញ្ហា..........................................................................................................២

៣.គោលបំណងនៃការស្រាវជ្រាវ.......................................................................................២

៤.ដែនកំណត់ និងវិសាលភាពនៃការស្រាវជ្រាវ.................................................................២

៥.វិធីសាស្ត្រនៃការស្រាវជ្រាវ ...........................................................................................៣

៦.រចនាសម្ព័ន្ធនៃការស្រាវជ្រាវ.........................................................................................៣

**ជំពូកទី១**

**សញ្ញាណទូទៅនៃការជំនុំជម្រះសាជាថ្មី**

**ផ្នែកទី១. គោលបំណងនៃការជំនុំជម្រះសាជាថ្មី**...........................................................៤

**កថាភាគទី១. ការផ្តល់នូវនីតិវិធីឧបាស្រ័យពិសេស**..........................................................៥

**កថាភាគទី២.ការធានាគោលការណ៍ជម្រះក្តីដោយយុត្តិធម៌**.............................................៥

**កថាភាគទី៣.ការការពារសិទ្ធិស្របច្បាប់បុគ្គលពាក់ព័ន្ធ**.....................................................៥

**ផ្នែកទី២. រចនាសម្ព័ន្ធនៃការជំនុំជម្រះសាជាថ្មី** ..............................................................៦

**ជំពូកទី២**

**ការធ្វើបណ្តឹងទាមទារជំនុំជម្រះសាជាថ្មី**

**ផ្នែកទី១. លក្ខខណ្ឌគ្រឹះ**...........................................................................................៧

**កថាភាគទី១.កម្មវត្ថុនៃការជំនុំជម្រះសាជាថ្មី**................................................................៧

១.សាលក្រម ឬ សាលដីកា..................................................................................៧

២.ដីកាសម្រេច.......................................................................................................៨

**កថាភាគទី២.មូលហេតុនៃការជំនុំជម្រះសាជាថ្មី**...........................................................៩

១.ការបំពាននីតិវិធីធ្ងន់ធ្ងរ ..... ៩
២.ភាពមិនប្រក្រតីនៃសេចក្តីសម្រេចដែលជាមូលដ្ឋាននៃសាលក្រម ឬសាលដីកា ..... ១១
៣.ករណីដែលមានការប្តូរសាលក្រម ..... ១៤
៤.ករណីដែលមានការភ្លេចបញ្ចូលការវិនិច្ឆ័យ ..... ១៥
៥.សាលក្រម ឬសាលដីកាមានភាពផ្ទុយច្បាប់ ..... ១៦
**កថាភាគទី៣.បុគ្គលដែលមានសិទ្ធិប្តឹង និង អំឡុងពេល** ..... ១៧
១.បុគ្គលដែលមានសិទ្ធិប្តឹង ..... ១៧
១.១. គោលការណ៍ ..... ១៧
១.២. អញ្ញត្រកម្ម ..... ១៨
២.អំឡុងពេល ..... ១៨
២.១. គោលការណ៍ ..... ១៨
២.២. អញ្ញត្រកម្ម ..... ១៩
**កថាភាគទី៤.ភាពបង្ខំកិច្ចនៃការជំនុំជម្រះសាជាថ្មី** ..... ១៩
១.ករណីដែលភាគីបានធ្វើការអះអាង ..... ២០
២.ករណីដែលភាគីមិនបានធ្វើការអះអាង ..... ២១
**ផ្នែកទី២. លក្ខខណ្ឌទម្រង់** ..... ២១
**កថាភាគទី១.ការសរសេរពាក្យបណ្តឹង** ..... ២២
១.ចំណុចដែលត្រូវសរសេរ ..... ២២
២.ឯកសារភ្ជាប់ ..... ២៣
**កថាភាគទី២.ការដាក់ពាក្យបណ្តឹង** ..... ២៣
១.តុលាការនៃបណ្តឹងទាមទារជំនុំជម្រះសាជាថ្មី ..... ២៣
២.ពន្ធដាក់ពាក្យសុំ ..... ២៤
៣.ការដកពាក្យបណ្តឹងទាមទារឱ្យជំនុំជម្រះសាជាថ្មី ..... ២៤

## ជំពូកទី៣

## ចំណាត់ការលើបណ្តឹងទាមទារជំនុំជម្រះសាជាថ្មី


**ផ្នែកទី១.នីតិវិធីបណ្តឹងនៃការជំនុំជម្រះសាជាថ្មី** ........................................................... ២៦

**កថាភាគទី១. ការទទួលពាក្យបណ្តឹង** ........................................................... ២៧

**កថាភាគទី២.ការពិនិត្យពាក្យបណ្តឹង** ........................................................... ២៧

១.ភាពស្របច្បាប់នៃបណ្តឹង........................................................... ២៧

២.អត្ថិភាព ឬនត្ថិភាពនៃមូលហេតុនៃការជំនុំជម្រះសាជាថ្មី........................................................... ២៨

**កថាភាគទី៣.ការបញ្ជូនពាក្យបណ្តឹង** ........................................................... ២៨

**ផ្នែកទី២. ការវិនិច្ឆ័យ និងសេចក្តីសម្រេចអំពីភាពត្រឹមត្រូវ នៃបណ្តឹង**........................................................... ២៩

**កថាភាគទី១. ការវិនិច្ឆ័យនៃបណ្តឹង** ........................................................... ២៩

១.ដីកាសម្រេចលើកចោលបណ្តឹងទាមទារជំនុំជម្រះសាជាថ្មី ........................................................... ២៩

១.១.បណ្តឹងជំទាស់លើដីកាសម្រេចលើកចោលបណ្តឹងទាមទារជំនុំជម្រះសាជាថ្មី.......... ៣០

២.ដីកាសម្រេចច្រានចោលការទាមទារឲជំនុំជម្រះសាជាថ្មី ........................................................... ៣០

២.១.បណ្តឹងជំទាស់លើដីកាសម្រេចច្រានចោលបណ្តឹងទាមទារជំនុំជម្រះសាជាថ្មី.......... ៣០

៣.ដីកាសម្រេចឲចាប់ផ្តើមការជំនុំជម្រះសាជាថ្មី ........................................................... ៣១

៣.១.បណ្តឹងជំទាស់លើដីកាសម្រេចឲចាប់ផ្តើមការជំនុំជម្រះសាជាថ្មី........................... ៣១

**កថាភាគទី២. អានុភាពនៃការជំនុំជម្រះសាជាថ្មី** ........................................................... ៣១

១.ការផ្អាកការអនុវត្តដោយបង្ខំ........................................................... ៣១

២.ការលុបចោលការអនុវត្តដោយបង្ខំ........................................................... ៣២

**ផ្នែកទី៣. ការវិនិច្ឆ័យ និងចេញសាលក្រម ឬសាលដីកាអំពីអង្គសេចក្តី** ................ ៣២

**កថាភាគទី១. ការវិនិច្ឆ័យលើអង្គសេចក្តី** ........................................................... ៣២

**កថាភាគទី២. សេចក្តីសម្រេចលើអង្គសេចក្តី** ........................................................... ៣៣

១.សាលក្រម ឬសាលដីកាច្រានចោលបណ្តឹងទាមទារជំនុំជម្រះសាជាថ្មី........................... ៣៣

២.សាលក្រម ឬសាលដីកាលុបចោលសាលក្រមដើម និងសម្រេចសេចក្ដីម្ដងទៀត.............៣៤

**សេចក្ដីសន្និដ្ឋាន** ..........................................................................................................៣៦

**អនុសាសន៍**...................................................................................................................៣៨

**ឯកសារយោង**

**ឧបសម្ព័ន្ធ**

# សេចក្តីផ្តើម

# សេចក្តីផ្តើម

## ១. លំនាំបញ្ហានៃការស្រាវជ្រាវ

**ក្រមនីតិវិធីរដ្ឋប្បវេណី** ត្រូវបានប្រកាសឱ្យប្រើដោយព្រះរាជក្រមលេខ នស/រកម/០៧០៦/០២១ ចុះថ្ងៃទី០៦ ខែកក្កដា ឆ្នាំ២០០៦ ហើយក្រមនេះត្រូវយកមកអនុវត្តនៅទូទាំងប្រទេសនៅថ្ងៃទី ២៧ ខែ កក្កដា ឆ្នាំ ២០០៧ តាមបញ្ញត្តិនៃមាត្រា៥៨៧ នៃក្រមនីតិវិធីរដ្ឋប្បវេណី និងមាត្រា៩៣ នៃរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា។ ក្រមនេះមានមាត្រា ៥៨៨មាត្រា ដោយបែងចែកជា៩គន្ថី រួមមាន គន្ថីទី១ ស្តីពីបទបញ្ញត្តិទូទៅ (ពី មាត្រា១ ដល់មាត្រា៧៣) គន្ថីទី២ ស្តីពីនីតិវិធីនៃការជម្រះក្តីលើកទី១ (ពីមាត្រា៧៤ ដល់មាត្រា២៥៨) គន្ថីទី៣ ស្តីពីបណ្តឹងឧបាស្រ័យទៅតុលាការជាន់ខ្ពស់ (ពីមាត្រា២៥៩ ដល់មាត្រា៣០៦) គន្ថីទី៤ ស្តីពីការជំនុំជម្រះសាជា ថ្មី(ពីមាត្រា៣០៧ ដល់មាត្រា៣១៨) គន្ថីទី៥ស្តីពីនីតិវិធីដាស់តឿន (ពីមាត្រា៣១៩ ដល់មាត្រា៣៣៣) គន្ថីទី៦ ស្តីពីការអនុវត្តដោយបង្ខំ (ពីមាត្រា៣៣៤ ដល់មាត្រា៥២៩) គន្ថីទី៧ ស្តីពីការចាត់ចែងរក្សាការពារ (ពីមាត្រា ៥៣០ ដល់មាត្រា៥៧១) គន្ថីទី៨ស្តីពីអន្តរបញ្ញត្តិ(ពីមាត្រា ៥៧២ ដល់មាត្រា៥៨៦) និងគន្ថីទី៩ស្តីពីអវសាន បប្បញ្ញត្តិ (ពីមាត្រា៥៨៧ ដល់មាត្រា៥៨៨)។

ដោយឡែក ចំពោះ ការជំនុំជម្រះសាជាថ្មី ស្ថិតនៅក្នុងគន្ថីទី៤ នៃក្រមនីតិវិធីរដ្ឋប្បវេណី ត្រូវបាន ចែកចេញជាជំពូកទោលរួមមាន៖ ជំពូកទី១ស្តីពីការជំនុំជម្រះសាជាថ្មី (ពីមាត្រា៣០៧ ដល់មាត្រា៣១៨) ។ ពាក់ព័ន្ធនឹងប្រធានដែលក្រុមយើងខ្ញុំបានលើកយកមកសិក្សាស្រាវជ្រាវនេះ ដែលនិយាយអំពី នីតិវិធីនៃការជំនុំជម្រះសាជាថ្មី គឺជាប្រភេទនៃបញ្ញតិពិសេសមួយ ដែលមានគោលបំណង ផ្តល់នូវបណ្តឹងឧបាស្រ័យពិសេសមួយ ដើម្បីជាការធានាឱ្យបាននូវគោលការណ៍ជម្រះក្តីដោយយុត្តិធម៌ និងការពារសិទ្ធិស្របច្បាប់របស់បុគ្គលដែលពាក់ព័ន្ធ។

នីតិវិធីនៃការជំនុំជម្រះសាជាថ្មី មានលក្ខណៈពិសេសជាងនីតិវិធីឧបាស្រ័យផ្សេងទៀត ដោយហេតុថានីតិវិធីនេះអាចត្រូវចំណាត់ការបានយ៉ាងឆាប់រហ័ស, ចំណាយសោហ៊ុយនៃការអនុវត្តក្នុងកម្រិតតិច រួមជាមួយនឹងដំណើរការនៃនីតិវិធីមានលក្ខណៈតឹងរ៉ឹង ហើយជាពិសេសគឺផលប្រយោជន៍របស់ភាគីនៃរឿងក្តីអាចត្រូវទទួលបាន ការការពារក្នុងកម្រិតខ្ពស់ជាអាទិ៍។ នីតិវិធីនៃការជំនុំជម្រះសាជាថ្មី គឺជាជាមធ្យោបាយឧបាស្រ័យមួយ ដែលភាគីប្តឹងទាមទារឱ្យតុលាការ ដែលចេញសាលក្រម ឬ សាលដីកាលុបចោល ឬកែប្រែនូវសាលក្រម ឬ សាលដីកាចុងក្រោយដែលបានចូលជាស្ថាពររួចហើយ និង ស្នើសុំឲ្យជំនុំជម្រះអំពីរឿងក្តីនោះសាជាថ្មីឡើងវិញ ដោយយកមូលហេតុថា ការអនុវត្តនីតិវិធីនៃបណ្តឹងនោះមានវិការៈធ្ងន់ធ្ងរ ឬ ឯកសារដែលជាមូលដ្ឋាននៃសេចក្តីវិនិច្ឆ័យនោះ មានការខ្វះខាតមិនប្រក្រតី ។

## ២. ចំណោទបញ្ហា

ជាទូទៅ នៅពេលដែលសាលក្រម ឬ សាលដីកាចុងក្រោយមួយបានចូលជាស្ថាពររួចហើយ នោះអានុភាពនៃអាជ្ញាអស់ជំនុំនឹងត្រូវកើតមានឡើង ដែលជាហេតុនាំឱ្យភាគីនៃរឿងក្តីមិនអាចប្តឹងឧបាស្រ័យចំពោះសាលក្រម ឬ សាលដីកានោះបានទៀតឡើយ។ ប៉ុន្តែប្រសិនបើ សាលក្រម ឬ សាលដីកាចុងក្រោយមួយបានចូលជាស្ថាពរនោះត្រូវបានរកឃើញថាមានផ្ទុកនូវកំហុសនីតិវិធីដូចដែលច្បាប់បានកំណត់ នោះភាគីអាចធ្វើការស្នើសុំឱ្យធ្វើការជំនុំជម្រះសាជាថ្មីបាន។ ហេតុនេះហើយបានជាមាននូវសំណួរមួយចំនួនបានចោទសួរឡើងមកថា តើអ្វីទៅជា នីតិវិធីនៃការជំនុំជម្រះសាជាថ្មី ? តើនីតិវិធីនៃការជំនុំជម្រះសាជាថ្មីនេះមាននូវលក្ខណៈពិសេស និងត្រូវគោរពលក្ខណៈគតិយុត្តបែបណាខ្លះ? ហើយតើនីតិវិធីនៃការជំនុំជម្រះសាជាថ្មីមាននូវលំហូនីតិវិធីយ៉ាងណាខ្លះ?

## ៣. គោលបំណងនៃការស្រាវជ្រាវ

ការសិក្សាស្រាវជ្រាវក្នុងការសរសេរសារណានេះ ធ្វើឡើងក្នុងគោលបំណង ដើម្បីពង្រឹង និងពង្រីកនូវចំណេះដឹងផ្នែកច្បាប់បន្ថែមទៀតពាក់ព័ន្ធនឹង ការអនុវត្តនីតិវិធីនៃការទាមទារឱ្យជំនុំជម្រះសាជាថ្មី។ មួយវិញទៀតដោយសារតែមើលឃើញពីលក្ខណៈបច្ចេកទេស ផលវិបាក និងភាពស្មុគស្មាញនូវក្នុងការអនុវត្តនីតិវិធីនៃការទាមទារឱ្យជំនុំជម្រះសាជាថ្មីបែបនេះហើយ ទើបបានជាយើងខ្ញុំធ្វើការសិក្សាស្រាជ្រាវដើម្បីជាការស្រាយចម្ងល់ឱ្យកាន់តែច្បាស់ និងស្វែងរកនូវចំណុចជាមូលដ្ឋានមួយ ក្នុងការអនុវត្តដំណើរការនីតិវិធី ចាប់តាំងពីការដាក់ពាក្យបណ្តឹង រហូតដល់ចំណាត់ការរបស់តុលាការចំពោះពាក្យបណ្តឹងទាមទារឱ្យជំនុំជម្រះសាជាថ្មី ប្រកបដោយសង្គតិភាព ។

## ៤. ដែនកំណត់ និងវិសាលភាពនៃការស្រាវជ្រាវ

សូមកត់សម្គាល់ថាប្រធានបទសារណាស្តីពី "**នីតិវិធីនៃការជំនុំជម្រះសាជាថ្មី**" នេះមានវិសាលភាពគ្របដណ្តប់ត្រឹមតែ កម្រិតនៃការជំនុំជម្រះសាជាថ្មីចំពោះសេចក្តីសម្រេចក្នុងនីតិវិធីអង្គសេចក្តីដែលមានកំណត់នៅក្នុងក្រមនីតិវិធីរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៦ មកដល់បច្ចុប្បន្ន ។ ចំណែកឯ សេចក្តីសម្រេច ក្នុងនីតិវិធីអនុវត្ត ដែលមានដូចជាៈ ដីកាសម្រេចចាប់ផ្តើមការលក់ដោយបង្ខំ និង ដីកាសម្រេចរក្សាការពារ ជាអាទិ៍ មិនត្រូវបានលើកយកមកបកស្រាយក្នុងសារណានេះឡើយ ។

## ៥. វិធីសាស្ត្រនៃការស្រាវជ្រាវ

ប្រភពទិន្នន័យ ដែលត្រូវបានក្លាយជាមូលដ្ឋានក្នុងការសរសេរប្រធានបទសារណានេះ មាន ដូចជាៈ ច្បាប់ និងបទដ្ឋានគតិយុត្តនានា ដែលកំពុងតែត្រូវបានអនុវត្តក្នុងព្រះរាជាណាចក្រកម្ពុជា នាពេលបច្ចុប្បន្ន ក៏ដូចជាឯកសារជំនួយស្មារតីផ្នែកច្បាប់ ដែលត្រូវបានចងក្រងដោយអ្នកជំនាញ ការផ្នែកច្បាប់នានានៃប្រទេស

កម្ពុជា និងប្រទេសជប៉ុន ដែលនេះគឺជាកត្តាយ៉ាងចម្បងក្នុងការធ្វើឱ្យ ប្រធានបទសារណានេះដើរទាន់សម័យកាល ។ ទិន្នន័យដែលមាននៅក្នុងសារណានេះ ត្រូវបាន ប្រមូលយកមក តាមរយៈការអានឯកសារដូចបានរៀបរាប់ខាងលើ និងតាមរយៈការសាកសួរអ្នក វិជ្ជាជីវៈ ដែលកំពុងតែអនុវត្តផ្ទាល់រួមមាន៖ ចៅក្រម មេធាវី ជាអាទិ៍ ចំពោះបញ្ហានានាដែលកើតមាន ឡើងក្នុងការអនុវត្តនីតិវិធីនៃការជំនុំជម្រះសាជាថ្មី ។

## ៦. រចនាសម្ព័ន្ធនៃការស្រាវជ្រាវ

ដើម្បីទទួលបាននូវមូលដ្ឋានមួយក្នុងការអនុវត្តដំណើរការ នីតិវិធីនៃការជំនុំជម្រះសាជាថ្មី ប្រកបដោយភាពច្បាស់លាស់ ដូចបានលើកឡើងខាងលើ ប្រធានបទសារណាស្តីពី "**នីតិវិធីនៃការជំនុំជម្រះសាជាថ្មី**" ត្រូវបានបែងចែកចេញជា ០៣ (បី)ជំពូក ដែលមានខ្លឹមសារដូចខាងក្រោម៖

**ជំពូកទី១** ៖ សញ្ញាណទូទៅនៃការជំនុំជម្រះសាជាថ្មី

**ជំពូកទី២** ៖ បណ្តឹងទាមទារឱ្យជំនុំជម្រះសាជាថ្មី

**ជំពូកទី៣** ៖ ចំណាត់ការលើបណ្តឹងទាមទារឱ្យជំនុំជម្រះសាជាថ្មី

# ជំពូកទី ១
# សញ្ញាណទូទៅនៃការជំនុំជម្រះសាជាថ្មី

# ជំពូកទី១
# សញ្ញាណទូទៅនៃការជំនុំជម្រះសាជាថ្មី

ការជំនុំជម្រះសាជាថ្មី គឺជានីតិវិធីរដ្ឋប្បវេណីមួយដែលអនុញ្ញាតឱ្យភាគីដែលទទួលរងនូវភាពអយុត្តិធម៌ដោយការសម្រេចសេចក្តីដោយមានចំនុចខ្វះចន្លោះ នៅក្នុងដំណើរការនីតិវិធីនៃបណ្តឹង ឬ ឯកសារដែលជាមូលដ្ឋាននៃសេចក្តីវិនិច្ឆ័យលើសាលក្រម ឬ សាលដីកានោះមានវិការៈធ្ងន់ធ្ងរ ឬ មានភាពខ្វះខាតមិនប្រក្រតីនោះ ដែលបានចូលជាស្ថាពររួចហើយ អាចធ្វើបណ្តឹងស្នើសុំឱ្យតុលាការដែលបានចេញសាលក្រម ឬ សាលដីកាចុងក្រោយនោះធ្វើការពិនិត្យ និង សម្រេចឱ្យលើកយកនូវសំណុំរឿងដែលបានចូលស្ថាពររួចហើយមកធ្វើការវិនិច្ឆ័យ ឡើងវិញម្តងទៀត ។ ដើម្បីឱ្យការសិក្សាអំពីការជំនុំជម្រះសាជាថ្មី មានភាពស៊ីជម្រៅ និង ក្បោះក្បាយប្រកបដោយប្រសិទ្ធិភាពនោះចំណុចដែលត្រូវយកមកសិក្សាដំបូងគេគឺ សញ្ញាណនៃការជំនុំជម្រះសាជាថ្មី ដែលរួមមាន៖ គោលបំណង (ផ្នែកទី១) និង រចនាសម្ព័ន្ធនៃការជំនុំជម្រះសាជាថ្មី (ផ្នែកទី២)។

## ផ្នែកទី១.គោលបំណងនៃការជំនុំជម្រះសាជាថ្មី

គោលបំណងចម្បងនៃការជំនុំជម្រះសាជាថ្មី គឺជាការផ្តល់នូវនីតិវិធីឧបាស្រ័យពិសេស (កថាភាគទី ១) ទៅដល់ភាគីដែលទទួលរងនូវការខាតបង់ផលប្រយោជន៍ចំពោះសាលក្រម ឬសាលដីកា ដែលបានចូលជាស្ថាពរដោយមានផ្ទុកវិការៈធ្ងន់ធ្ងរ ដើម្បីជាការធានានូវគោលការណ៍ជម្រះក្តីដោយយុត្តិធម៌ (កថាខណ្ឌទី ២) ស្របតាមលក្ខខណ្ឌច្បាប់ និងការពារសិទ្ធិស្របច្បាប់របស់បុគ្គលដែលពាក់ព័ន្ធ (កថាខណ្ឌទី ៣) ជាអាទិ៍។




( រូបទី១ ) រូបភាពស្តីពីគោលបំណងនៃបណ្តឹងទាមទារឱ្យជំនុំជម្រះសាជាថ្មី

**កថាភាគទី១៖ ការផ្តល់នូវវិធីនីតិវិធីឧបាស្រ័យពិសេស**

ជាទូទៅ នៅពេលដែលសាលក្រម ឬ សាលដីកាចុងក្រោយមួយបានចូលជាស្ថាពររួចហើយ នោះអានុភាពនៃអាជ្ញាអស់ជំនុំនឹងត្រូវកើតមានឡើង ដែលជាហេតុនាំឱ្យភាគីនៃរឿងក្តីមិនអាចប្តឹងឧបាស្រ័យចំពោះសាលក្រម ឬ សាលដីកានោះបានទៀតឡើយ[1]។ ប៉ុន្តែប្រសិនបើក្នុងករណី ត្រូវបានរកឃើញថា សាលក្រម ឬ សាលដីកាស្ថាពរចុងក្រោយនោះ មានវិការៈធ្ងន់ធ្ងរក្នុងដំណើរការនៃនីតិវិធីស្របតាមលក្ខខណ្ឌច្បាប់កំណត់ នោះភាគីនៃរឿងក្តីអាចធ្វើការដាក់ពាក្យស្នើសុំលុបចោលសាលក្រម ឬ សាលដីកាស្ថាពរចុងក្រោយដោយហេតុថាមានវិការៈធ្ងន់ធ្ងរក្នុងសាលក្រម ឬ សាលដីកាស្ថាពរនោះ។

**កថាភាគទី២៖ ការធានាគោលការណ៍ជម្រះក្តីដោយយុត្តិធម៌**

ប្រសិនបើមិនអាចអនុញ្ញាតឱ្យមានការលុបចោលនូវសាលក្រម ឬ សាលដីកាស្ថាពរ បានទាល់តែសោះ បើទោះបីជារកឃើញថា មានវិការៈធ្ងន់ធ្ងរក៏ដោយនោះ វាហាក់បីដូចជាមានភាពផ្ទុយទៅនឹងទស្សនៈស្តីពីការសម្រេចសេចក្តីដោយយុត្តិធម៌ តាមរយៈនីតិវិធីនៃបណ្តឹងដែលប្រកបដោយភាពត្រឹមត្រូវមួយ ហើយនាំឱ្យមានការប៉ះពាល់ទៅដល់សិទ្ធិ និង ផលប្រយោជន៍របស់ភាគីដែលពាក់ព័ន្ធ ។ ដោយយល់ឃើញថា យុត្តិធម៌នឹងត្រូវបានបំពាន ក្នុងករណីបើមិនអនុញ្ញាតឱ្យលុបចោលសាលក្រម ឬ សាលដីកាស្ថាពរដែលមានវិការៈធ្ងន់ធ្ងរ ហេតុដូច្នេះហើយបានជាក្រមនីតិវិធីរដ្ឋប្បវេណីបានបញ្ញត្តិចំពោះករណីមួយចំនួន ដែលច្បាប់អនុញ្ញាតឱ្យមាននូវការលុបចោលសាលក្រម ឬ សាលដីកាស្ថាពរនោះ ។ លើសពីនេះ ការទទួលបានការជំនុំជម្រះដោយយុត្តិធម៌ គឺជាខ្សែម៉ែត្រសំខាន់មួយសម្រាប់វាយតម្លៃពីភាពជឿជាក់បាន និងសេចក្តីថ្លៃថ្នូរនៃប្រព័ន្ធយុត្តិធម៌។

**កថាភាគទី៣៖ ការការពារសិទ្ធិស្របច្បាប់បុគ្គលពាក់ព័ន្ធ**

សិទ្ធិទទួលបានការជំនុំជម្រះដោយយុត្តិធម៌ ដើរតួនាទីយ៉ាងសំខាន់ក្នុងការបង្ការភាពអយុត្តិធម៌ តាមរយៈការការពារអ្នកគ្មានកំហុសពីភាពអយុត្តិធម៌ និងការធានានូវសិទ្ធិស្របច្បាប់ទាំងឡាយចំពោះភាគីនៃរឿងក្តី រួមជាមួយនិងតតិយជនផងដែរ។ សិទ្ធិស្របច្បាប់ទាំងនេះ ប្រមូលផ្តុំនូវសិទ្ធិជាមូលដ្ឋានដូចជា សិទ្ធិប្តឹងទៅតុលាការ សិទ្ធិទទួលបានការជំនុំជម្រះជាសាធារណៈ សិទ្ធិស្មើភាព សិទ្ធិទទួលបានការជំនុំជម្រះដោយតុលាការមានសមត្ថកិច្ច ឯករាជ្យ និងមិនលំអៀង សិទ្ធិទទួលបានការជំនុំជម្រះរហ័ស សិទ្ធិមានមេធាវីជាអាទិ៍ ។ សិទ្ធិទាំងនេះមានទំនាក់ទំនងគ្នាទៅវិញទៅមក ហេតុដូចនេះការរំលោភបំពានលើសិទ្ធិណាមួយក៏អាចរំលោភបំពានសិទ្ធិផ្សេងទៀតដែរ។ ម្យ៉ាងវិញទៀត ប្រសិនបើសិទ្ធិស្របច្បាប់ទាំងនេះ មិនត្រូវបានគោរព និងការពារឱ្យបានល្អ នោះសាធារណជននឹងបាត់បង់ជំនឿទៅប្រព័ន្ធយុត្តិធម៌ អាស្រ័យហេតុនេះយើងអាចនិយាយបានថា ការការពារសិទ្ធិស្របច្បាប់របស់បុគ្គលនៅក្នុងរឿងក្តីមួយ គឺជាគោលការណ៍មូលដ្ឋាននៃសង្គមដ៏ត្រឹមត្រូវមួយ។

[1] មាត្រា១៩៤, ក្រមនីតិវិធីរដ្ឋប្បវេណី, លេខ នស/រកម/០៧០៦/០២១, ០៦ កក្កដា ២០០៦

## ផ្នែកទី២. រចនាសម្ព័ន្ធនៃការជំនុំជម្រះសាជាថ្មី

ការជំនុំជម្រះសាជាថ្មី មានបញ្ញត្តក្នុងគន្ថីទី៤ នៃក្រមនីតិវិធីរដ្ឋប្បវេណី ចាប់ពីមាត្រា ៣០៧ ដល់មាត្រា ៣១៨ ។ ដើម្បីឱ្យមានភាពងាយស្រួលក្នុងការស្វែងរក និងយល់ដឹងពីលំហូរនៃនីតិវិធី ដែលមានកំណត់ក្នុងក្រមនីតិវិធីរដ្ឋប្បវេណី រចនាសម្ព័ន្ធនៃការជំនុំជម្រះសាជាថ្មីអាចត្រូវបានកំណត់ ដោយផ្អែកតាមទីតាំងក្នុងក្រមនីតិវិធីរដ្ឋប្បវេណីដូចខាងក្រោម ។

( រូបទី២ ) រចនាសម្ព័ន្ធផ្អែកតាមទីតាំងក្នុងក្រមនីតិវិធិរដ្ឋប្បវេណី



# ជំពូកទី២

# ការធ្វើបណ្ដឹងតាមការជំនុំជម្រះសាជាថ្មី

# ជំពូកទី២

# ការធ្វើបណ្តឹងទាមទារជំនុំជម្រះសាជាថ្មី

បណ្តឹង គឺជាសកម្មភាពទាមទារមួយ ដែលដើមចោទធ្វើឡើងចំពោះចុងចម្លើយ នៅតុលាការ ដោយលើកឡើងអំពីអត្ថិភាព ឬ នត្ថិភាពនៃសិទ្ធិ ឬ ទំនាក់ទំនងគតិយុត្តតាមផ្លូវច្បាប់នីតិឯកជនមួយ ហើយទាមទារឱ្យតុលាការចេញសាលក្រម ដែលមានខ្លឹមសារជាកំណត់មួយដោយផ្អែកតាមភស្តុតាង និងគតិច្បាប់ ហើយជាគោលការណ៍ទូទៅ សកម្មភាពនៃបណ្តឹងនេះ ត្រូវធ្វើឡើងដោយវិធីដាក់ពាក្យ បណ្តឹង[2]។ យ៉ាងណាមិញ បណ្តឹងទាមទារឱ្យជំនុំជម្រះសាជាថ្មី ក៏មានលក្ខខណ្ឌគ្រឹះមិនខុសគ្នាពីបណ្តឹងធម្មតាដែរ គឺអាចត្រូវបានធ្វើឡើងតាមរយៈវិធីដាក់ពាក្យបណ្តឹងទាមទារឱ្យជំនុំជម្រះសាជាថ្មី ដោយត្រូវអនុលោម តាមលក្ខខណ្ឌដ៏តឹងរ៉ឹង ដែលមានបញ្ញត្តក្នុងច្បាប់ បើមិនដូចនេះទេ បណ្តឹងទាមទារឱ្យជំនុំជម្រះសាជាថ្មី អាចនឹងត្រូវក្លាយជាកម្មវត្ថុនៃការច្រានចោល ឬ លើកចោលដោយតុលាការ ។ ហេតុដូចនេះ ហើយ ដើម្បីជៀសវាងកុំឱ្យមានបាតុភូតអសកម្មជាអតិបរិមាច្រើនពេកនោះ ភាគីចាំបាច់ត្រូវគោរពតាម លក្ខខណ្ឌគ្រឹះ (ផ្នែកទី១) ក៏ដូចជា លក្ខខណ្ឌទម្រង់ (ផ្នែកទី២) នៃបណ្តឹងទាមទារឱ្យជំនុំជម្រះសាជាថ្មី ដូចដែលមានកំណត់នៅក្នុងជំពូកទី២ នេះ ។

## ផ្នែកទី១.លក្ខខណ្ឌគ្រឹះ

បណ្តឹងទាមទារឱ្យជំនុំជម្រះសាជាថ្មីចំពោះរឿងក្តីដែលត្រូវបានបញ្ចប់ដោយសាលក្រម ឬ សាលដីកាចុងក្រោយដែលបានចូលជាស្ថាពររួចហើយនោះ តម្រូវឱ្យដើមចោទនៃបណ្តឹងទាមទារជំនុំជម្រះសាជាថ្មី ត្រូវធ្វើការអះអាងនូវមូលហេតុនៃការជំនុំជម្រះសាជាថ្មី (កថាខណ្ឌទី១) យ៉ាងជាក់លាក់ដូចមានបញ្ញត្តក្នុងច្បាប់ ដោយមានកម្មវត្ថុជាសាលក្រម ឬ សាលដីកា ឬ ដីកាសម្រេចបានចូលជាស្ថាពរហើយ (កថាខណ្ឌទី២) មានភាគី និងមានការគោរពតាមការកម្រិតអំឡុងពេល ដូចមានកំណត់ក្នុងច្បាប់ (កថាខណ្ឌទី៣) ដោយតម្រូវឲបំពេញភាពបង្គ្រប់កិច្ច (កថាខណ្ឌទី ៤) ឲបានត្រឹមត្រូវ ។

### កថាភាគទី១.កម្មវត្ថុនៃបណ្តឹងទាមទារជំនុំជម្រះសាជាថ្មី

ជាគោលការណ៍ កម្មវត្ថុនៃបណ្តឹងទាមទារជំនុំជម្រះសាជាថ្មី គឺសាលក្រម ឬ សាលដីកា ក៏ប៉ុន្តែមានករណីខ្លះ ដីកាសម្រេចក៏អាចជាកម្មវត្ថុនៃបណ្តឹងទាមទារជំនុំជម្រះសាជាថ្មីដែរ ។

**១.សាលក្រម ឬ សាលដីកា**

កម្មវត្ថុចម្បងនៃបណ្តឹងទាមទារជំនុំជម្រះសាជាថ្មី គឺសាលក្រម ឬសាលដីកាចុងក្រោយដែលចូលជាស្ថាពរ[3]ហើយមានវិការៈធ្ងន់ធ្ងរក្នុងនីតិវិធីបណ្តឹង ។

[2] សេចក្តីពន្យល់អំពីក្រមនីតិវិធីរដ្ឋប្បវេណី ភាគ១ នីតិវិធីបណ្តឹង ឆ្នាំ២០០៨.

[3] មាត្រា ៣០៧, ក្រមនីតិវិធីរដ្ឋប្បវេណី, លេខ នស/រកម / ០៧០៦, ០៦ កក្កដា ២០០៦

សាលក្រម ឬ សាលដីកាចុងក្រោយសំដៅដល់សេចក្តីសម្រេចរបស់តុលាការបញ្ចប់ការវិនិច្ឆ័យលើអង្គសេចក្តីទាំងមូល ឬមួយផ្នែក ដែលមានអានុភាពអាជ្ញាអស់ជំនុំ ដែលរួមមាន៖ សាលក្រម ឬ សាលដីកាទទួលស្គាល់ការទាមទារ និង សាលក្រម ឬ សាលដីកាច្រានចោលការទាមទារ។

មួយវិញទៀតសាលក្រមរបៀប ដែលជាសេចក្តីសម្រេចជាមូលដ្ឋាននៃសាលក្រម ឬ សាលដីកា ពុំមែនជាកម្មវត្ថុដែលអាចធ្វើបណ្តឹងទាមទារជំនុំជម្រះសាជាថ្មីដោយឯករាជ្យបាននោះទេ ប៉ុន្តែក្នុងករណីមានមូលហេតុនៃការជំនុំជម្រះសាជាថ្មី ចំពោះសាលក្រមរបៀប ភាគីអាចយកមូលហេតុនៃការជំនុំជម្រះសាជាថ្មី យោងតាមមាត្រា ៣០៧ នៃក្រមនីតិវិធីរដ្ឋប្បវេណី ដែលកើតលើសាលក្រមរបៀបនោះ មកធ្វើការទាមទារជំនុំជម្រះសាជាថ្មីចំពោះសាលក្រម ឬ សាលដីកាដែលចូលជាស្ថាពរ ទោះបីសាលក្រម ឬ សាលដីកាចុងក្រោយនោះមាន ឬ គ្មានអត្ថិភាពនៃមូលហេតុនៃការជំនុំជម្រះសាជាថ្មីក៏ដោយ ។ ក្នុងករណីដែលសាលក្រមរបៀបជាកម្មវត្ថុនៃការជំនុំជម្រះសាជាថ្មី ត្រូវបានលុបចោល និង សម្រេចសាជាថ្មី នោះសាលក្រមរបៀបថ្មី នឹងក្លាយទៅជាកម្មវត្ថុនៃការកែប្រែសេចក្តីសម្រេចបញ្ចប់នៃសាលក្រម ឬ សាលដីកាចុងក្រោយដែលបានចូលជាស្ថាពរហើយ ។ ដូចនេះ ដើម្បីកាត់បន្ថយឱ្យបានជាអតិបរមានូវការចំណាយពេលវេលា និងធនធានឥតប្រយោជន៍ចំពោះការជំនុំជម្រះជាច្រើនលើកច្រើនសារបែបនេះ មាត្រា ៣០៨ នៃក្រមនីតិវិធីរដ្ឋប្បវេណី អនុញ្ញាត ឱ្យមានរបបនៃការយកមូលហេតុនៃការជំនុំជម្រះសាជាថ្មីលើសាលក្រមរបៀប ទៅធ្វើការទាមទារ លើសាលក្រម ឬ សាលដីកាចុងក្រោយដែលបានចូលជាស្ថាពរតែម្តង ។

**២.ដីកាសម្រេច**

ដីកាសម្រេច ក៏អាចជាកម្មវត្ថុនៃការទាមទារឱ្យជំនុំជម្រះសាជាថ្មីបានដែរ ក្នុងករណីដែល ដីកាសម្រេចនោះ គឺជាដីកាសម្រេចដែលអាចប្តឹងឧបាស្រ័យទៅតុលាការជាន់ខ្ពស់ដោយបណ្តឹង ជំទាស់ និងដែលបានចូលជាស្ថាពរ ។

ការទាមទារឱ្យជំនុំជម្រះសាជាថ្មីលើដីកាសម្រេច អាចចាប់ ផ្តើមឡើងដោយឯករាជ្យ តាមរយៈពាក្យសុំទាមទារឱ្យជំនុំជម្រះសាជាថ្មី ដែលត្រូវអនុវត្តដូចគ្នាទៅ នឹងបញ្ញត្តិស្តីពីពាក្យបណ្តឹងទាមទារឱ្យជំនុំជម្រះសាជាថ្មី ដែលមានកំណត់ចាប់ពីមាត្រា ៣០៧ ដល់ មាត្រា៣១៦ នៃក្រមនីតិវិធីរដ្ឋប្បវេណី ។

ដីកាសម្រេចដូចមានកំណត់ក្នុងមាត្រា ៣១៧ មានជាអាទិ៍៖ ដីកាសម្រេចដែលសម្រេចថា ការដកហូត ឬ បណ្តឹងដិតចិត្តពុំត្រឹមត្រូវ (មាត្រា ៣០ កថាខណ្ឌទី៦) និងដីកាសម្រេចអំពីការ បដិសេធនូវការផ្តល់ចម្លើយជាកសិណសាក្សី (មាត្រា ១៣៥ កថាខណ្ឌទី២) ជាដើម ។ បន្ថែមពីនេះ ដីកាសម្រេចដែលជាសេចក្តីសម្រេចបញ្ចប់ដូចមានកំណត់ក្នុងច្បាប់ស្តីពីនីតិវិធី នៃរឿងក្តីរដ្ឋប្បវេណីដែលមិនមែនជាបណ្តឹង ក៏អាចជាកម្មវត្ថុនៃពាក្យសុំទាមទារឱ្យជំនុំជម្រះសាជាថ្មី តាមមាត្រា ៣១៧ ខាងលើនេះដែរ ប្រសិនបើដីកាសម្រេចនោះមានមូលហេតុជំនុំជម្រះសាជាថ្មី ។

**កថាខណ្ឌទី២.មូលហេតុនៃការជំនុំជម្រះសាជាថ្មី**

យើងដឹងហើយថា មូលហេតុនៃការជំនុំជម្រះសាជាថ្មី ជាលក្ខខណ្ឌមួយ ដែលនាំឱ្យការជំនុំជម្រះសាជាថ្មី មានលក្ខណៈពិសេសជាងបណ្តឹងរដ្ឋប្បវេណីផ្សេងៗទៀត ដោយហេតុថា មូលហេតុទាំងអស់នេះគឺជាកត្តាដែលជម្រុញឱ្យមានដំណើរការនៃនីតិវិធីនៃការជំនុំជម្រះសាជាថ្មីលើសាលក្រម ឬ សាលដីកា ដែលបានចូលជាស្ថាពរ (អាជ្ញាអស់ជំនុំ) រួចទៅហើយ ។

មូលហេតុនៃការជំនុំជម្រះសាជាថ្មី យោងតាមមាត្រា ៣០៧ កថាខណ្ឌទី១ នៃក្រមនីតិវិធីរដ្ឋប្បវេណី មានចំនួន ១០ (ដប់) មូលហេតុផ្សេងគ្នា ដែលមានលំដាប់រៀងពី **ក** ដល់ **ញ** ។ មូលហេតុទាំងនេះ អាចត្រូវបានបែងចែកចេញជា ០៥ (ប្រាំ) ករណីធំៗ ដែលរួមមាន៖ ករណីដែលមានការបំពាននីតិវិធីធ្ងន់ធ្ងរ (១.១) ករណីដែលមានភាពមិនប្រក្រតីនៃមូលដ្ឋាននៃសាលក្រម ឬ សាលដីកា ដែលបានចូលជាស្ថាពរ (១.២) ករណីដែលមានកង្វះនៃការវិនិច្ឆ័យរបស់តុលាការនៅក្នុងសាលក្រម ឬ សាលដីកាដែលបានចូលជាស្ថាពរ (១.៣) ករណីដែលសាលក្រម ឬសាលដីកាជាអាទ៍ ដែលជាមូលដ្ឋាននៃសាលក្រម ឬសាលដីកាដែលបានចូលជាស្ថាពរ ត្រូវបានផ្លាស់ប្តូរ (១.៤) និងករណីដែលមសារនៃសាលក្រម ឬ សាលដីកាដែលបានចូលជាស្ថាពរផ្ទុយគ្នានឹងខ្លឹមសារនៃសាលក្រម ឬ សាលដីកាមុនដែលបានចូលជាស្ថាពរ (១.៥)។ បន្ថែមពីលើមូលហេតុទាំងនេះ ក៏នៅមានករណីពិសេស មួយផ្សេងទៀត ដូចមានកំណត់ក្នុង មាត្រា ៣១៨ នៃក្រមនីតិវិធីរដ្ឋប្បវេណី ផងដែរ។

**១.ករណីដែលមានការបំពាននីតិវិធីធ្ងន់ធ្ងរ**[4]

សាលក្រម ឬ សាលដីកា ដែលចូលជាស្ថាពរអាចចងភាគីបាន ទាល់តែមានការធានានូវនីតិវិធីត្រឹមត្រូវ ។ ប៉ុន្តែ បើសិនជាមានការធ្វើផ្ទុយនឹងនីតិវិធីធ្ងន់ធ្ងរ គឺមិនមានការធានាអំពីនីតិវិធីទេ។ ដូច្នេះ ល័ក្ខខ័ណ្ឌដែលជាអានុភាពអាចចងសាលក្រម ឬសាលដីកានោះពុំមានទេ។ ហេតុនេះហើយ ការធ្វើផ្ទុយនឹងនីតិវិធី គឺជាមូលហេតុនៃការជំនុំជម្រះសាជាថ្មី ទោះជាការធ្វើផ្ទុយនឹងនីតិវិធីនោះមានឥទ្ធិពលទៅ លើខ្លឹមសារនៃសាលក្រម ឬសាលដីកានោះ ឬគ្មានក៏ដោយ។ ករណីដែលមាន ការបំពាននីតិវិធីធ្ងន់ធ្ងរនេះត្រូវបានកំណត់នៅក្នុងចំណុច **ក** ចំណុច **ខ** និង ចំណុច **គ** នៃមាត្រា ៣០៧ កថាខណ្ឌទី១ នៃក្រមនីតិវិធីរដ្ឋប្បវេណី។

**ក-បើពុំបានចាត់តាំងតុលាការដែលបានចេញសាលក្រម ឬ សាលដីកា ទៅតាមច្បាប់កំណត់**[5]

ឧទាហរណ៍៖

- ការសម្រេចសេចក្តីត្រូវធ្វើដោយក្រុមប្រឹក្សាជំនុំជម្រះ៣រូប តែបែរជាទៅធ្វើការសម្រេចសេចក្តីដោយ២រូបទៅវិញ[6] ។

[4] បទបង្ហាញនៅក្នុងសិក្ខាសាលាស្តីពីបញ្ហានានា ដែលមាននៅក្នុងរឿងក្តីរដ្ឋប្បវេណី,១៧ មករា ២០១៨

[5] មាត្រា ៣០៧ កថាខណ្ឌទី ១ វាក្យខណ្ឌទី ១ ចំណុច ក, ក្រមនីតិវិធីរដ្ឋប្បវេណី, លេខ នស/រមក/០៧០៦/០២១, ០៦ កក្កដា ២០០៦,

[6] មាត្រា២៣ កថាខណ្ឌទី៣, ក្រមនីតីវិធីរដ្ឋប្បវេណី, លេខ នស/រកម/០៧០៦/០២១, ០៦ កក្កកដា ២០០៦

- " **ក** " ជាដើមចោទ (ជាកូនរបស់ " **ខ** " តាមរយៈសំបុត្រកំណើត) ចំណែក " **ខ** " ជាចុងចម្លើយ ( រស់នៅក្នុងខេត្តកណ្តាល )។ " **ក** " បានដាក់ពាក្យបណ្តឹងមក សាលាដំបូងរាជធានីភ្នំពេញ ឱ្យចេញសាលក្រម ទទួលស្គាល់ថា " **ក** " មិនមែនជាកូនរបស់ " **ខ** " (បណ្តឹងបដិសេធបិតុភាពពីកូន) ហើយសាលក្រមរបស់សាលក្រមរបស់សាលាដំបូងនេះបានចូលជាស្ថាពរ។

ផ្អែកតាមច្បាប់ទម្រង់ (ច្បាប់ស្តីពីនីតិវិធីបណ្តឹងទាក់ទងនឹងឋានៈបុគ្គល ) បណ្តឹងបដិសេធបិតុភាពពីកូន ត្រូវដំណើការតាមនីតិវិធីបណ្តឹងទាក់ទងនឹងឋានៈបុគ្គល ដោយស្ថិតក្រោមសមត្ថកិច្ចផ្តាច់មុខ ហើយអង្គហេតុខាងលើនេះ ត្រូវស្ថិតក្រោមសមត្ថកិច្ចរបស់សាលាដំបូងខេត្តកណ្តាល ប៉ុន្តែសាលាដំបូងរាជធានីភ្នំពេញបែរជាចេញសាលក្រម និង សាលក្រមនេះបានចូលជាស្ថាពរ។ ករណីនេះ ហៅថា " តុលាការដែលបានចេញសាលក្រមពុំបានទទួលការចាត់តាំងតាមច្បាប់កំណត់ " ដែលនាំឱ្យសាលក្រមនេះផ្ទុកនូវមូលហេតុនៃការជំនុំជម្រះសាជាថ្មី។

**ខ.បើចៅក្រមដែលពុំអាចចូលរួមក្នុងការចេញសាលក្រម ឬ សាលដីកាតាមច្បាប់ បានចូលរួមក្នុងការចេញសាលក្រម ឬ សាលដីកានោះ**[7]

ឧទាហរណ៍៖

- មានមូលហេតុដកហូតចៅក្រមចេញ[8] តាមមាត្រា ២៧ នៃក្រមនីតិវិធីរដ្ឋប្បវេណី តែចៅក្រមនោះបាន ចូលរួមក្នុងការវិនិច្ឆ័យ ជំនុំជម្រះក្តី និងចេញសាលក្រម ឬ សាលដីកា។
- ចៅក្រមដែលបានចេញសាលក្រម ឬ សាលដីកាដែលជាកម្មវត្ថុនៃបណ្តឹងទាមទារជំនុំជម្រះសាជាថ្មី បានចូលរួម ក្នុងការជំនុំជម្រះ និងសម្រេចសេចក្តីអំពីបណ្តឹងទាមទារជំនុំជម្រះសាជាថ្មីនោះ [9] ។

**គ.បើខ្វះសិទ្ធិតំណាងដែលច្បាប់បានកំណត់ ឬ អ្នកតំណាងដែលច្បាប់បានកំណត់ ខ្វះការប្រគល់សិទ្ធិចាំបាច់សម្រាប់ធ្វើសកម្មភាពបណ្តឹង ឬ ខ្វះសិទ្ធិតំណាងដោយអាណត្តិ [10] ។**

ឧទាហរណ៍៖

" ក " ជាដើមចោទ ចំណែក " ខ " ជាចុងចម្លើយ (នីតិបុគ្គល)។ " ក " បានប្តឹង " ខ " ទៅ សាលាដំបូងរាជធានីភ្នំពេញ ទាមទារឱ្យចេញសាលក្រមបង្គាប់ឱ្យ " ខ " បង់ប្រាក់។ សាលក្រមរបស់សាលាដំបូងនេះបានចូលជាស្ថាពរ។ សន្មតថានៅពេលដំណើរការរឿងក្តី " ខ " បានចាត់ " គ "ដែលជាបុគ្គលិកផ្នែកច្បាប់ មក

[7] មាត្រា ៣០៧ កថាខណ្ឌទី ១ វាក្យខណ្ឌទី ១ ចំណុច ខ, ក្រមនីតិវិធីរដ្ឋប្បវេណី, លេខ នស/រមក/០៧០៦/០២១, ០៦ កក្កដា ២០០៦

[8] មាត្រា ២៧ ក្រមនីតិវិធីរដ្ឋប្បវេណី លេខ នស/រមក/០៧០៦/០២១, ០៦ កក្កដា ២០០៦

[9] មាត្រា ៣០៩ កថាខណ្ឌទី ៣ក, ក្រមនីតីវិធីរដ្ឋប្បវេណី, លេខ នស/រមក/០៧០៦/០២១, ០៦ កក្កដា ២០០៦

[10] មាត្រា ៣០៧ កថាខណ្ឌទី ១ វាក្យខណ្ឌទី៣ ចំណុច គ, ក្រមនីតីវិធីរដ្ឋប្បវេណី, លេខ នស/រមក/០៧០៦/០២១, ០៦ កក្កដា ២០០៦

ធ្វើជា អ្នកតំណាងឱ្យខ្លួនក្នុងការដំណើរការរឿងក្តីនៅតុលាការ។ ករណីនេះ " គ " គ្មានលក្ខណៈសម្បត្តិធ្វើជាអ្នកតំណាងឱ្យ " ខ " នៅចំពោះមុខតុលាការនោះទេ សកម្មភាពនេះ ហៅថា " កង្វះសិទ្ធិតំណាង [11] "។

**២.ភាពមិនប្រក្រតីនៃសេចក្តីសម្រេចដែលជាមូលដ្ឋាននៃសាលក្រម ឬសាលដីកា** [12]

ករណីដែលមានភាពមិនប្រក្រតីនៃសេចក្តីសម្រេចដែលជាមូលដ្ឋាននៃសាលក្រម ឬ សាលដីកាដែលចូលជាស្ថាពរ មាន ៥ (ប្រាំ) មូលហេតុ ដែលមានកំណត់ក្នុងចំណុច **ឃ** ចំណុច **ង** ចំណុច **ច** ចំណុច **ឆ** និង ចំណុច **ជ** នៃមាត្រា ៣០៧ កថាខណ្ឌទី១ នៃក្រមនីតិវិធីរដ្ឋប្បវេណី។

**ឃ-បើចៅក្រមដែលបានចូលរួមក្នុងការចេញសាលក្រម ឬ សាលដីកា បានប្រព្រឹត្តអំពើល្មើសដែលពាក់ព័ន្ធនឹងមុខងាររបស់ខ្លួនចំពោះរឿងក្តី [13] ។**

ករណីនេះ ពាក់ព័ន្ធនឹងអំពើល្មើសរបស់ចៅក្រម ដែលទាមទារឱ្យមានការចូលជាស្ថាពរនៃសាលក្រម ឬ សាលដីកាដែលផ្តន្ទាទោស ឬ សេចក្តីសម្រេចដាក់ប្រាក់ពិន័យ ចំពោះអំពើល្មើសនោះ ដោយមិនចាំបាច់ពិចារណាថា អំពើដែលត្រូវដាក់ទណ្ឌកម្មនោះ មាន ឬ គ្មានឥទ្ធិពលទៅលើលទ្ធផលនៃសាលក្រម ឬ សាលដីកានោះទេ ឱ្យតែមានវត្តមាននៃអំពើល្មើសគឺគ្រប់គ្រាន់។

ឧទាហរណ៍៖

បទស៊ីសំណូកប្រព្រឹត្តដោយចៅក្រម[14] ៖ ចៅក្រមទទួលសំណូកពីភាគីណាមួយហើយសម្រេចឱ្យភាគីនោះឈ្នះក្តី ក្នុងសាលក្រម ឬ សាលដីកា ។

**ង-បើភាគីបានសារភាព ឬ ត្រូវបានរារាំងក្នុងការដាក់មធ្យោបាយតទល់ ឬមធ្យោបាយការពារខ្លួនដែលមានឥទ្ធិពលដល់សាលក្រម ឬ សាលដីកា ដោយសារបទល្មើសអ្នកដទៃ [15] ។**

ករណីនេះ ទាមទារឱ្យមានការចូលជាស្ថាពរនៃសាលក្រម ឬ សាលដីកាដែលផ្តន្ទាទោស ឬ សេចក្តីសម្រេចដាក់ប្រាក់ពិន័យចំពោះអំពើល្មើសនោះ និងទាមទារដាច់ខាតឱ្យអំពើល្មើសនោះ មានឥទ្ធិពលទៅលើលទ្ធផលនៃសាលក្រម ឬ សាលដីកាដែលចូលស្ថាពរ ។

ឧទាហរណ៍៖

បទគំរាមកំហែង[16] ៖ ភាគីម្ខាង ត្រូវបានភាគីម្ខាងទៀតគំរាមថានឹងប្រព្រឹត្តអំពើហិង្សា ប្រសិនបើភាគីនោះ មិនសារភាពអំពីអង្គហេតុ ដែលជាមូលដ្ឋាននៃការចេញសាលក្រម ឬ សាលដីកា ។

---

11 មាត្រា ៣៨, ក្រមនីតិវិធីរដ្ឋប្បវេណី, លេខ នស/រមក/០៧០៦/០២១, ០៦ កក្កដា ២០០៦

12 បទបង្ហាញនៅក្នុងសិក្ខាសាលាស្តីពីបញ្ហា នានា ដែលមាននៅក្នុងរឿងក្តីរដ្ឋប្បវេណី, ១៧ មករា ២០១៨

13 មាត្រា ៣០៧ កថាខណ្ឌទី ១ វាក្យខណ្ឌទី ៤ ចំណុច ឃ, ក្រមនីតីវិធីរដ្ឋប្បវេណី, លេខ នស/រមក/០៧០៦/០២១, ០៦ កក្កដា ២០០៦

14 មាត្រា ៥១៧ក, ក្រមព្រហ្មទណ្ឌ, លេខ នស/រកម/១១០៩/០២២, ៣០ វិច្ឆិកា ២០០៩

15 មាត្រា ៣២ កថាខណ្ឌទី ១ វាក្យខណ្ឌទី ៥ ចំណុច ង, ក្រមនីតីវិធីរដ្ឋប្បវេណី, លេខ នស/រមក/០៧០៦/០២១, ០៦ កក្កដា ២០០៦

16 មាត្រា២៣១, ក្រមព្រហ្មទណ្ឌ, លេខ នស/រកម/១១០៩/០២២, ៣០ វិច្ឆិកា ២០០៩

បទហិង្សា[17] ៖ ភាគីណាម្ខាង ខកខានមិនបានអះអាងអំពីអង្គហេតុ ឬ មិនបានដាក់ភស្តុតាងសំខាន់ ដែលជាមូលដ្ឋានសំខាន់ ដែលជាមូលដ្ឋាននៃសាលក្រម ឬ សាលដីកា ដោយសារខ្លួនជាជនរងគ្រោះនៃអំពើហិង្សា ។

**ច-បើឯកសារ ឬ វត្ថុឯទៀតដែលបានក្លាយជាភស្តុតាងសម្រាប់សាលក្រម ឬ សាលដីកាត្រូវបានក្លែង ឬ កែប្រែដោយបន្លំ[18] ។**

ករណីនេះ ទាមទារឱ្យមានការចូលជាស្ថាពរនៃសាលក្រម ឬ សាលដីកាដែលផ្តន្ទាទោស ឬ សេចក្តីសម្រេចដាក់ប្រាក់ពិន័យចំពោះអំពើល្មើសនោះ និងទាមទារដាច់ខាតឱ្យអំពើនោះ មានឥទ្ធិពលទៅលើលទ្ធផលនៃសាលក្រម ឬ សាលដីកាដែលចូលជាស្ថាពរ ។

ឧទាហរណ៍ ៖

បទក្លែងបន្លំ[19] ៖ " ក " ជាដើមចោទ ចំណែក " ខ " ជាចុងចម្លើយ។ " ក " បានប្ដឹង " ខ " ទៅសាលាដំបូងរាជធានីភ្នំពេញ ដោយទាមទារឱ្យតុលាការចេញសាលក្រម បង្គាប់ឱ្យ " ខ " បង់ប្រាក់ ហើយសាលក្រមរបស់ សាលាដំបូងនេះបានសម្រេចតាមការទាមទាររបស់ " ក " និងបានចូលជាស្ថាពរ ។ សន្មត " ក " មានភស្តុតាង គឺជាកិច្ចសន្យាខ្ចីប្រាក់ និងលិខិតប្រគល់ទទួលប្រាក់ ប៉ុន្តែ " ខ " បដិសេធ ។ ផ្អែកលើភស្តុតាងរបស់ " ក " តុលាការ បានទទួលស្គាល់ការទាមទាររបស់ " ក " ដោយបង្គាប់ឱ្យ " ខ " បង់ប្រាក់ទៅឱ្យ " ក " ហើយសាលក្រមបាន ចូលជាស្ថាពរ។ បន្ទាប់មក " ខ " ទើបដឹងថា លិខិតប្រគល់ទទួលប្រាក់ដែលមានស្នាមម្រាមដៃរបស់ " ខ " ជា ការក្លែងបន្លំរបស់ " ក " គឺមិនមែនជាស្នាមម្រាមដៃរបស់ " ខ " នោះទេ។

**ឆ-បើសេចក្តីថ្លែងការណ៍មិនពិតរបស់សាក្សី អ្នកធ្វើកោសលវិច័យ អ្នកបកប្រែ ភាគីដែលបានធ្វើសម្បថ ឬ របស់អ្នកតំណាងដែលច្បាប់បានកំណត់ដែលបានធ្វើសម្បថ បានក្លាយជាភស្តុតាងសម្រាប់សាលក្រម ឬ សាលដីកា[20] ។**

ករណីនេះ ក៏ទាមទារឱ្យមានការចូលជាស្ថាពរនៃសាលក្រម ឬ សាលដីកា ដែលផ្តន្ទាទោស ឬ សេចក្តីសម្រេចដាក់ប្រាក់ពិន័យចំពោះអំពើល្មើសនោះ និងទាមទារដាច់ខាតឱ្យអំពើល្មើសនោះ មានឥទ្ធិពលទៅលើលទ្ធផលនៃសាលក្រម ឬ សាលដីកាដែលចូលជាស្ថាពរ ។

ឧទាហរណ៍៖

បទផ្តល់សក្ខីកម្មក្លែងក្លាយ[21] ៖ សាក្សីបានផ្តល់សក្ខីកម្មភូតកុហក នៅចំពោះមុខតុលាការ ហើយតុលាការបានសម្រេចសេចក្តី ដោយផ្អែកលើសក្ខីកម្មនោះ ។

[17] មាត្រា២១៧, ក្រមព្រហ្មទណ្ឌ, លេខ នស/រកម/១១០៩/០២២, ៣០ វិច្ឆិកា ២០០៩

[18] មាត្រា ៣២ កថាខណ្ឌទី ១ វាក្យខណ្ឌទី ៦ ចំណុច ច, ក្រមនីតិវិធីរដ្ឋប្បវេណី, លេខ នស/រមក/០៧០៦/០២១, ០៦ កក្កដា ២០០៦

[19] មាត្រា៦២៨, ក្រមព្រហ្មទណ្ឌ, លេខ នស/រកម/១១០៩/០២២, ៣០ វិច្ឆិកា ២០០៩

[20] មាត្រា ៣២ កថាខណ្ឌទី ១ វាក្យខណ្ឌទី ៧ ចំណុច ឆ, ក្រមនីតិវិធីរដ្ឋប្បវេណី, លេខ នស/រមក/០៧០៦/០២១, ០៦ កក្កដា ២០០៦

[21] មាត្រា២៣១, ក្រមព្រហ្មទណ្ឌ, លេខ នស/រកម/១១០៩/០២២, ៣០ វិច្ឆិកា ២០០៩

<u>បទក្លែងដោយអ្នកជំនាញ</u>[22] ៖ អ្នកធ្វើកោសលវិច័យ បានក្លែងដោយចេតនា នូវទិន្នន័យ ឬ លទ្ធផលនៃកោសលវិច័យ នៅក្នុងសេចក្តីថ្លែងការណ៍ ដោយផ្ទាល់មាត់ ឬ របាការណ៍ជាលាយលក្ខណ៍អក្សរ ដែលក្លាយជាមូលដ្ឋាននៃសាលក្រម ឬ សាលដីកា ។

<u>បទស៊ីសំណូករបស់អ្នកបកប្រែ</u>[23] ៖ ដើមចោទ ជាជនបរទេស បានប្តឹងចុងចម្លើយជាជនជាតិខ្មែរ ហើយដើម្បីឱ្យដើមចោទជាជនបរទេសនោះចាញ់ក្តី ចុងចម្លើយបានសូកប៉ាន់អ្នកបកប្រែឱ្យក្លែងខ្លឹមសារនៃភាសាក្នុងសេចក្តីថ្លែងការណ៍ ដែលជាមូលដ្ឋាននៃសាលក្រម ឬ សាលដីកា

<u>អំពើក្លែងបន្លំសេចក្តីថ្លែងការណ៍</u>[24] ៖ ភាគីដែលបានស្បថ ឬ អ្នកតំណាងដែលច្បាប់បានកំណត់ ដែលបានស្បថ បានក្លែងបន្លំសេចក្តីថ្លែងការណ៍របស់ខ្លួន ដែលក្លាយជាមូលដ្ឋាននៃការចេញសាលក្រម ឬ សាលដីកា ។

**៣.ករណីដែលមានការប្តូរសាលក្រម**

**ជ- បើសាលក្រម ឬ សាលដីកា ឬសេចក្តីសម្រេចឯទៀត ផ្នែករដ្ឋប្បវេណី ឬ ផ្នែកព្រហ្មទណ្ឌ ឬការចាត់ចែងរដ្ឋបាល ដែលជាមូលដ្ឋាននៃសាលក្រម ឬ សាលដីកា ត្រូវបានផ្លាស់ប្តូរ ដោយសារសេចក្តីសម្រេច ឬ ការចាត់ចែងផ្នែករដ្ឋបាលនៅពេលក្រោយ[25]។**

ករណីនេះ ទាមទារដាច់ខាតឱ្យការផ្លាស់ប្តូរនៃសេចក្តីសម្រេច ឬ ការចាត់ចែងរដ្ឋបាលនោះមានឥទ្ធិពលទៅលើលទ្ធផលនៃសាលក្រម ឬ សាលដីកាដែលចូលជាស្ថាពរ ។

ឧទាហរណ៍៖ " ក " ជាដើមចោទ ចំណែក «ខ» ជាចុងចម្លើយ។ " ក " បានប្តឹង " ខ " ទៅសាលាដំបូង រាជធានីភ្នំពេញ ដោយទាមទារតុលាការចេញសាលក្រមបង្គាប់ឱ្យ " ខ " បង់ប្រាក់ ផ្អែកលើអំពើអនីត្យានុកូល[26] ករណីឃាតកម្ម) ដោយភ្ជាប់សាលក្រមព្រហ្មទណ្ឌរបស់ សាលាដំបូងបានផ្តន្ទាទោស " ខ " ដែលបានសម្លាប់ " គ " ត្រូវជាកូនរបស់ " ក " បានចូលជាស្ថាពរ។ សន្មតសាលក្រមព្រហ្មទណ្ឌដែលបានចូលជាស្ថាពរនេះមានមូលហេតុនៃការសើរើហេតុនេះ " ខ " បានដាក់បណ្តឹងសើរើទៅតុលាការកំពូលតាមនីតិវិធីព្រហ្មទណ្ឌ [27] ទាមទារឱ្យសើរើសំណុំរឿងឃាតកម្មនេះ។ ជាលទ្ធផល តុលាការកំពូលទទួលយកការទាមទាររបស់ " ខ " មូលហេតុ " គ " ត្រូវបានសម្លាប់ដោយ " ឃ " មិនមែន " ខ " នោះទេ។ ផ្អែកលើសាលដីកាព្រហ្មទណ្ឌដែលបានសើរើ និងលើកលែង

---

22 មាត្រា២១៧, ក្រមព្រហ្មទណ្ឌ, លេខ នស/រកម/១១០៩/០២២, ៣០ វិច្ឆិកា ២០០៩

23 មាត្រា៦២៨, ក្រមព្រហ្មទណ្ឌ, លេខ នស/រកម/១១០៩/០២២, ៣០ វិច្ឆិកា ២០០៩

24 មាត្រា៦២៨, ក្រមព្រហ្មទណ្ឌ, លេខ នស/រកម/១១០៩/០២២, ៣០ វិច្ឆិកា ២០០៩

25 មាត្រា ៣០៧ កថាខណ្ឌទី ១ វាក្យខណ្ឌទី៨ ចំណុច ជ, ក្រមនីតិវិធីរដ្ឋប្បវេណី, លេខ នស/រមក/០៧០៦/០២១, ០៦ កក្កដា ២០០៦

26 មាត្រា ៧៤៣ក, ក្រមរដ្ឋប្បវេណី, លេខ នស/រកម/១២០៧/០៣០, ០៨ ធ្នូ ២០០៧

27 មាត្រា៤៤៣, ក្រមនីតិវិធីព្រហ្មទណ្ឌ, លេខ នស/រកម/០៨០៧/០២៤, ១០ សីហា ២០០៧

ចោទប្រកាន់ចំពោះ " ខ " គឺ " ខ " អាចដាក់បណ្ដឹងទាមទារជំនុំជម្រះសាជាថ្មី ទៅសាលាដំបូងរាជធានីភ្នំពេញចំពោះសាលក្រមរដ្ឋប្បវេណីស្ថាពរ ដែលបានបង្គាប់ឱ្យ " ខ "បង់ប្រាក់មក" ក "។ ករណីនេះហៅថា " សេចក្ដីសម្រេច ផ្នែកព្រហ្មទណ្ឌដែលជាមូលដ្ឋាននៃសាលក្រមរដ្ឋប្បវេណីត្រូវបានផ្លាស់ប្ដូរ "។

**៤.ករណីដែលមានការភ្លេចបញ្ចូលការវិនិច្ឆ័យ**[28]

ចំណុចសំខាន់ ដែលមានកំណត់ក្នុងចំណុច **ឈ** នៃមាត្រា ៣០៧ កថាខណ្ឌទី១ សំដៅដល់មធ្យោបាយតទល់ និងមធ្យោបាយការពារខ្លួន ដែលភាគីបានអះអាង នៅក្នុងនីតិវិធីទាញហេតុផលដោយផ្ទាល់មាត់ ដែលមានឥទ្ធិពលទៅលើលទ្ធផលនៃសាលក្រម ឬ សាលដីកា។

ចំណុចសំខាន់ទាំងនេះ ទាមទារឱ្យតុលាការធ្វើការវិនិច្ឆ័យ និងបង្ហាញពីការវិនិច្ឆ័យរបស់ខ្លួន ក្នុងសំអាងហេតុនៃសាលក្រម ឬ សាលដីកា ។ ដូចនេះ ក្នុងករណីដែលតុលាការមិនបានធ្វើការវិនិច្ឆ័យ លើមធ្យោបាយតទល់ ឬ មធ្យោបាយការពារខ្លួនរបស់ភាគីណាមួយ ដែលនាំឱ្យមានការប្រែប្រួលនូវខ្លឹមសារនៃសាលក្រម ឬ សាលដីកា ភាគីដែលខាតបង់ផលប្រយោជន៍ ដោយសារលទ្ធផលនៃសាលក្រម ឬ សាលដីកានេះ អាចធ្វើការទាមទារឱ្យជំនុំជម្រះសាជាថ្មីបាន ដោយផ្អែកលើមូលហេតុដូចមានកំណត់ក្នុងចំណុច **ឈ** នេះ ។

**ឈ-បើមានការភ្លេចបញ្ចូលសេចក្ដីវិនិច្ឆ័យលើចំណុចសំខាន់ៗ ដែលមានឥទ្ធិពលទៅលើសាលក្រម ឬ សាលដីកា**[29] **។**

ឧទាហរណ៍៖ " ក " ជាដើមចោទ ចំណែក " ខ " ជាចុងចម្លើយ។ " ក " បានប្ដឹង " ខ " ទៅសាលាដំបូង រាជធានីភ្នំពេញ ដោយទាមទារឱ្យតុលាការចេញសាលក្រមបង្គាប់ឱ្យ " ខ " បង់ប្រាក់ ហើយសាលក្រមរបស់ សាលាដំបូងនេះបានសម្រេចតាមការទាមទាររបស់ " ក " និងបានចូលជាស្ថាពរ ។ សន្មត " ក " មានភស្តុតាង ជាឯកសារ ( កិច្ចសន្យាខ្ចីប្រាក់ និងលិខិតប្រគល់ទទួលប្រាក់ ) ប៉ុន្តែ " ខ " មិនទទួលស្គាល់ដោយបានតវ៉ាអំពី ភាពត្រឹមត្រូវនៃឯកសារ ហើយបានស្នើសុំធ្វើកោសលវិច័យ ប៉ុន្តែតុលាការមិនបានពិចារណាអំពីភាពត្រឹមត្រូវ នៃឯកសារ តាមរយៈការស្នើសុំធ្វើកោសលវិច័យឡើយ ។ ករណីនេះ ជាស្ថានភាពតុលាការភ្លេចបញ្ចូល សេចក្ដីវិនិច្ឆ័យលើចំណុចសំខាន់ៗដែលមានឥទ្ធិពលទៅលើសាលក្រម ឬសាលដីកា មានន័យថា បើតុលាការចេញដីកាសម្រេចបង្គាប់ឱ្យធ្វើកោសលវិច័យ ហើយលទ្ធផលចេញមកភស្តុតាងជាឯកសាររបស់ " ក " ពិតជាមិនត្រឹមត្រូវ គឺលទ្ធផលនឹងផ្សេងពីអ្វីដែលតុលាការបានសម្រេច ។

28 បទបង្ហាញនៅក្នុងសិក្ខាសាលាស្ដីពីបញ្ហានានា ដែលមាននៅក្នុងរឿងក្ដីរដ្ឋប្បវេណី,១៧ មករា ២០១៨

29 មាត្រា ៣០៧ កថាខណ្ឌទី១ វាក្យខណ្ឌទី៩ ចំណុច ឈ, ក្រមនីតិវិធីរដ្ឋប្បវេណី, លេខ នស/រមក/០៧០៦/០២១, ០៦ កក្កដា ២០០៦

### ៥. ករណីដែលសាលក្រម ឬ សាលដីកាមានខ្លឹមសារផ្ទុយគ្នា[30]

ករណីដែលសាលក្រម ឬ សាលដីកាមានខ្លឹមសារខុសគ្នានេះ គឺជាករណីដែលអាជ្ញាអស់ជំនុំនៃសាលក្រម ឬ សាលដីកាដើម មានភាពផ្ទុយគ្នាទៅនឹងអាជ្ញាអស់ជំនុំនៃសាលក្រម ឬ សាលដីកាក្រោយ ។ ស្ថានភាពនេះ អាចបង្កនូវហានិភ័យយ៉ាងធ្ងន់ធ្ងរចំពោះភាគី ហេតុដូចនេះហើយ ទើបករណីនេះ ត្រូវបានរាប់បញ្ចូលថាជា មូលហេតុមួយនៃការជំនុំជម្រះសាជាថ្មី ដែលមានបញ្ញត្តក្នុងចំណុច ញ នៃមាត្រា ៣០៧ កថាខណ្ឌទី១ នៃក្រមនីតិវិធីរដ្ឋប្បវេណី។

**ញ-បើសាលក្រម ឬ សាលដីកាដែលជាកម្មវត្ថុនៃបណ្ដឹងទាមទារឱ្យជំនុំជម្រះសាជាថ្មី មានការប៉ះពាល់ដល់សាលក្រម ឬ សាលដីកាមុនដែលបានចូលជាស្ថាពរហើយ[31] ។**

ឧទាហរណ៍៖ សញ្ញាណនៃរឿងក្ដីពាក់ព័ន្ធនឹងការទាមទារឱ្យប្រគល់ប្រាក់ ដោយផ្អែកលើកិច្ចសន្យាលក់-ទិញ តែចុងចម្លើយបានអះអាង តាមរយៈកិច្ចសេចក្ដីថ្លែងការណ៍ និងការដាក់ភស្តុតាងថាខ្លួនបានសងបំណុលរួចហើយ តុលាការសម្រេចច្រានចោលការទាមទារ ដោយបាន វិនិច្ឆ័យ និងបង្ហាញនូវសេចក្ដីវិនិច្ឆ័យរបស់ខ្លួនក្នុងសំអាងហេតុបានត្រឹមត្រូវ ។ ប៉ុន្តែក្រោយមក ចុងចម្លើយបានស្លាប់ ហើយដើមចោទបានដាក់ពាក្យបណ្ដឹងដដែលម្ដងទៀត ដែលទាមទារឱ្យសន្តតិជន ជាកូនរបស់ចុងចម្លើយប្រគល់ប្រាក់ ដោយផ្អែកលើកិច្ចសន្យាលក់ទិញដដែល ដោយសន្តតិជននោះមិនបានដឹងពី អត្ថិភាពនៃសាលក្រម ឬសាលដីកាមុន និងមិនមានភស្តុតាងគ្រប់គ្រាន់ដើម្បីដាក់ជូនតុលាការ ហើយតុលាការក៏សម្រេចទទួលស្គាល់ការទាមទាររបស់ដើមចោទ ដែលបណ្ដាលឱ្យមានស្ថានភាពផ្ទុយគ្នានៃសេចក្ដីសម្រេចពីលើអង្គហេតុតែមួយ ដែលបំពានអានុភាពអាជ្ញាអស់ជំនុំនៃសេចក្ដីសម្រេចមុន ។

## កថាភាគទី៣. បុគ្គលដែលមានសិទ្ធិប្ដឹង និង អំឡុងពេល

ការធ្វើបណ្ដឹងទាមទារឱ្យជំនុំជម្រះសាជាថ្មី គឺដើម្បីកែប្រែអានុភាពនៃសាលក្រម ឬសាលដីកាដែលបានចូលជាស្ថាពរហើយ ប៉ុន្តែប្រសិនបើអនុញ្ញាតឱ្យការដាក់ពាក្យបណ្ដឹងនេះបែបណាក៏បាន ពេលណាក៏បាន នោះអាចបណ្ដាលឱ្យមានការរារាំងដល់ស្ថិរភាពនៃទំនាក់ទំនងរវាងភាគី ហេតុនេះបណ្ដឹងទាមទារឱ្យជំនុំជម្រះសាជាថ្មី បានកំណត់យ៉ាងច្បាស់អំពី បុគ្គលដែលមានសិទ្ធិក្នុងការធ្វើបណ្ដឹង (៣.១) និង អំឡុងពេល (៣.២) ។

### ១. បុគ្គលដែលមានសិទ្ធិប្ដឹង

បុគ្គលដែលមានសិទ្ធិនៅក្នុងការធ្វើបណ្ដឹងទាមទារឱ្យជំនុំជម្រះសារជាថ្មី ត្រូវតែជាបុគ្គលមានសមត្ថភាពក្នុងការធ្វើបណ្ដឹង និងសមត្ថភាពដែលអាចក្លាយជាភាគីនៅក្នុងសកម្មភាពបណ្ដឹង ដូចមាន

[30] បទបង្ហាញនៅក្នុងសិក្ខាសាលាស្ដីពីបញ្ហានានា ដែលមាននៅក្នុងរឿងក្ដីរដ្ឋប្បវេណី,១៧ មករា ២០១៨

[31] មាត្រា ៣០៧ កថាខណ្ឌទី១ វាក្យខណ្ឌទី ១០ ចំណុច ញ, ក្រមនីតិវិធីរដ្ឋប្បវេណី, លេខ នស/រមក/០៧០៦/០២១, ០៦ កក្កដា ២០០៦

កំណត់នៅក្នុងបទបញ្ញត្តិទូទៅស្តីពី " ភាគី " ដែលមានចែងក្នុងក្រមនីតិវិធីរដ្ឋប្បវេណី។ ក្នុងនោះដែរ ភាគី សំដៅដល់ដើមចោទ និង ចុងចម្លើយនៃបណ្តឹងទាមទារឱ្យជំនុំជម្រះសាជាថ្មី ហើយចំពោះករណីដែលភាគីនៃបណ្តឹងទាមទារឱ្យជំនុំជម្រះសាជាថ្មី ជាជនដទៃផ្សេងទៀតពីភាគីនៃសាលក្រម ឬ សាលដីកាដើមនោះ ចាំបាច់ត្រូវតែបញ្ជាក់ឱ្យបានច្បាស់លាស់អំពីទំនាក់ទំនង រវាងជននោះជាមួយនឹងភាគីនៃសាលក្រម ឬ សាលដីកាដើម ។

### ១.១. គោលការណ៍

ការដាក់ពាក្យបណ្តឹងទាមទារឱ្យជំនុំជម្រះសាជាថ្មី ជាគោលការណ៍ គឺជាបុគ្គលដែលទទួលរងនូវអានុភាពនៃសាលក្រម ឬសាលដីកាដែលបានចូលជាស្ថាពរ ហើយមានផលប្រយោជន៍ក្នុងការទាមទារឱ្យលុបចោលនូវសាលក្រម ឬសាលដីកានោះ(ផលប្រយោជន៍ក្នុងការធ្វើឧបាស្រ័យ)។ ក្នុងករណីសាលក្រម ឬ សាលដីកាដើមប្រានចោលការទាមទារ ដើមចោទនៃសាលក្រម ឬ សាលដីកា គឺជាដើមចោទនៃបណ្តឹងទាមទារឱ្យជំនុំជម្រះសាជាថ្មី[32] ប៉ុន្តែ ករណីសាលក្រម ឬ សាលដីកា ដើមទទួលស្គាល់ការទាមទារ នោះដើមចោទនៃសាលក្រម ឬ សាលដីកាដើម ក្លាយជាចុងចម្លើយនៃបណ្តឹងទាមទារឱ្យជំនុំជម្រះសាជាថ្មីវិញ ។

### ១.២. អញ្ញត្រកម្ម

ទោះបីជាយ៉ាងនេះក៏ដោយ ក៏មានករណីខ្លះទៀត បុគ្គលដែលដាក់ពាក្យបណ្តឹងទាមទារឱ្យជំនុំជម្រះសាជាថ្មី គឺជាតតិយជន[33] ដែលមានន័យថាជាបុគ្គលផ្សេង ពីដើមចោទ និង ចុងចម្លើយនៃសាលក្រម ឬ សាលដីកាដើម តែបុគ្គលនោះទទួលរងនូវអានុភាពពីសាលក្រម ឬ សាលដីកាដើមនោះ ដែលអាចមានជាអាទិ៍៖ តតិយជនដែលជាអ្នកចូលរួមជួយអន្តរាគមន៍[34] តតិយជនដែលទទួលបន្តនូវ សិទ្ធិ ឬ កាតព្វកិច្ចពីភាគីតាមរយៈសន្តតិកម្មជាដើម និងតតិយជនក្នុងករណីដែលភាគីធ្វើជាដើម ចោទ ឬ ចុងចម្លើយនៃបណ្តឹងជំនួសតតិយជននោះ[35] " ។ ករណីនេះ តតិយជនអាចធ្វើការទាមទារឱ្យជំនុំជម្រះសាជាថ្មី ដោយចាំបាច់លើកពីមូលហេតុណាមួយដូចមានកំណត់ក្នុងមាត្រា ៣០៧ កថាខណ្ឌ ទី១ នៃក្រមនីតិវិធីរដ្ឋប្បវេណី ។ បន្ថែមពីលើនេះ តតិយជនដែលរងអានុភាពពីសាលក្រម ឬ សាលដីកាខាងលើ ក៏នៅមានតតិយ ជនមួយប្រភេទទៀត ដែលហៅថា "តតិយជនដែលពាក់ព័ន្ធផលប្រយោជន៍" ។

អនុលោមតាមមាត្រា ៣១៨ នៃក្រមនីតិវិធីរដ្ឋប្បវេណី បណ្តឹងទាមទារឱ្យជំនុំជម្រះសាជាថ្មីដោយសតតិយជនដែលពាក់ព័ន្ធ ផលប្រយោជន៍នេះ ត្រូវបានហៅថា "បណ្តឹងទាមទារឱ្យជំនុំជម្រះសាជាថ្មីដើម្បីកុំឱ្យមានការខូចខាត ផលប្រយោជន៍" ។ បណ្តឹងប្រភេទនេះ ជាករណីពិសេសមួយនៃការទាមទារឱ្យជំនុំជម្រះ

[32] មាត្រា ៣០៧ និង ៣០៨, ក្រមនីតិវិធីរដ្ឋប្បវេណី, លេខ នស/រកម/០៧០៦/០២១, ០៦ កក្កដា ២០០៦

[33] មាត្រា ៣១៨, ក្រមនីតិវិធីរដ្ឋប្បវេណី, លេខ នស/រកម/០៧០៦/០២១, ០៦ កក្កដា ២០០៦

[34] មាត្រា ៤៦, ក្រមនីតិវិធីរដ្ឋប្បវេណី, លេខ នស/រកម/០៧០៦/០២១, ០៦ កក្កដា ២០០៦

[35] សេចក្តីពន្យល់អំពីក្រមនីតីវិធីរដ្ឋប្បវេណី ភាគ១, ២០០៨

សាជាថ្មី ដែលមិនចំណុះឱ្យមូលហេតុទាំង ១០ (ដប់) ដូចមានកំណត់ក្នុងមាត្រា ៣០៧ នៃក្រមនីតិវិធីរដ្ឋប្បវេណី នោះទេ ពោលគឺឱ្យតែលក្ខខណ្ឌបញ្ញត្តក្នុងមាត្រា ៣១៨ នៃក្រមនីតិវិធីរដ្ឋប្បវេណី ត្រូវបានបំពេញ នោះច្បាប់អនុញ្ញាតឱ្យតតិយជនធ្វើការទាមទារឱ្យជំនុំជម្រះសាជាថ្មីលើសាលក្រម ឬ សាលដីកាដែល ចូលជាស្ថាពរបានហើយ ។ ក្នុងករណីនេះ តតិយជន គឺជាដើមចោទនៃបណ្ដឹងទាមទារឱ្យជំនុំជម្រះ សាជាថ្មី ហើយដើមចោទ និងចុងចម្លើយនៃសាលក្រម ឬ សាលដីកាដើមដែលចូលជាស្ថាពរ ក្លាយ ជាសហចុងចម្លើយនៃបណ្ដឹងទាមទារឱ្យជំនុំជម្រះសាជាថ្មី ។

**២. អំឡុងពេល**

នៅក្នុងបណ្ដឹងទាមទារឱ្យជំនុំជម្រះសាជាថ្មី ក៏មិនខុសគ្នាពីបណ្ដឹងឧបាស្រ័យទូទៅផ្សេងទៀតដែរ គឺមាននូវការកម្រិតនូវអំឡុងពេល ដើម្បីរក្សាស្ថេរភាពច្បាប់ និង ទំនាក់ទំនងគតិយុត្តរវាងគូភាគី។

**២.១. គោលការណ៍**

ជាគោលការណ៍ បណ្ដឹងទាមទារឱ្យជំនុំជម្រះសាជាថ្មី ត្រូវធ្វើឡើងនៅក្នុងអំឡុងពេល ៣០ ថ្ងៃ គិតចាប់ពីថ្ងៃដែលភាគីបានដឹងអំពីមូលហេតុនៃការជំនុំជម្រះសាជាថ្មី ក្រោយពេលដែលសាលក្រម ឬ សាលដីកាចូលជាស្ថាពរ[36] ហើយអំឡុងពេលនេះ មិនអាចពន្យារបានឡើយ[37] ។

ម្យ៉ាងទៀត ភាគីពុំអាចធ្វើបណ្ដឹងទាមទារឱ្យជំនុំជម្រះសាជាថ្មីបានឡើយ ប្រសិនបើក្នុងអំឡុងពេល ៥ ឆ្នាំ បានកន្លងផុត ដោយគិតពីថ្ងៃដែលសាលក្រម ឬ សាលដីកាបានចូលជាស្ថាពរ ឬ គិតពីថ្ងៃដែលមូលហេតុនៃការជំនុំជម្រះសាជាថ្មីកើតឡើង ក្នុងករណីដែលមូលហេតុនោះកើតឡើង ក្រោយពេលសាលក្រម ឬ សាលដីកាបានចូលជាស្ថាពរ ទោះជាភាគីបានដឹង ឬ មិនបានដឹងអំពីមូលហេតុនោះក៏ដោយ[38] ។

**២.២.អញ្ញត្រកម្ម**

បណ្ដឹងទាមទារឱ្យជំនុំជម្រះសាជាថ្មី ក្នុងចំណុចនេះមិនចាំបាច់ត្រូវធ្វើក្នុងអំឡុងពេលនៃការជំនុំជម្រះសាជាថ្មីដែលបានកំណត់ដោយច្បាប់ឡើយ ប្រសិនបើមូលហេតុនៃការជំនុំជម្រះសាជាថ្មីពាក់ព័ន្ធនឹង "កង្វះសិទ្ធិតំណាង" ដោយហេតុថា បណ្ដឹងដែលមានសាលក្រម ឬសាលដីកាស្ថាពរ ត្រូវបានធ្វើឡើងនៅពេលដែលសាមីភាគី និងអ្នកតំណាងដែលច្បាប់បានកំណត់មិនបានដឹងសោះ (បណ្ដឹងដែលត្រូវបានធ្វើឡើងដោយអ្នកតំណាងដែលគ្មានសិទ្ធិ) ហើយតុលាការបានចេញសាលក្រម ឬសាលដីកា ដោយមិនធានានូវសិទ្ធិមូលដ្ឋាននៃនីតិវិធីចំពោះភាគី ដូចច្នេះការកម្រិតអំឡុងពេល សម្រាប់បណ្ដឹងទាមទារឱ្យជំនុំជម្រះសាជាថ្មី គឺផ្ទុយច្បាប់ ។ លើសពីនេះទៅទៀត នៅពេលដែល "កម្មវត្ថុនៃបណ្ដឹងទាមទារឱ្យជំនុំជម្រះសាជាថ្មីមានការប៉ះ

[36] មាត្រា ៣១១ កថាខណ្ឌទី ១ វាក្យខណ្ឌទី ១, ក្រមនីតិវិធីរដ្ឋប្បវេណី, លេខ នស/រមក/០៧០៦/០២១, ០៦ កក្កដា ២០០៦

[37] មាត្រា ៣១១ កថាខណ្ឌទី ២, ក្រមនីតិវិធីរដ្ឋប្បវេណី, លេខ នស/រមក/០៧០៦/០២១, ០៦ កក្កដា ២០០៦

[38] មាត្រា ៣១១ កថាខណ្ឌទី ៣ វាក្យខណ្ឌទី ១, ក្រមនីតិវិធីរដ្ឋប្បវេណី, លេខ នស/រមក/០៧០៦/០២១, ០៦ កក្កដា ២០០៦

ពាល់ដល់សាលក្រម ឬសាលដីកាមុនដែលបានចូលជាស្ថាពរ" ការកម្រិតអំឡុងពេលសម្រាប់បណ្ដឹងទាមទារឱ្យជំនុំជម្រះសាជាថ្មីនឹងនាំឱ្យមានភាពច្របូកច្របល់ ដោយហេតុថា បង្កើតនូវភាពមិនច្បាស់លាស់នៃទំនាក់ទំនងគតិយុត្តរបស់គូភាគីដោយសាលក្រម ឬសាលដីកាណាមួយ ។ ហេតុនេះភាគីដែលមានមូលហេតុ ដូចមានចែងនៅក្នុងមាត្រា ៣០៧ កថាខណ្ឌទី ១ វាក្យខណ្ឌទី ១ ចំណុច គ ឬ ចំណុច ញ អាចធ្វើបណ្ដឹងទាមទារឱ្យជំនុំជម្រះសាជាថ្មីបានដោយមិនពិចារណាទៅលើអំឡុងពេលឡើយ[39] ។

## កថាភាគទី៤. ភាពបង្គ្រប់កិច្ចនៃការជំនុំជម្រះសាជាថ្មី

ទោះបីជាមានអង្គហេតុដែលត្រូវនឹងមូលហេតុនៃការជំនុំជម្រះសាជាថ្មីក៏ដោយ ក៏ភាគីមិនអាចធ្វើការទាមទារឱ្យធ្វើការជំនុំជម្រះសាជាថ្មីបាននោះទេ ប្រសិនបើមានករណីណាមួយបានកើតឡើងដូចខាងក្រោម[40]៖

- ករណីដែលភាគីបានធ្វើការអះអាងអំពីមូលហេតុនោះ នៅពេលធ្វើបណ្ដឹងឧបាស្រ័យទៅតុលាការជាន់ខ្ពស់ (១)
- ករណីដែលភាគីបានដឹងអំពីមូលហេតុនេះហើយ តែមិនបានធ្វើការអះអាង (២)

ករណីទាំងពីរខាងលើនេះ គឺជាការបំពេញបន្ថែម ឬ ការបង្គ្រប់កិច្ច នៃបណ្ដឹងទាមទារឱ្យជំនុំជម្រះសាជាថ្មី ដែលជាការធានានូវ គោលការណ៍ សុច្ចរិតភាព និង ភាពស្មោះត្រង់ ។ អំពីអង្គហេតុដែលត្រូវជាមូលហេតុនៃការជំនុំជម្រះសាជាថ្មី ជាបឋមត្រូវធ្វើការអះអាងនៅក្នុងបណ្ដឹងឧបាស្រ័យទៅតុលាការជាន់ខ្ពស់ តាមរយៈការដាក់ពាក្យបណ្ដឹងឧបាស្រ័យធម្មតាជាមុនសិន ។ ហេតុនេះហើយ មានតែករណីដែលមិនអាចអះអាងបាននៅក្នុងបណ្ដឹងឧបាស្រ័យទៅតុលាការជាន់ខ្ពស់ប៉ុណ្ណោះទេ ដែលអាចយកនូវអង្គហេតុនោះមកធ្វើការអះអាងបានតាមបណ្ដឹងទាមទារសុំឱ្យជំនុំជម្រះសាជាថ្មី[41] ។

### ១.ករណីដែលភាគីបានធ្វើការអះអាង

ករណីដែលភាគីបានធ្វើការអះអាងអំពីមូលហេតុនោះ នៅពេលធ្វើបណ្ដឹងឧបាស្រ័យទៅ តុលាការជាន់ខ្ពស់ ដែលមានបញ្ញត្តក្នុងមាត្រា ៣០៧ កថាខណ្ឌទី១ វាក្យខណ្ឌទី២ នៃក្រមនីតិវិធី រដ្ឋប្បវេណី សំដៅដល់ ករណីដែលភាគីបានដឹងអំពីអង្គហេតុណាមួយ ដែលត្រូវនឹងមូលហេតុនៃការជំនុំជម្រះសាជាថ្មី ហើយបានលើកយកអង្គហេតុនោះមកធ្វើការអះអាង នៅក្នុងការធ្វើបណ្ដឹងឧបាស្រ័យទៅតុលាការជាន់ខ្ពស់ ហេតុនេះ ភាគីមិនអាចលើកយកនូវអង្គហេតុដដែលនោះ មកធ្វើជាមូលដ្ឋានក្នុងការទាមទារឱ្យជំនុំជម្រះសាជាថ្មីទៅលើសាលក្រម ឬ សាលដីកាដែលបានចូលជាស្ថាពរនោះទេ។ ដោយសារតែ តុលាការជាន់ខ្ពស់បានធ្វើ

---

[39] មាត្រា ៣១១ កថាខណ្ឌទី ១ វាក្យខណ្ឌទី ២, ក្រមនីតិវិធីរដ្ឋប្បវេណី, លេខ នស/រកម/០៧០៦/០២១, ០៦ កក្កដា ២០០៦

[40] មាត្រា ៣០៧ កថាខណ្ឌទី ១ វាក្យខណ្ឌទី ២, ក្រមនីតិវិធីរដ្ឋប្បវេណី, លេខ នស/រកម/០៧០៦/០២១, ០៦ កក្កដា ២០០៦

[41] សេចក្ដីកំណត់ចំពោះមាត្រានីមួយៗនៃក្រមនីតិវិធីរដ្ឋប្បវេណី, ២០០៧

ការវិនិច្ឆ័យលើអង្គហេតុនោះរួចរាល់ហើយ ដូច្នេះការដែលភាគីលើកយកបញ្ហាដដែល មកឱ្យតុលាការធ្វើការជំនុំជម្រះសាជាថ្មី ឬ ការពិចារណាសាជាថ្មីម្តងទៀត គឺជាការមិនសមរម្យឡើយ ។

ឧទាហរណ៍ ៖ ដើមចោទ "ក" ប្តឹងចុងចម្លើយ "ខ" ទាមទារឱ្យបង់ប្រាក់ចំនួន ១០,០០០ដុល្លា ដោយផ្អែកលើកិច្ចសន្យាលក់-ទិញ ចុះថ្ងៃទី០១.០១.២០២៣។ ចៅក្រម "គ" ជាចៅក្រមដែលធ្លាប់ធ្វើជាអ្នកតំណាងដោយអាណត្តិឱ្យ "ខ" បានចូលរួមនៅក្នុងចេញសាលក្រម ហើយបានច្រានចោលការទាមទាររបស់ "ក"។ "ក" បានប្តឹងឧទ្ធរណ៍ចំពោះខ្លឹមសារនៃសេចក្តីសម្រេច នេះ ហើយក៏បានលើកឡើងអំពីករណីចៅក្រម "គ" ជាចៅក្រមដែលធ្លាប់ធ្វើជាអ្នកតំណាងដោយអាណត្តិឱ្យ "ខ" ផងដែរ ប៉ុន្តែតុលាការនៃបណ្តឹងឧទ្ធរណ៍ បានច្រានចោល ការទាមទារនេះក្នុងសាលដីកា ក្នុងករណីនេះ "ក" មិនអាចធ្វើការជំនុំជម្រះសាជាថ្មី ដោយផ្អែកលើមូលហេតុខាងលើបានទេ ។ ត្រង់ចំណុចនេះ ចង់បញ្ជាក់ពីបញ្ហានៃការតវ៉ាដដែលៗនឹងមិនអាចត្រូវបានទទួលស្គាល់ថាសមរម្យសម្រាប់ការពិចារណាជាថ្មីឡើយ ហើយធ្វើឱ្យអស្ថិរភាពក្នុងការដឹកនាំនីតិវិធីថែមទៀតផង។ ផ្ទុយទៅវិញ ប្រសិនបើ ការដឹកនាំនីតិវិធីមានវិការៈ ឬមូលដ្ឋាននៃការសម្រេចសេចក្តីមានវិការៈ គឺមានភាពចាំបាច់ ក្នុងការ វិនិច្ឆ័យជាថ្មី ដោយកម្រិតត្រឹមមូលហេតុជាក់លាក់ដែលច្បាប់ទទួលស្គាល់ ។

**២.ករណីដែលភាគីមិនបានធ្វើការអះអាង**

ករណីដែលភាគីបានដឹងអំពីអង្គហេតុណាមួយ ដែលអាចនឹងក្លាយជាមូលហេតុនៃការទាមទារឱ្យជំនុំជម្រះសាជាថ្មីប៉ុន្តែ ខ្លួនពុំបានធ្វើការអះអាងភ្លាមៗ អំពីហេតុនោះនៅក្នុងដំណើរការនីតិវិធីណាមួយរបស់តុលាការ ដូចជានៅនីតិវិធីត្រៀមសម្រាប់ការទាញហេតុផល ឬ នីតិវិធីទាញហេតុផលដោយផ្ទាល់មាត់ជាអាទិ៍ ដោយរង់ចាំរហូតដល់ពេលសាលក្រម ឬ សាលដីកាចូលជាស្ថាពរ ដើម្បីយកហេតុនោះមកធ្វើជាមូលហេតុក្នុងការទាមទារឱ្យជំនុំជម្រះសាជាថ្មី ។ មូលហេតុដែលភាគីមិនបានធ្វើការអះអាងភ្លាមៗនេះ គឺក្នុងគោលបំណងប្រើប្រាស់ហេតុផលនោះ នៅពេលដែលខ្លួនបាត់បង់ផលប្រយោជន៍ តាមរយៈសាលក្រម ឬ សាលដីកាដែលបានចូលជាស្ថាពរ ។ ករណីបែបនេះ ច្បាប់មិនអនុញ្ញាតឱ្យភាគីធ្វើការទាមទារឱ្យជំនុំជម្រះសាជាថ្មីឡើយ ព្រោះភាគីមិនបានគោរពនូវភាពបង្គ្រប់កិច្ចនៃការទាមទារឱ្យជំនុំជម្រះសាជាថ្មី ដូចមានកំណត់ក្នុងមាត្រា ៣០៧ កថាខណ្ឌទី១ វាក្យខណ្ឌទី២ នៃក្រមនីតិវិធីរដ្ឋប្បវេណី នោះទេ។

ឧទាហរណ៍ ៖ ដើមចោទ "ក" ប្តឹងចុងចម្លើយ "ខ" ទាមទារឱ្យបង់ប្រាក់ចំនួន ១០,០០០ដុល្លា ដោយផ្អែកលើកិច្ចសន្យាលក់-ទិញ ចុះថ្ងៃទី០១.០១.២០២៤។ ចៅក្រម "គ" ជាចៅក្រមដែលធ្លាប់ធ្វើជាអ្នកតំណាងដោយអាណត្តិឱ្យ "ខ" បានចូលរួមនៅក្នុងចេញសាលក្រម ហើយបានច្រានចោលការទាមទាររបស់ "ក"។ "ក" បានដឹងអំពីបញ្ហានេះ ប៉ុន្តែមិនបានធ្វើការលើកឡើងនៅក្នុងនីតិវិធីបណ្តឹងនៅតុលាការជាន់ខ្ពស់ទេ ដោយរង់ចាំរហូតដល់ពេលសាលក្រម ឬ សាលដីកាចូលជាស្ថាពរ ។ ក្នុងករណីនេះ "ក" មិនអាចលើកយកនូវអង្គហេតុដដែលនោះ មកធ្វើជាមូលដ្ឋានក្នុងការទាមទារឱ្យជំនុំជម្រះសាជាថ្មី បានឡើយ។

## ផ្នែកទី២. លក្ខខណ្ឌទម្រង់

ពាក្យបណ្តឹងទាមទារឱ្យជំនុំជម្រះសាជាថ្មី ចាំបាច់ត្រូវគោរពតាមលក្ខខណ្ឌទម្រង់ ដែលតម្រូវឱ្យភាគី នៃបណ្តឹងអនុវត្តតាម ដោយបន្ថែមពីលើលក្ខខណ្ឌគ្រឹះ ដូចបានរៀបរាប់នៅក្នុងផ្នែកទី១ខាងលើ ។ ហេតុដូចនេះ ភាគីដើមចោទនៃបណ្តឹងទាមទារឱ្យជំនុំជម្រះសាជាថ្មី ចាំបាច់ត្រូវយល់ដឹង អំពីរបៀបនៃការសរសេរពាក្យបណ្តឹង (កថាភាគទី១) និង ការដាក់ពាក្យបណ្តឹង (កថាភាគទី២) ដែលមានលក្ខណៈត្រឹមត្រូវតាមបញ្ញត្តិច្បាប់ ទើបត្រូវបានតុលាការទទួលស្គាល់ ។

### កថាភាគទី១. ការសរសេរពាក្យបណ្តឹង

នៅក្នុងពាក្យបណ្តឹងទាមទារឱ្យជំនុំជម្រះសាជាថ្មី ច្បាប់បានបញ្ញត្តិយ៉ាងច្បាស់លាស់ អំពីចំណុចសំខាន់ៗ ដែលភាគីដើមចោទនៃបណ្តឹង ចាំបាច់ត្រូវធ្វើការសរសេរ (១.១) និង ឯកសារដែលត្រូវភ្ជាប់មកជាមួយ (១.២) ហើយចំពោះករណីដែលមានភាពខ្វះចន្លោះ ក្នុងការសរសេរចំណុចចាំបាច់ ជាអាទិ៍ តុលាការនឹងបង្គាប់ឱ្យកែតម្រូវលើចំណុចខ្វះខាតនោះ យោងទៅតាមបទប្បញ្ញត្តិពាក់ព័ន្ធនឹងពាក្យបណ្តឹងធម្មតា ហើយប្រសិនបើភាគីមិនបានគោរពអនុវត្តតាមនោះទេ ពាក្យបណ្តឹងនោះនឹងត្រូវក្លាយជាកម្មវត្ថុនៃការលើកចោលដោយដីកាសម្រេច ដែលជាហេតុនាំឱ្យមិនមាននូវការជំនុំជម្រះសាជាថ្មីលើសាលក្រម ឬ សាលដីកាដែលបានចូលជាស្ថាពរ ហើយបណ្តាលឱ្យប៉ះពាល់ដល់ផលប្រយោជន៍របស់ដើមចោទថែមទៀតផង ។

#### ១.ចំណុចដែលត្រូវសរសេរ[42]

ចំណុចសំខាន់ៗ ដែលតម្រូវឱ្យភាគីធ្វើការសរសេរនៅក្នុងពាក្យបណ្តឹងទាមទារឱ្យជំនុំជម្រះសាជាថ្មី ស្របតាមច្បាប់កំណត់មានដូចតទៅ៖

ក. ឈ្មោះ ឬ នាមករណ៍ និងអាសយដ្ឋានរបស់ភាគី ហើយនិង ឈ្មោះ ឬ នាមករណ៍ និងអាស័យដ្ឋានរបស់អ្នកតំណាងដែលច្បាប់បានកំណត់ ។

ខ. សញ្ញាណនៃ សាលក្រម ឬ សាលដីកា ដែលជាកម្មវត្ថុនៃបណ្តឹងទាមទារឱ្យជំនុំជម្រះសាជាថ្មី និង សេចក្តីទាមទារ ឱ្យជំនុំជម្រះសាជាថ្មីចំពោះសាលក្រម ឬ សាលដីកានោះ ។

គ. អង្គហេតុដែលត្រូវនឹងមូលហេតុនៃការជំនុំជម្រះសាជាថ្មី ។

ឧទាហរណ៍៖

- ដើមចោទ៖ ឈ្មោះ ខ-អាស អាសយដ្ឋានស្ថិតនៅផ្ទះលេខ០១ ផ្លូវលេខ០២ ក្រុម៣៖ ភូមិ០៤ សង្កាត់០៥ ខណ្ឌ០៦ រាជធានីភ្នំពេញ។ ចុងចម្លើយ៖ ឈ្មោះ "ក" អាសយដ្ឋានស្ថិតនៅ អាសយដ្ឋានស្ថិតនៅផ្ទះលេខ១១ ផ្លូវលេខ២២ ក្រុម៣៣ ភូមិ៤៤ សង្កាត់៥៥ ខណ្ឌ៦៦ រាជធានីភ្នំពេញ។

[42] មាត្រា ៣១២ ក្រមនីតិវិធីរដ្ឋប្បវេណី, លេខ នស/រកម/០៧០៦/០២១, ០៦ កក្កដា ២០០៦

❖ សាលក្រមដែលជាកម្មវត្ថុនៃការជំនុំជម្រះសាជាថ្មី៖ សាលក្រមរដ្ឋប្បវេណីលេខ.........ចុះថ្ងៃទី....ខែ.......ឆ្នាំ.......របស់សាលាដំបូងរាជធានីភ្នំពេញ។

❖ សេចក្តីទាមទារឱ្យជំនុំជម្រះសាជាថ្មី៖

– ទី១ ចាប់ផ្តើមជំនុំជម្រះសាជាថ្មីចំពោះសំណុំរឿងរដ្ឋប្បវេណីលេខ.........ចុះថ្ងៃទី....ខែ.......ឆ្នាំ.......របស់សាលាដំបូងរាជធានីភ្នំពេញ

– ទី២ លុបចោលសាលក្រម រដ្ឋប្បវេណីលេខ......... ចុះថ្ងៃទី....ខែ.......ឆ្នាំ.......របស់សាលាដំបូងរាជធានីភ្នំពេញ

– ទី៣ បង្គាប់ឱ្យ ចុងចម្លើយ............មកឱ្យដើមចោទ និង

– ទី៤ ប្រាក់ប្រដាប់ បាក់ប្រដាប់ក្តី ជាបន្ទុករបស់ចុងចម្លើយ។

ក្នុងករណីដែល ភាគីនៃបណ្តឹងទាមទារឱ្យជំនុំជម្រះសាជាថ្មី ជាជនណាផ្សេងពីភាគីនៃសាលក្រមដើម ឬ សាលដីកាដើម នោះចាំបាច់ ត្រូវសរសេរឱ្យបានច្បាស់អំពីទំនាក់ទំនងរវាងជននោះជាមួយនឹងភាគីនៃសាលក្រមដើម ឬ សាលដីកាដើមនោះ ។ ឧទាហរណ៍:សន្តតិជនរបស់ភាគីនៃសាលក្រមឬសាលដីកាជាដើម

**២. ឯកសារភ្ជាប់** [43]

ឯកសារដែលភាគីចាំបាច់ ត្រូវភ្ជាប់មកជាមួយនឹងពាក្យបណ្តឹងទាមទារឱ្យជំនុំជម្រះសាជាថ្មី នៅពេលដាក់ពាក្យបណ្តឹងជូនទៅ តុលាការមានសមត្ថកិច្ច គឺ ឯកសារចម្លងនៃសាលក្រម ឬ សាលដីកាស្ថាពរដែលជា កម្មវត្ថុនៃបណ្តឹងទាមទារឱ្យជំនុំជម្រះសាជាថ្មី ។

**កថាភាគទី២. ការដាក់ពាក្យបណ្តឹង**

ជាគោលការណ៍ ពាក្យបណ្តឹងទាមទារឱ្យជំនុំជម្រះសាជាថ្មីនោះ ត្រូវយកទៅដាក់នៅលេខាធិការដ្ឋាននៃតុលាការដែលមានសមត្ថកិច្ច (២.១) ហើយជាមួយគ្នានេះ ភាគីនឹងត្រូវតម្រូវឱ្យធ្វើការបង់ ពន្ធដាក់ពាក្យសុំ (២.២) តាមការកំណត់របស់ច្បាប់ ទើបអាចឱ្យបណ្តឹងទាមទារឱ្យជំនុំជម្រះសាជាថ្មីនោះ បង្កើតបាននូវអានុភាពគតិយុត្តបាន ។

**១.តុលាការនៃបណ្តឹងទាមទារជំនុំជម្រះសាជាថ្មី**[44]

តុលាការ ដែលមានសមត្ថកិច្ចផ្តាច់មុខ ក្នុងការទទួល និងធ្វើចំណាត់ការលើបណ្តឹងទាម ទារឱ្យជំនុំជម្រះសាជាថ្មី គឺតុលាការដែលបានចេញសាលក្រម ឬ សាដីកាដែលជាកម្មវត្ថុនៃការជមនុំជម្រះសាជាថ្មីនោះ។

[43] មាត្រា ៣១២ កថាខណ្ឌទី ២, ក្រមនីតិវិធីរដ្ឋប្បវេណី, លេខ នស/រកម/០៧០៦/០២១, ០៦ កក្កដា ២០០៦

[44] មាត្រា ៣០៩ កថាខណ្ឌទី ១, ក្រមនីតិវិធីរដ្ឋប្បវេណី, លេខ នស/រកម/០៧០៦/០២១, ០៦ កក្កដា ២០០៦

ជាគោលការណ៍ ក្នុងករណីដែលមិនមានបណ្តឹងឧបាស្រ័យចំពោះសាលក្រមនៃតុលាការ ជាន់ទាប ដែលបានចូលជាស្ថាពរដែលជាកម្មវត្ថុនៃបណ្តឹងទាមទារឱ្យជំនុំជម្រះសាជាថ្មី តុលាការតែមួយគត់ដែលមាន សមត្ថកិច្ច គឺតុលាជាន់ទាបដែលសំដៅដល់សាលាដំបូងរាជធានី-ខេត្ត ។ ដោយឡែក បណ្តឹងទាមទារឱ្យជំនុំ ជម្រះសាជាថ្មីចំពោះសាលក្រម ឬ សាលដីកាអំពីរឿងតែ មួយដែលត្រូវបានចេញដោយតុលាការច្រើនដែល មានថ្នាក់ខុសគ្នា តុលាការដែលមានសមត្ថកិច្ចរួម បញ្ចូលសាលក្រម ឬ សាលដីកាទាំងនោះ គឺតុលាការជាន់ ខ្ពស់ ដែលសំដៅដល់សាលាឧទ្ធរណ៍ ឬ តុលាការកំពូល ។

ក្នុងករណីដែលមានការប្តឹងឧទ្ធរណ៍ចំពោះសាលក្រមនៃសាលាដំបូង ហើយតុលាការនៃបណ្តឹង ឧទ្ធរណ៍ បានធ្វើការវិនិច្ឆ័យលើអង្គសេចក្តី និងបានចេញសាលដីកាចុងក្រោយ ដែលបាន ចូលជាស្ថាពរ ហើយប្រសិនបើ មានការទាមទារឱ្យជំនុំជម្រះសាជាថ្មីចំពោះសាលក្រម និងសាល ដីកាទាំងពីរនោះសាល ដីកានៃសាលាឧទ្ធរណ៍ ដែលជាសេចក្តីសម្រេចរបស់តុលាការ ដែលមានថ្នាក់ខ្ពស់ជាង ត្រូវក្លាយជាកម្មវត្ថុនៃ បណ្តឹងទាមទារឱ្យជំនុំជម្រះសាជាថ្មី ហើយតុលាការដែលមាន សមត្ថកិច្ច គឺសាលាឧទ្ធរណ៍ ។

ប៉ុន្តែ បន្ថែមពីលើករណីខាងលើ ប្រសិនបើមានការប្តឹងសាទុក្ខ ចំពោះសាលដីកានៃសាលាឧទ្ធរណ៍ ហើយតុលាការកំពូល បានចេញសាលដីកាចុងក្រោយដែល ចូលជាស្ថាពរ នោះសាលដីកានៃតុលាការ កំពូល ដែលជារសេចក្តីសម្រេចរបស់តុលាការដែលមាន ថ្នាក់ខ្ពស់ជាងគេ ត្រូវក្លាយជាកម្មវត្ថុនៃបណ្តឹង ទាមទារឱ្យជំនុំជម្រះសាជាថ្មី ហើយតុលាការដែល មានសមត្ថកិច្ច គឺតុលាការកំពូល ។ មូលហេតុនៃការផ្តល់ សមត្ថកិច្ចផ្តាច់មុខនេះជូនដល់តុលាការ ជាន់ខ្ពស់ គឺដើម្បីបញ្ចៀសនូវភាពច្របូកច្របល់ពាក់ព័ន្ធនឹងបញ្ហា អាជ្ញាអស់ជំនុំនៃអង្គហេតុ ដែល អាចកើតមានឡើង ដោយការជំនុំជម្រះច្រើនដង ដោយតុលាការថ្នាក់ខុសគ្នា លើរឿងតែមួយ ។ ដូច្នេះ តុលាការដែលមានថ្នាក់ខ្ពស់ គឺជាតុលាការដែលមានសមត្ថកិច្ចក្នុងការដោះស្រាយ បញ្ហាទាំងនេះ ។

ចៅក្រម ដែលបានចេញសាលក្រម ឬ សាលដីកា ដែលជាកម្មវត្ថុនៃបណ្តឹងទាមទារឱ្យជំនុំ ជម្រះ សាជាថ្មី ត្រូវបានហាមឃាត់មិនឱ្យចូលរួមក្នុងការវិនិច្ឆ័យ និងចេញសេចក្តីសម្រេចណាមួយ លើបណ្តឹង ទាមទារឱ្យជំនុំជម្រះសាជាថ្មីបានទេ " ដើម្បីជៀសវាងនូវស្ថានភាពបុរេវិនិច្ឆ័យ ។

**២. ពន្ធដាក់ពាក្យសុំ**[45]

ពន្ធដាក់ពាក្យសុំនេះ គឺជាប្រាក់ពន្ធដែលភាគីត្រូវបង់នៅពេលដាក់ពាក្យបណ្តឹងទៅតុលាការ ដែល មានសមត្ថកិច្ច ដើម្បីឱ្យមានចំណាត់ការរបស់តុលាការ លើបណ្តឹងរបស់ខ្លួន ដោយត្រូវអនុវត្ត តាមបញ្ញត្តិ ច្បាប់ ។ អនុលោមតាមមាត្រា ៦១ កថាខណ្ឌទី៤ នៃក្រមនីតិវិធីរដ្ឋប្បវេណី ដើមបណ្តឹងនៃបណ្តឹងទាមទារឱ្យ ជំនុំជម្រះសាជាថ្មី ត្រូវបង់ពន្ធដាក់ពាក្យសុំចំពោះ បណ្តឹងទាមទារឱ្យជំនុំជម្រះសាជាថ្មី នេះនូវចំនួនទឹកប្រាក់

[45] មាត្រា ៦១ កថាខណ្ឌទី ៤ក, ក្រមនីតិវិធីរដ្ឋប្បវេណី, លេខ នស/រកម/០៧០៦/០២១, ០៦ កក្កដា ២០០៦

១០.០០០៛ (មួយម៉ឺនរៀល) ទៅតុលាការ ដើម្បីឱ្យមានចំណាត់ការលើពាក្យ បណ្ដឹងទាមទារឱ្យជំនុំជម្រះសាជាថ្មីនេះ ។

**៣. ការដកពាក្យបណ្ដឹងទាមទារឱ្យជំនុំជម្រះសាជាថ្មី**

បណ្ដឹងទាមទារឱ្យជំនុំជម្រះសាជាថ្មី អាចត្រូវបានដក នៅពេលណាក៏បាន រហូតដល់ពេលសាលក្រម ឬសាលដីកាចុងក្រោយរបស់តុលាការនៃបណ្ដឹងទាមទារឱ្យជំនុំជម្រះសាជាថ្មីត្រូវបានប្រកាស។ ការដកបណ្ដឹងទាមទារឱ្យជំនុំជម្រះសាជាថ្មី គឺជាការដកចេញនូវបណ្ដឹងឧបាស្រ័យពិសេសចំពោះសេចក្ដីសម្រេចដើម ដែលបានចូលជាស្ថាពរ (កម្មវត្ថុនៃការជំនុំជម្រះសាជាថ្មី) ហើយអានុភាពនៃការដកបណ្ដឹងទាមទារឱ្យជំនុំជម្រះសាជាថ្មី នាំឱ្យនីតិវិធីនៃការជំនុំជម្រះសាជាថ្មីត្រូវបានបញ្ចប់ និងចាត់ទុកថាគ្មានបណ្ដឹងទាមទារឱ្យជំនុំជម្រះសាជាថ្មីតាំងពីដើម ហើយសេចក្ដីសម្រេចដើមដែលបានចូលជាស្ថាពរត្រូវបានបន្តអានុភាពនៃការអនុវត្ត។

ឧទាហរណ៍៖ ដើមចោទនៃបណ្ដឹងទាមទារឱ្យជំនុំជម្រះសាជាថ្មី បានដាក់បណ្ដឹងនេះ នៅថ្ងៃទី០១ ខែមីនា ឆ្នាំ២០២៣ ប្រឆាំងនឹងសាលក្រមស្ថាពររដ្ឋប្បវេណីលេខ ០១ "ឆ" ចុះថ្ងៃទី០១ ខែកុម្ភៈឆ្នាំ២០២៣ ។ តុលាការនៃបណ្ដឹងនេះបានទទួលចាត់ការ និង បានកំណត់កាលបរិច្ឆេទទាញហេតុផល នៅថ្ងៃទី២០ ខែមិថុនា ឆ្នាំ២០២៣ ប៉ុន្តែនៅថ្ងៃទី១០ ខែមិថុនា ឆ្នាំ២០២៣ ដើមចោទបានដកពាក្យបណ្ដឹងនេះ ហេតុនេះ សាលក្រមរបស់សាលាដំបូងដែលចូលជាស្ថាពរត្រូវចាត់ទុកថាបន្តអនុវត្តដដែល បើមានពាក្យសុំ ផ្អាកការអនុវត្ត ជាអាទិ៍ ។

ការដកបណ្ដឹងទាមទារឱ្យជំនុំជម្រះសាជាថ្មីដោយដើមចោទ មិនត្រូវការការយល់ព្រមពីចុងចម្លើយនោះទេ ដោយមូលហេតុចុងចម្លើយមិនត្រូវបានទទួលស្គាល់ថាខូចខាតនូវផលប្រយោជន៍ ដោយសារការដកបណ្ដឹងទាមទារឱ្យជំនុំជម្រះសាជាថ្មីឡើយ។

# ជំពូកទី៣

# ចំណាត់ការលើបណ្តឹងតាមការជំនុំជម្រះសាជាថ្មី

# ជំពូកទី៣

# ចំណាត់ការលើបណ្តឹងទាមទារជំនុំជម្រះសាជាថ្មី

ចំណាត់ការរបស់តុលាការលើបណ្តឹងទាមទារឱ្យជំនុំជម្រះសាជាថ្មី សំដៅទៅលើការវិនិច្ឆ័យ និង សម្រេចសេចក្តីរបស់តុលាការ ចំពោះបណ្តឹងទាមទារឱ្យជំនុំជម្រះសាជាថ្មីនោះ ។ នៅពេលដែលបណ្តឹង ទាមទារឱ្យជំនុំជម្រះសាជាថ្មី ត្រូវបានបង្កើតអានុភាព តុលាការត្រូវធ្វើការចាប់ផ្តើមនីតិវិធីលើបណ្តឹង(ផ្នែកទី១) អោយបានឆាប់រហ័សដោយគ្មានការយឺតយ៉ាវ ។ ដំណាក់កាលនៃការជំនុំជម្រះសាជាថ្មី អាចធ្វើឡើងតាមការ អនុវត្តតាមនីតិវិធីធំៗ ចំនួនពីរបន្តបន្ទាប់គ្នាគឺ តុលាការត្រូវធ្វើការវិនិច្ឆ័យទៅលើភាពត្រឹមត្រូវនៃបណ្តឹង (ផ្នែកទី២) ប្រសិនបើពាក្យបណ្តឹងទាមទារឱ្យជំនុំជម្រះសាជាថ្មី មាននូវលក្ខណៈត្រឹមត្រូវ និងស្របទៅតាម លក្ខខណ្ឌ ដែលច្បាប់កំណត់អស់ហើយ តុលាការត្រូវបន្តនីតិវិធីលើការជំនុំជម្រះលើអង្គសេចក្តី (ផ្នែកទី៣) ។

## ផ្នែកទី១. នីតិវិធីបណ្តឹងនៃការជំនុំជម្រះសាជាថ្មី

បទប្បញ្ញត្តិនៃនីតិវិធីបណ្តឹងតាមលំដាប់ថ្នាក់នៃការជំនុំជម្រះនីមួយៗ ត្រូវយកមកអនុវត្តចំពោះ បណ្តឹងទាមទារឱ្យជំនុំជម្រះសាជាថ្មី លើកលែងតែបញ្ញត្តិនោះផ្ទុយនឹងលក្ខណៈនៃបណ្តឹងទាមទារឱ្យជំនុំ ជម្រះសាជាថ្មី[46]។

ស្ថានភាពនេះ សំដៅការជំនុំជម្រះសាជាថ្មីលើសាលក្រមរបស់តុលាការនៃការជំនុំជម្រះលើកទី១ (សាលាដំបូង) គឺបញ្ញត្តិនីតិវិធីបណ្តឹងនៃការជំនុំជម្រះលើកទី១ ត្រូវយកមកអនុវត្ត និងប្រសិនបើមានការជំនុំ ជម្រះសាជាថ្មីលើសាលដីការបស់តុលាការនៃការជំនុំជម្រះលើកទី២ (សាលាឧទ្ធរណ៍) គឺបញ្ញត្តិនីតិវិធី បណ្តឹងនៃការជំនុំជម្រះលើកទី២ ត្រូវយកមកអនុវត្ត ហើយ បើមានការជំនុំជម្រះសាជាថ្មីលើសាលដីការបស់ តុលាការនៃការជំនុំជម្រះលើកចុងក្រោយ (តុលាការកំពូល) គឺបញ្ញត្តិនីតិវិធីនៃការជំនុំជម្រះលើកចុងក្រោយ ត្រូវយកមកអនុវត្ត។

ចំពោះពាក្យ "លើកលែងតែបញ្ញត្តិនោះផ្ទុយនឹងលក្ខណៈនៃបណ្តឹងទាមទារឱ្យជំនុំជម្រះសាជាថ្មី សំដៅ នីតិវិធីជំនុំជម្រះសាជាថ្មី គឺមាន ០២ (ពីរ) ដំណាក់កាល គឺដំណាក់កាលពិនិត្យ មូលហេតុនៃការ ជំនុំ ជម្រះសាជាថ្មី និងវិនិច្ឆ័យអង្គសេចក្តី ហេតុនេះទោះបីបណ្តឹងទាមទារឱ្យជំនុំជម្រះសាជាថ្មីស្ថិតក្រោមចំណាត់ ការរបស់សាលាដំបូង ឬសាលាឧទ្ធរណ៍ ឬតុលាការកំពូល ក៏ដោយ ក៏ត្រូវធ្វើតាមបែបបទនេះផងដែរ។ មួយ វិញទៀត ទោះបីតុលាការកំពូលជាតុលាការ អង្គច្បាប់ក៏ដោយ ក៏ករណីជំនុំជម្រះសាជាថ្មី ត្រូវពិនិត្យ និង វិនិច្ឆ័យអង្គហេតុដែរ គឺអង្គហេតុនៃមូលហេតុជំនុំជម្រះសាជាថ្មី ។

ឧទាហរណ៍ ៖ "ក" ជាដើមចោទ ចំណែក "ខ" ជាចុងចម្លើយ សាលាដំបូងបានចេញសាលក្រម បង្គាប់ឱ្យ "ខ" បង់ប្រាក់ ហើយសាលក្រមរបស់សាលាដំបូងនេះបានចូលជាស្ថាពរ ករណីនេះបើមានបណ្តឹង ទាមទារឱ្យជំនុំជម្រះសាជាថ្មី សាលាដំបូងនឹងក្លាយជាតុលាការនៃបណ្តឹងទាមទារឱ្យជំនុំជម្រះសាជាថ្មី និង

[46] មាត្រា៣១០ក, ក្រមនីតិវិធីរដ្ឋប្បវេណី, លេខ នស/រកម/០៧០៦/០២១, ០៦ កក្កដា ២០០៦

ប្រសិនបើសាលាដំបូងយល់ថាមានមូលហេតុជំនុំជម្រះសាជាថ្មី សាលាដំបូងនឹងចេញដីកាសម្រេចចាប់ផ្ដើមជំនុំជម្រះសាជាថ្មី និងនៅពេលដីកាសម្រេចនេះបានចូលជាស្ថាពរ សាលាដំបូងនឹងបន្តនីតិវិធីដូចបណ្ដឹងធម្មតា មានន័យថា គឺកំណត់កាលបរិច្ឆេទនៃនីតិវិធីត្រៀមសម្រាប់ការទាញហេតុផល បន្ទាប់មករៀបចំ ការអះអាង រៀបចំចំណុចវិវាទ រៀបចំភស្តុតាងពាក់ព័ន្ធនឹងចំណុចវិវាទ បញ្ចប់នីតិវិធីត្រៀម បង្គាប់ឱ្យដាក់ ភស្តុ-តាង កំណត់កាលបរិច្ឆេទទាញហេតុផលដោយផ្ទាល់មាត់ និងប្រកាសសាលក្រម ជាអាទិ៍។

ឧទាហរណ៍៖ "ក" ជាដើមចោទ ចំណែក "ខ" ជាចុងចម្លើយ សាលាដំបូងបានចេញសាលក្រមបង្គាប់ ឱ្យ "ខ" បង់ប្រាក់ ហើយសាលក្រមរបស់សាលាដំបូងនេះត្រូវបានប្ដឹងឧទ្ធរណ៍ សាលាឧទ្ធរណ៍បានចេញ សាលដីកាច្រានចោលបណ្ដឹងឧទ្ធរណ៍ និងសាលដីកានេះបានចូលជាស្ថាពរ ករណីនេះ បើមានបណ្ដឹងទាមទារឱ្យជំនុំជម្រះសាជាថ្មី សាលាឧទ្ធរណ៍នឹងក្លាយជាតុលាការនៃបណ្ដឹងទាមទារឱ្យជំនុំជម្រះសាជាថ្មី ប្រសិនបើសាលាឧទ្ធរណ៍យល់ថាមានមូលហេតុជំនុំជម្រះសាជាថ្មី សាលាឧទ្ធរណ៍នឹងចេញដីកាសម្រេចចាប់ផ្ដើមជំនុំជម្រះសាជាថ្មី និងនៅពេលដីកាសម្រេចនេះបានចូលជាស្ថាពរ សាលាឧទ្ធរណ៍នឹងបន្តនីតិវិធីដូចបណ្ដឹងឧទ្ធរណ៍ មានន័យថា គឺកំណត់កាលបរិច្ឆេទទាញហេតុផលដោយផ្ទាល់មាត់ និងប្រកាស សាលដីកា ជាអាទិ៍។

**កថាភាគទី១. ការទទួលពាក្យបណ្ដឹង**

នៅពេលដើមចោទបានដាក់ពាក្យបណ្ដឹងទាមទារឱ្យជំនុំជម្រះសាជាថ្មី មកតុលាការនៃការជំនុំជម្រះ សាជាថ្មី ដើម្បីជំនុំជម្រះសាជាថ្មីលើសេចក្ដីសម្រេចដើមដែលបានចូលជាស្ថាពរ ជាការចាប់ផ្ដើមនីតិវិធីនៃ បណ្ដឹង គឺក្រឡាបញ្ជីដែលទទួលបន្ទុកក្នុងការទទួលពាក្យបណ្ដឹងត្រូវបោះត្រាដើម្បីបញ្ជាក់កាលបរិច្ឆេទ (ថ្ងៃ ខែ ឆ្នាំ)ដែលបានទទួលពាក្យបណ្ដឹងនោះ ដោយបន្ថែមក្រប និងចុះលេខបណ្ដឹង ជាអាទិ៍។ បន្ទាប់មករដ្ឋបាល តុលាការត្រូវបែងចែកសំណុំរឿងនេះ របស់តុលាការ[47] ។

**កថាភាគទី២. ការពិនិត្យពាក្យបណ្ដឹង**

នៅពេលតុលាការនៃបណ្ដឹងទាមទារជំនុំជម្រះសាជាថ្មី បានទទួលពាក្យបណ្ដឹងទាមទារជំនុំជម្រះសាជាថ្មី ជាបឋម តុលាការត្រូវពិនិត្យទៅលើចំណុចចំនួន ០២ (ពីរ) គឺ ភាពស្របច្បាប់នៃបណ្ដឹង (២.១) និង អត្ថិភាព ឬនត្ថិភាពនៃមូលហេតុនៃការជំនុំជម្រះសាជាថ្មី (២.២) ។

**១ ភាពស្របច្បាប់នៃបណ្ដឹង**

ការវិនិច្ឆ័យទៅលើលក្ខណៈស្របច្បាប់នៃបណ្ដឹងទាមទារឱ្យជំនុំជម្រះសាជាថ្មី អាចដំណើរការទៅបានដោយផ្អែកតាមការពិចារណាទៅលើ ចំណុចមួយចំនួនដូចជា៖

ក. តើពាក្យបណ្ដឹងនោះមានសរសេរចំណុចដែលចាំបាច់ត្រូវសរសេរឬទេ[48] ?

ខ. តើដើមចោទបានបង់ពន្ធដាក់ពាក្យសុំ [49] ?

---

[47] មាត្រា៣១០, ក្រមនីតិវិធីរដ្ឋប្បវេណី, លេខ នស/រកម/០៧០៦/០២១, ០៦ កក្កដា ២០០៦

[48] មាត្រា៣១២, ក្រមនីតិវិធីរដ្ឋប្បវេណី, លេខ នស/រកម/០៧០៦/០២១, ០៦ កក្កដា ២០០៦

[49] មាត្រា៦១, ក្រមនីតិវិធីរដ្ឋប្បវេណី, លេខ នស/រកម/០៧០៦/០២១, ០៦ កក្កដា ២០០៦

គ. តើអំឡុងពេលនៃការជំនុំជម្រះសាជាថ្មីត្រឹមត្រូវដែរឬទេ ?

ឃ. តើសមត្ថកិច្ចត្រឹមត្រូវដែរឬទេ ?

ការពិនិត្យនេះគឺជាការពិនិត្យអំពីភាពស្រប ឬមិនស្របនឹងលក្ខខណ្ឌទម្រង់តែប៉ុណ្ណោះ ដែលមិនពិចារណា អំពីផលប្រយោជន៍នៃបណ្តឹង ឬលក្ខខណ្ឌបណ្តឹង ឬការទាមទារមានមូលហេតុត្រឹមត្រូវតាមច្បាប់ឡើយ។ ប្រសិនបើពិនិត្យទៅឃើញថាមានចំណុចខ្វះខាត ដូចជាចំណុចចាំបាច់ដែលត្រូវសរសេរក្នុង ពាក្យ បណ្តឹង ឬពន្ធដាក់ពាក្យសុំមិនត្រូវបានបង់ ឬបង់មិនគ្រប់ចំនួន ជាអាទិ៍ តុលាការត្រូវចេញដីកាសម្រេច បង្គាប់ឱ្យកែតម្រូវចំណុចខ្វះខាតនោះ ដោយកំណត់អំឡុងពេលសមរម្យសម្រាប់កែតម្រូវ។(ក្រមនីតិវិធីរដ្ឋប្បវេណី, លេខ នស/រមក/០៧០៦/០២១, ០៦ កក្កដា ២០០៦, មាត្រា៣១០ និង មាត្រា ៧៨ កថាខណ្ឌទី១) បើដើមចោទមិន បានកែតម្រូវក្នុងអំឡុងពេលដែលបានកំណត់ តុលាការត្រូវលើកចោលពាក្យបណ្តឹងដោយដីកាសម្រេច[50] ។

ឧទាហរណ៍ ៖ ដើមចោទ "ក" នៃបណ្តឹងទាមទារឱ្យជំនុំជម្រះសាជាថ្មី មិនបានសរសេរអំពីអង្គហេតុដែលត្រូវនឹងមូលហេតុនៃការជំនុំជម្រះសាជាថ្មី។ ក្នុងករណីនេះ គឺតុលាការនឹងចេញដីកាសម្រេចបង្គាប់ឱ្យ កែតម្រូវ ដែលមានខ្លឹមសារថា៖

ទី១ បង្គាប់ឱ្យដើមចោទកែតម្រូវពាក្យបណ្តឹងទាមទារឱ្យជំនុំជម្រះសាជាថ្មី ចុះថ្ងៃទី....ខែ........ឆ្នាំ.......ឱ្យស្របតាមច្បាប់

ទី២ បង្គាប់ឱ្យដើមចោទដាក់លិខិតកែតម្រូវពាក្យបណ្តឹងមក តុលាការ ឱ្យបានមុន ថ្ងៃទី.....ខែ.......ឆ្នាំ.....។

### ២. អត្ថិភាព ឬនត្ថិភាពនៃមូលហេតុនៃការជំនុំជម្រះសាជាថ្មី

ក្នុងដំណាក់កាលនេះ តុលាការត្រូវធ្វើការវិនិច្ឆ័យលើមូលហេតុដែលដើមចោទនៃបណ្តឹងទាមទារឱ្យជំនុំជម្រះសាជាថ្មី បានសរសេរក្នុងពាក្យបណ្តឹងរបស់ខ្លួន និងធ្វើការសម្រេចថា មូលហេតុនោះមានអត្ថិភាព ឬនត្ថិភាព នៃមូលហេតុណាមួយ ក្នុងចំណោមមូលហេតុទាំង ១០ (ដប់) នៃការជំនុំជម្រះសាជាថ្មី ដែលមានបញ្ញត្តិក្នុងមាត្រា ៣០៧ កថាខណ្ឌទី១ ឬ មូលហេតុ ពិសេស ដូចមានកំណត់ក្នុងមាត្រា ៣១៨ នៃក្រមនីតិវិធីរដ្ឋប្បវេណី ។ ក្នុងករណីដែលពុំមានមូលហេតុ នៃការជំនុំជម្រះសាជាថ្មី តុលាការត្រូវចេញដីកាសម្រេចច្រានចោលនូវការទាមទារឱ្យជំនុំជម្រះសាជាថ្មីនោះ[51] ។

ផ្ទុយទៅវិញ ក្នុងករណីដែលមានអត្ថិភាពនៃមូលហេតុនៃការជំនុំជម្រះសាជាថ្មីវិញ តុលាការ ត្រូវចេញដីកាសម្រេចចាប់ផ្តើមជំនុំជម្រះសាជាថ្មី តាមមាត្រា ៣១៥ កថាខណ្ឌទី១ ដោយត្រូវសួរចុង ចម្លើយជាមុន ប៉ុន្តែការសួរនេះ មិនមែនជានីតិវិធីនៃការទាញហេតុផលដោយផ្ទាល់មាត់ទេ ដូចនេះ តុលាការអាចធ្វើតាមលិខិតជាលាយលក្ខណ៍អក្សរបាន។

---

[50] មាត្រា៣១៤ កថាខណ្ឌទី១, ក្រមនីតិវិធីរដ្ឋប្បវេណី, លេខ នស/រមក/០៧០៦/០២១, ០៦ កក្កដា ២០០៦

[51] មាត្រា៣១៤ កថាខណ្ឌទី២, ក្រមនីតិវិធីរដ្ឋប្បវេណី, លេខ នស/រមក/០៧០៦/០២១, ០៦ កក្កដា ២០០៦

## ផ្នែកទី២. ការវិនិច្ឆ័យ និងសេចក្តីសម្រេចអំពីភាពត្រឹមត្រូវ នៃបណ្តឹង

### កថាភាគទី១. ការវិនិច្ឆ័យនៃបណ្តឹង

#### ១. ដីកាសម្រេចលើកចោលបណ្តឹងទាមទារជំនុំជម្រះសាជាថ្មី

តុលាការនៃបណ្តឹងទាមទារឱ្យជំនុំជម្រះសាជាថ្មី នឹងចេញដីកាសម្រេចលើកចោលបណ្តឹងទាមទារឱ្យ ជំនុំជម្រះសាជាថ្មី បើបណ្តឹងនេះមានភាពផ្ទុយនឹងច្បាប់[52] ។

ពាក្យ "បណ្តឹងនេះមានភាពផ្ទុយនឹងច្បាប់" សំដៅដល់លក្ខណៈដូចជា "ដើមចោទមិនមែនជាបុគ្គលដែលមានសិទ្ធិប្តឹងទាមទារឱ្យជំនុំជម្រះសាជាថ្មី" ឬ "អំឡុងពេលនៃការជំនុំជម្រះសាជាថ្មីបានកន្លងផុត" ឬ "ការប្តឹងនេះមិនមែនជាកម្មវត្ថុនៃបណ្តឹងទាមទារឱ្យជំនុំជម្រះសាជាថ្មី" ឬ "តុលាការដែលបានទទួលបណ្តឹងនេះមិនមែនជាតុលាការដែលមានសមត្ថកិច្ច (តុលាការនៃបណ្តឹងទាមទារឱ្យជំនុំជម្រះសាជាថ្មី)។

ឧទាហរណ៍៖ ដើមចោទ "គ" នៃបណ្តឹងទាមទារឱ្យជំនុំជម្រះសាជាថ្មី បានដាក់បណ្តឹងនេះមកសាលាដំបូងរាជធានីភ្នំពេញ នៅថ្ងៃទី១០ ខែមករា ឆ្នាំ២០២៤ ដោយបញ្ជាក់មូលហេតុនៃការជំនុំជម្រះសាជាថ្មីថា ឯកសារភស្តុតាងដែលជាមូលដ្ឋាននៃសាលក្រមគឺក្លែងក្លាយ ខណៈសាលក្រមដែលបានចូលជា ស្ថាពរដែលជាកម្មវត្ថុនៃការជំនុំជម្រះសាជាថ្មីរបស់ "គ" មានភាគីឈ្មោះ "ក" និង "ខ" មិនមែនជាភាគី ។

ឧទាហរណ៍៖ ដើមចោទ "ខ" នៃបណ្តឹងទាមទារឱ្យជំនុំជម្រះសាជាថ្មី បានដាក់បណ្តឹងនេះ មកសាលាដំបូងរាជធានីភ្នំពេញ នៅថ្ងៃទី១០ ខែមករា ឆ្នាំ២០២៤ ដោយបញ្ជាក់មូលហេតុនៃការជំនុំជម្រះសាជាថ្មីថា ឯកសារភស្តុតាងដែលជាមូលដ្ឋាននៃសាលក្រម គឺក្លែងក្លាយ ខណៈសាលក្រមដែលបានចូលជាស្ថាពរដែលជាកម្មវត្ថុនៃការជំនុំជម្រះសាជាថ្មីរបស់ "ខ" គឺបានចូលជាស្ថាពរនៅថ្ងៃទី០១ ខែមករា ឆ្នាំ២០១៩។ (ផុតអំឡុងពេលនៃការជំនុំជម្រះសាជាថ្មី)

ករណីនេះ តុលាការនៃបណ្តឹងទាមទារឱ្យជំនុំជម្រះសាជាថ្មីនឹងចេញដីកាសម្រេចលើកចោលបណ្តឹងទាមទារឱ្យជំនុំជម្រះសាជាថ្មី ហើយសេចក្តីសម្រេចបញ្ចប់នៃដីកាសម្រេច គឺ៖

ទី១- លើកចោលបណ្តឹងទាមទារឱ្យជំនុំជម្រះសាជាថ្មី ចុះថ្ងៃទី ១០ ខែ មករា ឆ្នាំ២០២៤ របស់ដើមចោទ ។

ទី២- ប្រាក់ប្រដាប់ក្តីជាបន្ទុករបស់ដើមចោទ ។

##### ១.១. បណ្តឹងជំទាស់លើដីកាសម្រេចលើកចោល

ដីកាសម្រេចលើកចោលបណ្តឹងទាមទារឱ្យជំនុំជម្រះសាជាថ្មី អាចប្តឹងជំទាស់បាន[53] អំឡុងពេលប្តឹងជំទាស់គឺ ១(មួយ)សប្តាហ៍ គិតចាប់ពីថ្ងៃបានទទួលដំណឹងអំពីដីកាសម្រេច[54] ។ នៅពេលដែលដីកាសម្រេចនេះបានចូលជាស្ថាពរហើយ ភាគីមិនអាចដាក់ពាក្យបណ្តឹងទាមទារឱ្យជំនុំជម្រះសាជាថ្មីទៀត ដោយ

[52] មាត្រា៣១៤ កថាខណ្ឌទី ១, ក្រមនីតិវិធីរដ្ឋប្បវេណី, លេខ នស/រកម/០៧០៦/០២១, ០៦ កក្កដា ២០០៦

[53] មាត្រា៣១៤ កថាខណ្ឌទី ៤, ក្រមនីតិវិធីរដ្ឋប្បវេណី, លេខ នស/រកម/០៧០៦/០២១, ០៦ កក្កដា ២០០៦

[54] មាត្រា៣០៣ កថាខណ្ឌទី ១, ក្រមនីតិវិធីរដ្ឋប្បវេណី, លេខ នស/រកម/០៧០៦/០២១, ០៦ កក្កដា ២០០៦

យកមូលហេតុដូចគ្នាបានឡើយ [55] ។

**២. ដីកាសម្រេចច្រានចោលការទាមទារឱ្យជំនុំជម្រះសាជាថ្មី**

ក្នុងករណីបណ្ដឹងទាមទារឱ្យជំនុំជម្រះសាជាថ្មី គ្មានមូលហេតុនៃការជំនុំជម្រះសាជាថ្មីតុលាការនៃបណ្ដឹងទាមទារឱ្យជំនុំជម្រះសាជាថ្មី នឹងចេញដីកាសម្រេចច្រានចោលការទាមទារឱ្យជំនុំជម្រះសាជាថ្មី[56] ។

ពាក្យ "គ្មានមូលហេតុនៃការជំនុំជម្រះសាជាថ្មី" សំដៅបណ្ដឹងទាមទារឱ្យជំនុំជម្រះសាជាថ្មីមិនបានពន្យល់អំពីអង្គហេតុដែលត្រូវនឹងមូលហេតុនៃការជំនុំជម្រះសាជាថ្មី ស្របតាមលក្ខខណ្ឌច្បាប់ ឬ គ្មានភស្តុតាងគាំទ្រអង្គហេតុនោះ។ ឧទាហរណ៍៖ ដើមចោទ "ខ" នៃបណ្ដឹងទាមទារឱ្យជំនុំជម្រះសាជាថ្មី បានដាក់បណ្ដឹងនេះមកសាលា ដំបូងរាជធានីភ្នំពេញ នៅថ្ងៃទី១០ ខែមករា ឆ្នាំ២០២៤ ដោយបញ្ជាក់មូលហេតុការជំនុំជម្រះសាជាថ្មីថា ឯកសារភស្តុតាងដែលជាមូលដ្ឋាននៃសាលក្រម គឺក្លែងក្លាយ ប៉ុន្តែគ្មានអ្វីដែលអាចបញ្ជាក់ថាភស្តុតាងនោះត្រូវ បានក្លែងបន្លំ។

ករណីនេះ តុលាការនៃបណ្ដឹងទាមទារឱ្យជំនុំជម្រះសាជាថ្មីនឹងចេញដីកាសម្រេចច្រានចោល ការទាមទារឱ្យជំនុំជម្រះសាជាថ្មី ហើយសេចក្ដីសម្រេចបញ្ចប់នៃដីកាសម្រេច គឺ ៖

ទី១ ច្រានចោលការទាមទារឱ្យជំនុំជម្រះសាជាថ្មី ចុះថ្ងៃទី១០ ខែមករា ឆ្នាំ២០២៤ របស់ដើមចោទ

ទី២ ប្រាក់ប្រដាប់ក្ដីជាបន្ទុករបស់ដើមចោទ។

**២.១ បណ្ដឹងជំទាស់លើដីកាសម្រេចច្រានចោលបណ្ដឹងទាមទារឱ្យជំនុំជម្រះសាជាថ្មី**

ដីកាសម្រេចច្រានចោលបណ្ដឹងទាមទារឱ្យជំនុំជម្រះសាជាថ្មី អាចប្ដឹងជំទាស់បាន [57] ដែលអំឡុងពេលប្ដឹងជំទាស់គឺ ១(មួយ) សប្ដាហ៍ គិតចាប់ពីថ្ងៃបានទទួលដំណឹងអំពីដីកាសម្រេច [58] នៅពេលដែលដីកាសម្រេចនេះបានចូលជាស្ថាពរ ហើយភាគីមិនអាចដាក់ពាក្យបណ្ដឹង ទាមទារឱ្យជំនុំជម្រះសាជាថ្មីទៀតដោយយកមូលហេតុដូចគ្នាបានឡើយ [59] ។

**៣. ដីកាសម្រេចចាប់ផ្ដើមការជំនុំជម្រះសាជាថ្មី**

ក្នុងករណី តុលាការនៃបណ្ដឹងទាមទារឱ្យជំនុំជម្រះសាជាថ្មី យល់ថាមានមូលហេតុ នៃការជំនុំជម្រះសាជាថ្មី តុលាការត្រូវសួរភាគីម្ខាងទៀតជាមុន ទើបអាចចេញដីកាសម្រេច ចាប់ផ្ដើមជំនុំជម្រះសាជាថ្មីបាន[60] ។

ពាក្យ "តុលាការត្រូវសួរភាគីម្ខាងទៀតជាមុន" សំដៅការដឹកនាំនីតិវិធីរបស់តុលាការ ក្នុងការទទួលបានយោបល់ពីភាគីម្ខាងទៀត តាមរយៈការកោះហៅភាគីម្ខាងទៀតមកសួរនៅតុលាការ ឬឱ្យភាគីនោះធ្វើលិខិតឆ្លើយតបនឹងមូលហេតុនៃការជំនុំជម្រះសាជាថ្មី។ មូលហេតុនៃការកំណត់លក្ខខណ្ឌបែបនេះ ដោយ

[55] មាត្រា៣១៤ កថាខណ្ឌទី ៣, ក្រមនីតិវិធីរដ្ឋប្បវេណី, លេខ នស/រកម/០៧០៦/០២១, ០៦ កក្កដា ២០០៦

[56] មាត្រា៣១៤ កថាខណ្ឌទី ២, ក្រមនីតិវិធីរដ្ឋប្បវេណី, លេខ នស/រកម/០៧០៦/០២១, ០៦ កក្កដា ២០០៦

[57] មាត្រា៣១៤ កថាខណ្ឌទី ៤, ក្រមនីតិវិធីរដ្ឋប្បវេណី, លេខ នស/រកម/០៧០៦/០២១, ០៦ កក្កដា ២០០៦

[58] មាត្រា៣០៣ កថាខណ្ឌទី ១, ក្រមនីតិវិធីរដ្ឋប្បវេណី, លេខ នស/រកម/០៧០៦/០២១, ០៦ កក្កដា ២០០៦

[59] មាត្រា៣១៤ កថាខណ្ឌទី ៣, ក្រមនីតិវិធីរដ្ឋប្បវេណី, លេខ នស/រកម/០៧០៦/០២១, ០៦ កក្កដា ២០០៦

[60] មាត្រា៣១៥ កថាខណ្ឌទី ១ និង កថាខណ្ឌទី២, ក្រមនីតិវិធីរដ្ឋប្បវេណី, លេខ នស/រកម/០៧០៦/០២១, ០៦ កក្កដា ២០០៦

ហេតុថា ដីកាសម្រេចចាប់ផ្ដើមជំនុំជម្រះសាជាថ្មី អាចនឹងប៉ះពាល់ដល់ផលប្រយោជន៍របស់ចុងចម្លើយនៃបណ្ដឹង ទាមទារឱ្យជំនុំជម្រះសាជាថ្មី ដូចនេះភាគីចុងចម្លើយនេះ គប្បីដឹងពីអត្ថិភាពនៃការចាប់ផ្ដើមនីតិវិធី ដើម្បីឱ្យខ្លួនមានឱកាសត្រៀមលក្ខណៈគ្រប់គ្រាន់ ក្នុងការចូលរួមនីតិវិធីនៃអង្គសេចក្ដីនោះជាដើម ។ ប្រសិនបើតុលាការចេញដីកាសម្រេចចាប់ផ្ដើម ជំនុំជម្រះសាជាថ្មី ដោយមិនធ្វើនីតិវិធីសួរភាគីម្ខាងទៀត គឺជាការដឹកនាំនីតិវិធីដោយនឹងខុសច្បាប់កំណត់ ហេតុនេះបុគ្គលដែល ខូចខាតដល់ប្រយោជន៍អាចតវ៉ាចំពោះការដឹកនាំនីតិវិធីនេះ ឬបើមានការខូចខាតកើតឡើង អាចប្ដឹងទាមទារសំណង ផ្អែកលើអំពើអនីត្យានុកូល។

ក្នុងករណី តុលាការនៃបណ្ដឹងទាមទារឱ្យជំនុំជម្រះសាជាថ្មី យល់ថាមានមូលហេតុនៃការជំនុំជម្រះសាជាថ្មី និងបានសួរភាគីម្ខាងទៀតរួចហើយ តុលាការនឹងធ្វើការចេញដីកាសម្រេចចាប់ផ្ដើម ជំនុំជម្រះសាជាថ្មី ដែលខ្លឹមសារនៃ សេចក្ដីសម្រេចបញ្ចប់គឺ ៖

ចាប់ផ្ដើមជំនុំជម្រះសាជាថ្មីចំពោះសំណុំរឿងរដ្ឋប្បវេណីលេខ.......... ចុះថ្ងៃទី..........ខែ..........ឆ្នាំ..........របស់...................... ។

**៣.១ បណ្ដឹងជំទាស់លើដីកាសម្រេចចាប់ផ្ដើមការជំនុំជម្រះសាជាថ្មី**

ម្យ៉ាងវិញទៀត ដីកាសម្រេចចាប់ផ្ដើមការជំនុំជម្រះសាជាថ្មី អាចធ្វើការប្ដឹងជំទាស់បាន [61] ដែលអំឡុងពេលប្ដឹងជំទាស់គឺ ១ (មួយ) សប្ដាហ៍ គិតចាប់ពីថ្ងៃបានទទួលដំណឹងអំពីដីកាសម្រេចនេះ[62] ។

**កថាភាគទី២. អានុភាពនៃការជំនុំជម្រះសាជាថ្មី**

**១. ការផ្អាកការអនុវត្តដោយបង្ខំ**

តុលាការនៃសំណុំរឿងអនុវត្តដោយបង្ខំ អាចចេញដីកាសម្រេចបង្គាប់ ឱ្យផ្អាកការអនុវត្តដោយបង្ខំមួយរយៈតាមពាក្យសុំ ដោយឱ្យដាក់ប្រាតិភោគ ឬ មិនដាក់ប្រាតិភោគ ក្នុងករណី បានដាក់បណ្ដឹងទាមទារឱ្យជំនុំជម្រះសាជាថ្មី និង មានស្ថានភាពដែលត្រូវបានអះអាងថា មានមូលហេតុនៃការជំនុំជម្រះសាជាថ្មី ភ្ជាប់សេចក្ដីបញ្ជាក់ដំបូងអំពីហេតុនោះ[63] ។

ពាក្យ "ផ្អាកមួយរយៈ" នេះ ថាតើត្រូវធ្វើការផ្អាករយៈពេល ប៉ុន្មានខែ ឬ ប៉ុន្មានថ្ងៃ គឺអាស្រ័យលើ មូលហេតុនៃការផ្អាក បើជាការផ្អាកដោយមូលហេតុជំនុំជម្រះសាជាថ្មី ហើយតុលាការយល់ថាមានមូលហេតុនៃការជំនុំជម្រះសាជាថ្មី គឺផ្អាកការអនុវត្តដោយបង្ខំ រហូតដល់ពេលចេញសាលក្រម ឬសាលដីកាដោយសម្រេចដល់អង្គសេចក្ដី ថាតើបណ្ដឹងទាមទារឱ្យជំនុំជម្រះសាជាថ្មីនោះ ត្រូវបានទទួលស្គាល់ ឬច្រានចោលដោយតុលាការនៃបណ្ដឹងនោះ។

**២. ការលុបចោលការអនុវត្តដោយបង្ខំ**

តុលាការ អាចចេញដីកាសម្រេចបង្គាប់ ឱ្យលុបចោលការអនុវត្តដោយបង្ខំ ដែលបានធ្វើរួច តាមរយៈពាក្យសុំ ដោយឱ្យដាក់ប្រាតិភោគ ក្នុងករណី បានដាក់បណ្ដឹងទាមទារឱ្យជំនុំជម្រះសាជាថ្មី និង មាន

[61] មាត្រា៣១៥ កថាខណ្ឌទី ៣, ក្រមនីតិវិធីរដ្ឋប្បវេណី, លេខ នស/រកម/០៧០៦/០២១, ០៦ កក្កដា ២០០៦

[62] មាត្រា៣០៣ កថាខណ្ឌទី ១, ក្រមនីតិវិធីរដ្ឋប្បវេណី, លេខ នស/រកម/០៧០៦/០២១, ០៦ កក្កដា ២០០៦

[63] មាត្រា៣៦៦ កថាខណ្ឌទី ១ ចំណុច ក, ក្រមនីតិវិធីរដ្ឋប្បវេណី, លេខ នស/រកម/០៧០៦/០២១, ០៦ កក្កដា ២០០៦

ស្ថានភាពដែលត្រូវ បានអះអាងថាមានមូលហេតុនៃការជំនុំជម្រះសាជាថ្មី ដោយមានសេចក្ដីបញ្ជាក់ដំបូងអំពីអង្គហេតុនោះ[64] ។

## ផ្នែកទី៣. ការវិនិច្ឆ័យ និងចេញសាលក្រម ឬសាលដីកាអំពីអង្គសេចក្ដី

ក្រោយពេលដែល តុលាការបានចេញដីកាសម្រេចចាប់ផ្ដើមដំណើរការ នៃការជំនុំជម្រះសាជាថ្មី ហើយ ដីការសម្រេចនោះបានចូលជាស្ថាពរ នោះតុលាការនៃបណ្ដឹងទាមទារឱ្យជំនុំជម្រះសាជាថ្មី នឹងត្រូវធ្វើការវិនិច្ឆ័យទៅលើអង្គសេចក្ដី (កថាភាគទី១) និង ការសេចក្ដីសម្រេចលើអង្គសេចក្ដី (កថាភាគទី២)

### កថាភាគទី១. ការវិនិច្ឆ័យលើអង្គសេចក្ដី

ចំពោះការវិនិច្ឆ័យលើអង្គសេចក្ដី នៃបណ្ដឹងទាមទារជំនុំជម្រះសាជាថ្មី គឺ តុលាការនៃបណ្ដឹងទាមទារជំនុំជម្រះសាជាថ្មី ត្រូវវិនិច្ឆ័យ និង សម្រេចលើអង្គសេចក្ដី ត្រឹមកម្រិតនៃ ខ្លឹមសារបណ្ដឹងទាមទារជំនុំជម្រះសាជាថ្មី (គោលការណ៍នៃសិទ្ធិចាត់ចែងរបស់ភាគី) ករណីដីកាសម្រេចចាប់ ផ្ដើមជំនុំជម្រះសាជាថ្មីចូលជាស្ថាពរ[65] ។ នៅក្នុងចំណុច ដែលត្រូវសរសេរក្នុងពាក្យបណ្ដឹងទាមទារជំនុំជម្រះសាជាថ្មី ត្រង់ចំណុចស្ដីពី "សេចក្ដីទាមទារឱ្យជំនុំជម្រះសាជាថ្មី" មានលក្ខណៈដូចគ្នា នឹងខ្លឹមសារនៃសាលក្រម ដែលដើមចោទទាមទារឱ្យតុលាការចេញ (គោលគំនិតនៃការទាមទារ) បើដើមចោទទាមទារត្រឹមទំហំណា តុលាការត្រូវវិនិច្ឆ័យត្រឹមទំហំនោះ មិនអាចពិចារណាលើសពីទំហំ នៃឧបាស្រ័យបានឡើយ (គោលការណ៍នៃសិទ្ធិចាត់ចែងរបស់ភាគី)។

ឧទាហរណ៍៖ ដើមចោទ "ខ" នៃបណ្ដឹងទាមទារឱ្យជំនុំជម្រះសាជាថ្មី បានសរសេរក្នុងពាក្យបណ្ដឹងទាមទារឱ្យជំនុំជម្រះសាជាថ្មី ត្រង់ចំណុច "សេចក្ដីទាមទារឱ្យជំនុំជម្រះសាជាថ្មី ថា "បង្គាប់ឱ្យចុងចម្លើយ បង់ប្រាក់ចំនួន ១០.០០០ (មួយម៉ឺន) ដុល្លារអាមេរិក" នេះហៅថាទំហំ នៃការវិនិច្ឆ័យចំពោះអង្គសេចក្ដី ហេតុនេះ ទោះបីដើមចោទមានសិទ្ធិទាមទារលើសពីនេះ ក៏តុលាការ មិនអាចទទួលស្គាល់បានឡើយ ទោះបីមានភស្តុតាងក៏ដោយ ។

### កថាភាគទី២. សេចក្ដីសម្រេចលើអង្គសេចក្ដី

ក្រោយពេលដែល តុលាការបានចេញដីកាសម្រេចចាប់ផ្ដើមដំណើរការ នៃការជំនុំជម្រះសាជាថ្មី ហើយ ដីការសម្រេចនោះបានចូលជាស្ថាពរ នោះតុលាការ នឹងត្រូវធ្វើការវិនិច្ឆ័យ ទៅលើសាលក្រមដើម ដែលជាកម្មវត្ថុនៃបណ្ដឹងទាមទារឱ្យជំនុំជម្រះសាជាថ្មី ថាតើសាលក្រមដើមនោះត្រឹមត្រូវដែរ ឬទេ? ហើយប្រសិនបើតុលាការបានរកឃើញថា សាលក្រមដើមមានភាពត្រឹមត្រូវ តុលាការ នឹងចេញសាលក្រមច្រានចោលបណ្ដឹងទាមទារជំនុំជម្រះសាជាថ្មីនោះ (១) ។ ក្នុងករណីដែល តុលាការមិនអាចសន្និដ្ឋានបានថា សាលក្រមដើមនោះមានភាពត្រឹមត្រូវ តុលាកា រនឹងចេញសាលក្រមមួយលុបចោលសាលក្រមដើម និង សម្រេចសេចក្ដីសាជាថ្មីម្ដងទៀត (២) ។

---

[64] មាត្រា៣៦៦ កថាខណ្ឌទី ២, ក្រមនីតិវិធីរដ្ឋប្បវេណី, លេខ នស/រមក/០៧០៦/០២១, ០៦ កក្កដា ២០០៦

[65] មាត្រា៣១៦ កថាខណ្ឌទី ១, ក្រមនីតិវិធីរដ្ឋប្បវេណី, លេខ នស/រមក/០៧០៦/០២១, ០៦ កក្កដា ២០០៦

### ១.សាលក្រម ឬសាលដីកាច្រានចោលបណ្តឹងទាមទារជំនុំជម្រះសាជាថ្មី

បើទោះបីជា មានមូលហេតុនៃការជំនុំជម្រះសាជាថ្មី ក៏មិនប្រាកដថា តុលាការនៃបណ្តឹងទាមទារឱ្យជំនុំជម្រះសាជាថ្មី ត្រូវតែលុបចោល សេចក្តីសម្រេចដើមដែលបានចូលជាស្ថាពរនោះទេ ដោយហេតុថា មូលហេតុនៃការវិនិច្ឆ័យ លើអង្គសេចក្តី ក្នុងការលុបចោល លុះត្រាតែសេចក្តីសម្រេចដើម គឺ ផ្ទុយនឹងច្បាប់សារធាតុ ។ ប្រសិនបើ សេចក្តីសម្រេចដើម មិនផ្ទុយនឹងច្បាប់សារធាតុនោះទេ ហើយគ្រាន់តែមានកំហុសនីតិវិធីនោះ មិននាំឱ្យមានការលុបចោលនូវ សេចក្តីសម្រេចដើមឡើយ ដូចជាក្នុងស្ថានភាពដែល សាលក្រម ត្រូវបានចេញដោយ ចៅក្រមដែលមិនអាចចូលរួមចេញសាលក្រម (ជាញាតិរបស់ភាគីណាមួយ ជាអាទិ៍) ឬ អ្នកតំណាងភាគី គ្មានលក្ខណៈសម្បត្តិ ឬ មិនបានទទួលការប្រគល់សិទ្ធិពីម្ចាស់សិទ្ធិ ជាអាទិ៍ ដែលទាំងនេះជាកំហុសនីតិវិធី មិនមែនជាកំហុសសារធាតុនោះទេ[66] ។

ចំពោះសេចក្តីសម្រេចដើមដែលបានចូលជាស្ថាពរ មិនមានភាពផ្ទុយនឹងច្បាប់សារធាតុ គឺសេចក្តីសម្រេចដើម នៅតែមានភាពត្រឹមត្រូវ នោះតុលាការត្រូវធ្វើការច្រានចោលការទាមទារឱ្យជំនុំជម្រះសាជាថ្មី ដោយសាលក្រម ឬសាលដីកា ។

ករណីនេះតុលាការនៃបណ្តឹងបណ្តឹងទាមទារឱ្យជំនុំជម្រះសាជាថ្មី នឹងចេញសាលក្រម ឬសាលដីកាច្រានចោលការទាមទារឱ្យជំនុំជម្រះសាជាថ្មី ហើយខ្លឹមសារនៃសេចក្តីសម្រេចបញ្ចប់នៃសាលក្រម ឬ សាលដីកានេះ គឺ ៖

ទី១ ច្រានចោលការទាមទារឱ្យជំនុំជម្រះសាជាថ្មី ចុះថ្ងៃទី១០ ខែមីនា ឆ្នាំ២០២៤ របស់ដើមចោទ

ទី២ ប្រាក់ប្រដាប់ក្តីជាបន្ទុករបស់ដើមចោទ ។

### ២.សាលក្រម ឬសាលដីកាលុបចោលសាលក្រមដើម និងសម្រេចសេចក្តីម្តងទៀត

ប្រសិនបើ មានមូលហេតុនៃការជំនុំជម្រះសាជាថ្មី និង ជាមូលហេតុពាក់ព័ន្ធ លក្ខណៈសារធាតុនៃសេចក្តីសម្រេចដើម ដូចជាភស្តុតាងដែលជាមូលដ្ឋាននៃសេចក្តីសម្រេចដើម ជាភស្តុតាងក្លែងបន្លំ ជាអាទិ៍ ដោយមានសេចក្តីសម្រេចស្ថាពរ ចំពោះអំពើនេះ តុលាការនៃបណ្តឹងទាមទារឱ្យជំនុំជម្រះសាជាថ្មី នឹងចាត់ទុកថា សេចក្តីសម្រេចដើមមានវិការៈធ្ងន់ធ្ងរ ផ្នែកសារធាតុ ដែលមានភាពចាំបាច់ក្នុងការទទួលស្គាល់បណ្តឹងទាមទារឱ្យជំនុំជម្រះសាជាថ្មី តាមរយៈការចេញ សាលក្រមឬ សាលដីកា លុបចោលសេចក្តីសម្រេចដើម និងធ្វើការសម្រេចសេចក្តីម្តងទៀត[67] ។

ភាគីដែលទទួលអានុភាពពីសាលក្រម ឬ សាលដីកាថ្មីនេះ អាចប្តឹងឧទ្ធរណ៍ចំពោះសាលក្រម នៃការជំនុំជម្រះលើកទី១ ឬ ប្តឹងសាទុក្ខចំពោះសាលដីកានៃបណ្តឹងឧទ្ធរណ៍បាន ដោយគោរពតាម បទបញ្ញត្តិនៃការប្តឹងឧបាស្រ័យទៅតុលាការជាន់ខ្ពស់ តាមលំដាប់ថ្នាក់នៃការជំនុំជម្រះនីមួយៗ[68] ។

[66] មាត្រា៣១៦ កថាខណ្ឌទី ២, ក្រមនីតិវិធីរដ្ឋប្បវេណី, លេខ នស/រកម/០៧០៦/០២១, ០៦ កក្កដា ២០០៦

[67] មាត្រា៣១៦ កថាខណ្ឌទី ៣, ក្រមនីតិវិធីរដ្ឋប្បវេណី, លេខ នស/រកម/០៧០៦/០២១, ០៦ កក្កដា ២០០៦

[68] មាត្រា៣១០, ក្រមនីតិវិធីរដ្ឋប្បវេណី, លេខ នស/រកម/០៧០៦/០២១, ០៦ កក្កដា ២០០៦

ឧទាហរណ៍៖ ដើមចោទ "ខ" នៃបណ្ដឹងទាមទារឱ្យជំនុំជម្រះសាជាថ្មី បានដាក់បណ្ដឹងនេះទៅសាលាដំបូងរាជធានីភ្នំពេញ ហើយមូលហេតុនៃការជំនុំជម្រះសាជាថ្មី គឺ ភស្តុតាងដែលជាមូលដ្ឋាន នៃសាលក្រមស្ថាពរ របស់សសាលាដំបូងរាជធានីភ្នំពេញ ជាឯកសារត្រូវបានក្លែង។ សន្មតថាមានភស្តុតាងសាលាដំបូង បានដំណើរការជាបន្តបន្ទាប់ និង ចុងក្រោយសម្រេចលុបចោលសាលក្រមដើម ដែលបានចូលជាស្ថាពរ ។

ករណីនេះ សាលាដំបូងរាជធានីភ្នំពេញនឹងចេញសាលក្រម ដែលខ្លឹមសារនៃសេចក្ដីសម្រេចបញ្ចប់នៃសាលក្រមនេះគឺ ៖

ទី១-លុបចោលសាលក្រមរដ្ឋប្បវេណីលេខ ១១ "ឆ" ចុះថ្ងៃទី១០ ខែមីនា ឆ្នាំ២០២៤ របស់ សាលាដំបូងរាជធានីភ្នំពេញ

ទី២-បង្គាប់ឱ្យចុងចម្លើយបង់ប្រាក់ចំនួន ១០.០០០ (មួយម៉ឺន) ដុល្លារអាមេរិក និងប្រាក់ចំនួន ១៨% (ដប់ប្រាំបីភាគរយ) ក្នុងមួយឆ្នាំ នៃប្រាក់ ១០.០០០ (មួយម៉ឺន) ដុល្លារអាមេរិក គិតចាប់ពីថ្ងៃទី០១ ខែមករា ឆ្នាំ២០២០ រហូតសងរួច មកឱ្យដើមចោទ

ទី៣-ប្រាក់ប្រដាប់ក្ដីជាបន្ទុករបស់ចុងចម្លើយ ។

ឧទាហរណ៍៖ អ្នកដាក់ពាក្យសុំ "ខ" នៃពាក្យសុំទាមទារឱ្យជំនុំជម្រះសាជាថ្មី បានដាក់ពាក្យសុំនេះទៅ សាលាឧទ្ធរណ៍ភ្នំពេញ ហើយមូលហេតុនៃការជំនុំជម្រះសាជាថ្មី គឺ ភស្តុតាងដែលជា មូលដ្ឋាននៃដីកាសម្រេច អំពីបណ្ដឹងជំទាស់បានចូលស្ថាពរ របស់សាលាឧទ្ធរណ៍ភ្នំពេញ ជាឯកសារត្រូវបានក្លែង ។ សន្មត ថាមានភស្តុតាង សាលាឧទ្ធរណ៍បានដំណើរការនីតិវិធីជាបន្តបន្ទាប់ និង ចុងក្រោយសម្រេចថា លុបចោលដីកា សម្រេចអំពីបណ្ដឹងជំទាស់ដើមបានចូលជាស្ថាពរ ។

ករណីនេះ សាលាឧទ្ធរណ៍ភ្នំពេញនឹងចេញដីកាសម្រេច ដែលខ្លឹមសារនៃសេចក្ដីសម្រេចបញ្ចប់នៃដីកាសម្រេចនេះ គឺ ៖

ទី១-លុបចោលដីកាសម្រេចអំពីបណ្ដឹងជំទាស់លេខ ១១ "ឆ" ចុះថ្ងៃទី១០ ខែមីនា ឆ្នាំ២០២៤ របស់សាលាឧទ្ធរណ៍ភ្នំពេញ

ទី២-លើកចោលពាក្យសុំឱ្យចេញដីកាសម្រេចរក្សាការពារ ចុះថ្ងៃទី០១ ខែកុម្ភៈ ឆ្នាំ២០២៣ របស់ម្ចាស់បំណុល

ទី៣-ប្រាក់ប្រដាប់ក្ដីជាបន្ទុករបស់ភាគីម្ខាងទៀតនៃពាក្យសុំ។

ឧទាហរណ៍៖ ដើមចោទ "ក" បានប្ដឹងចុងចម្លើយ "ខ" ទៅសាលាដំបូងរាជធានីភ្នំពេញ មានខ្លឹមសារបង្គាប់ឱ្យចុងចម្លើយ ប្រគល់ដីមកឱ្យដើមចោទ។ បណ្ដឹងនេះ ត្រូវបានចាត់ការជាបន្តបន្ទាប់ រហូតសាលាដំបូងរាជធានីភ្នំពេញ បានចេញសាលក្រម តាមការទាមទាររបស់ "ក" ហើយសាលក្រមនេះបានចូលជាស្ថាពរ ។ សន្មតថា កម្មសិទ្ធិករនៃដីមិនមែនជា "ក" និង "ខ" នោះទេ ដោយសកម្មភាពបណ្ដឹងនេះ គឺជាការរួមគំនិតរបស់ "ក" និង "ខ" ក្នុងគោលបំណង ធ្វើឱ្យខូចប្រយោជន៍របស់ "គ" (តតិយជន) ខណៈប័ណ្ណកម្មសិទ្ធិនៃដី "ថ" គឺឈ្មោះ "គ" និង សន្មត "គ" មានភស្តុតាងបញ្ជាក់អំពីការរួមគំនិតនេះ ។ "គ" បានដឹង នៅពេលសាលក្រម

នេះបានចូលជាស្ថាពរ ។ ក្រោយមក "គ" បានដាក់ពាក្យបណ្តឹង ទាមទារឱ្យជំនុំជម្រះសាជាថ្មី ចំពោះសាលក្រមដែលបានចូលជាស្ថាពរនេះ ទៅសាលាដំបូងរាជធានីភ្នំពេញ ដោយយក "ក" និង "ខ" ធ្វើជាសហចុងចម្លើយ ។ សាលាដំបូងរាជធានីភ្នំពេញ បានបន្តនីតិវិធី តាមច្បាប់កំណត់ និង សម្រេចទទួលស្គាល់បណ្តឹងទាមទារឱ្យជំនុំជម្រះសាជាថ្មី របស់ "គ" ។ ករណីនេះ ខ្លឹមសារនៃសេចក្តីសម្រេចបញ្ចប់ របស់សាលក្រមនៃសាលាដំបូង គឺ៖

ទី១ លុបចោលសាលក្រមរដ្ឋប្បវេណីលេខ ១១ "ធ" ចុះថ្ងៃទី១០ ខែមីនា ឆ្នាំ២០២៤ របស់ សាលាដំបូងរាជធានីភ្នំពេញ

ទី២ លើកចោលពាក្យបណ្តឹង ចុះថ្ងៃទី០១ ខែកុម្ភៈ ឆ្នាំ២០២៣ របស់ "ក"

ទី៣ បង្គាប់ឱ្យចុងចម្លើយ "ខ" ប្រគល់ដី "ថ" មកដើមចោទ

ទី៤ ប្រាក់ប្រដាប់ក្តីជាបន្ទុករបស់សហចុងចម្លើយ។

# សេចក្តីសន្និដ្ឋាន

# សេចក្តីសន្និដ្ឋាន

តាមរយៈលទ្ធផលនៃការសិក្សាស្រាវជ្រាវ លើទ្រឹស្តីគតិយុត្តនូវប្រធានបទស្តីពី "**នីតិវិធីនៃការជំនុំជម្រះសាជាថ្មី**" យើងអាចសន្និដ្ឋានបានថា នីតិវិធីនៃការជំនុំជម្រះសាជាថ្មី គឺពិតជាមានសារៈសំខាន់ណាស់ចំពោះភាគីនៃរឿងក្តី ក្នុងការសម្រេចនូវសិទ្ធិទាមទារយុត្តិធម៌របស់ខ្លួន ដូចមានកំណត់នៅក្នុងបញ្ញត្តិច្បាប់ដោយសារតែមូលហេតុ ក្នុងចំណាត់ការរបស់តុលាការមានហេតុណាមួយកើតឡើង ដែលមានវិការៈធ្ងន់ធ្ងរ ។ ការកំណត់អំពីនីតិវិធីបែបនេះ គឺដើម្បីធានាដំណើរការនៃការជំនុំជម្រះឱ្យមានសុក្រឹត្យភាព និងតម្លាភាព រវាងភាគីវិវាទ និងដើម្បីទទួលបាននូវលទ្ធផល នៃការសម្រេចសេចក្តីមួយដ៏យុត្តិធម៌ ប្រកបដោយសុគតិគមន៍សម្រាប់ជនដែលត្រូវបានបំពានសិទ្ធិ និងផលប្រយោជន៍ ។ តាមរយៈប្រធានបទនេះ យើងអាចស្រម៉ៃបានថា ប្រសិនបើគ្មាននីតិវិធីនៃការជំនុំជម្រះសាជាថ្មីទេ នោះភាគីនៅក្នុងរឿង រួមជាមួយនឹងតតិយជន ពីសាលាក្រម ឬ សាលដីកាដែលមានផ្ទុកនូវកំហុសផ្នែកនីតិវិធីធ្ងន់ធ្ងរ នឹងត្រូវទទួលរងនូវផលប៉ះពាល់អំពីសិទ្ធិ ក៏ដូចជាផលប្រយោជន៍របស់ខ្លួន យ៉ាងធ្ងន់ធ្ងរថែមទៀតផង ។ ចំពោះកត្តានេះទៀតសោត ក៏អាចជះឥទ្ធិពលមិនល្អដែលឈានដល់ការបង្កនូវភាពចលាចល អសន្តិសុខក្នុងសង្គមផងដែរ ។ នីតិវិធីនៃការជំនុំជម្រះសាជាថ្មី គឺត្រូវកំណត់ក្នុង ក្រមនីតិវិធីរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា និងច្បាប់ផ្សេងៗទៀត ដែលបានណែនាំដោយ ក្រសួងយុត្តិធម៌ ដើម្បីជាមូលដ្ឋានក្នុងការអនុវត្តលំហូរនីតិវិធីនៃការជំនុំជម្រះសាជាថ្មីនេះ ទាំងមូល ។

មួយវិញទៀត នីតិវិធីនៃការជំនុំជម្រះសាជាថ្មី ជានីតិវិធីបណ្តឹងឧបាស្រ័យមួយពិសេស ជាងបណ្តឹងឧបាស្រ័យផ្សេងទៀត ដោយហេតុថា ក្រោយពេលដែលសាលក្រម ឬ សាលដីការមួយបានចូលជាស្ថាពររួចហើយ ការស្នើសុំឱ្យកែប្រែសេចក្តីសម្រេចរបស់តុលាការ គឺជារឿងមួយដែលមិនសមនឹងធ្វើឡើងនោះឡើយ ។ ប៉ុន្តែ ទោះបីជាយ៉ាងណាក៏ដោយ ប្រសិនបើ ក្នុងចំណាត់ការរបស់តុលាការ មានហេតុណាមួយកើតឡើងដែលមានវិការៈធ្ងន់ធ្ងរ ច្បាប់ក៏នៅតែ អនុញ្ញាតឱ្យភាគីធ្វើការតវ៉ាតាមផ្លូវតុលាការទៀតបាន តាមរយៈនីតិវិធីនៃបណ្តឹងឧបាស្រ័យទៅតុលាការ ជាន់ខ្ពស់ និងនីតិវិធីបណ្តឹងឧបាស្រ័យពិសេស ឬ អាចហៅម៉្យាងទៀតថា នីតិវិធីនៃបណ្តឹងទាមទារឱ្យជំនុំជម្រះសាជាថ្មី ដែលជាប្រធានបទនៃសារណានេះ ។ ម្យ៉ាងវិញទៀតនីតិវិធីនៃបណ្តឹងទាមទារឱ្យជំនុំជម្រះសាជាថ្មី គឺជានីតិវិធីឯករាជ្យមួយដែលបង្កើតឡើង ដើម្បីសម្រេចនូវសិទ្ធិទាមទាររបស់ភាគីនៃរឿងក្តី តាមរយៈការដាក់ពាក្យបណ្តឹងទាមទារឱ្យជំនុំជម្រះសាជាថ្មី ដោយផ្អែកលើមូលហេតុច្បាស់លាស់ ដូចដែលមានកំណត់នៅក្នុងច្បាប់។ ជារួមមកវិញ យើងអាចនិយាយបានថា នីតិវិធីនៃការជំនុំជម្រះសាជាថ្មី គឺជានីតិវិធីដែលមានភាពស្មុគស្មាញជាខ្លាំង ដោយទាមទារឱ្យមានការឆ្លងកាត់ នូវដំណាក់កាលនៃនីតិវិធីបន្តបន្ទាប់គ្នា ចាប់តាំងពីដំណាក់ កាលនៃពាក្យបណ្តឹងទាមទារឱ្យជំនុំជម្រះសាជាថ្មី ដែលមាន

ពាក់ព័ន្ធ នឹងប្រធាននៃបណ្តឹង កម្មវត្ថុនៃ បណ្តឹង មូលហេតុនៃការជំនុំជម្រះសាជាថ្មី ការសរសេរពាក្យបណ្តឹង និងការដាក់ពាក្យបណ្តឹង រហូត ដល់ដំណាក់កាលនៃការជំនុំជម្រះសាជាថ្មី ដែលរួមមានការជំនុំជម្រះលើភាពត្រឹមត្រូវនៃបណ្តឹងទាម ទារឱ្យជំនុំជម្រះសាជាថ្មី និងការជំនុំជម្រះលើអង្គសេចក្តីសាជាថ្មី ។ ភាពស្មុគស្មាញនៃនីតិវិធីនៃការ ជំនុំជម្រះសាជាថ្មី អាចឱ្យអ្នកសិក្សា ក៏ដូចជា អ្នកអនុវត្តច្បាប់យល់ពីតម្លៃដ៏សំខាន់នៃពាក្យបណ្តឹង និងការដោះស្រាយវិវាទតាមផ្លូវតុលាការ ដែលជាកាតាលីករជម្រុញឱ្យមានការផ្តល់តម្លៃដល់នីតិវិធីនៃការជំនុំជម្រះសាជាថ្មី ក៏ដូចជានីតិវិធីនៃបណ្តឹងរដ្ឋប្បវេណីផ្សេងទៀត និងជម្រុញឱ្យការអនុវត្ត កាន់តែមានប្រសិទ្ធភាពថែមមួយកម្រិតទៀត ។ ក្នុងករណីទាំងអស់នេះ គឺតម្រូវឱ្យមានការទាមទារ ពីចៅក្រមដែលទទួលបន្ទុកក្នុងសំណុំរឿង ត្រូវមានភាពបត់បែន និងមានគោលការណ៍ ច្បាស់លាស់អំពីគោលគំនិតនៃការអនុវត្តលើនីតិវិធីនសការអនុវត្តដោយបង្ខំចំពោះចលនវត្ថុនេះ។

# អនុសាសន៍

# អនុសាសន៍

ក្រោយពីបានធ្វើការបកស្រាយ និង សិក្សាស្រាវជ្រាវយ៉ាងលម្អិតចំពោះ "**នីតិវិធីនៃការជំនុំជម្រះសាជាថ្មី**" រួចមក ក្រុមរបស់យើងខ្ញុំបានយល់ឃើញថា ការអនុវត្តនីតិវិធីនៃការជំនុំជម្រះសាជាថ្មី ដែលធ្វើឡើងចំពោះសាលក្រម ឬ សាលដីកាស្ថាពរដែលមានវិការៈ ពិតជាមានសារៈប្រយោជន៍យ៉ាងខ្លាំង ដែលជាមធ្យោបាយមួយសម្រាប់ឱ្យភាគីដែលរងនូវភាពអយុត្តិធម៌ អាចទទួលបាននូវសិទ្ធិ និង ផលប្រយោជន៍របស់ខ្លួនត្រឡប់មកវិញ ។ ទន្ទឹមនឹង នេះបើទោះបីជាភាគីនៃរឿងក្តី អាចសម្រេចនូវសិទ្ធិទាមទាររបស់ខ្លួន តាមរយៈនីតិវិធីនៃការជំនុំជម្រះសាជាថ្មីក៏ដោយ ក៏ស្ថាប័នតុលាការនៅតែអនុវត្តនីតិវិធីប្រកបដោយ ភាពហ្មត់ចត់ សុក្រឹតនិងត្រឹមត្រូវស្របតាមគោលការណ៍យុត្តិធម៌ និងឆាប់រហ័ស។

ជាក់ស្តែង ដោយសង្កេតឃើញស្ថានភាពនៅក្នុងប្រទេសកម្ពុជា យើងបច្ចុប្បន្នមានការរីកចម្រើនលើគ្រប់វិស័យ ជាពិសេសវិស័យច្បាប់ គឺជាវិស័យមួយដែលដើរតួនាទីយ៉ាងសំខាន់ សម្រាប់រក្សាស្ថិរភាព និងការអភិវឌ្ឍសង្គមជាតិ ហើយក៏ជាវិស័យមួយដ៏សំខាន់ សម្រាប់ការដឹកនាំ ក៏ដូចជាការគ្រប់គ្រងប្រទេសជាតិឱ្យមាន សុខសន្តិភាព សណ្តាប់ ធ្នាប់ របៀបរៀបរយល្អ ។ ហេតុនេះ ស្ថាប័ន ឬ អង្គភាព ដែលមានសមត្ថកិច្ចពាក់ព័ន្ធ ដូចជាតុលាការ និងក្រសួងយុត្តិធម៌ ត្រូវខិតខំធ្វើយ៉ាងណាដើម្បីឱ្យការអនុវត្តច្បាប់ កាន់តែមានភាពតឹងរឹង ត្រឹមត្រូវ និងប្រសិទ្ធភាពខ្ពស់ ។ ជាពិសេសនោះ គឺចៅក្រមដែលជាអ្នកកាត់សេចក្តី តំណាងឱ្យស្ថាប័នតុលាការត្រូវជៀសឱ្យឆ្ងាយអំពី ឆន្ទាគតិ សេចក្តីលំអៀងព្រោះស្រលាញ់ ទោសាគតិ សេចក្តី លំអៀងព្រោះស្អប់ មោហាគតិ សេចក្តីលំអៀងព្រោះល្ងង់ ភយាគតិ សេចក្តីលំអៀង ព្រោះខ្លាចបុណ្យខ្លាចអំណាច ឬ ខ្លាចគតិ នៅក្នុងពេលដែលខ្លួនធ្វើការវិនិច្ឆ័យ និងសម្រេចសេចក្តី ។

មួយវិញទៀត យើងខ្ញុំទាំងពីរនាក់ ក៏សូមធ្វើការស្នើសុំទៅដល់ក្រសួងយុត្តិធម៌ និង ស្ថាប័នដែលពាក់ព័ន្ធ គប្បីសហការគ្នាយ៉ាងជិតស្និទ្ធ ដើម្បីបង្កើតកម្មវិធី ពន្យល់ច្បាប់ឱ្យមានភាពទូលំទូលាយ ទាំងផ្នែកទ្រឹស្តី ទាំងការអនុវត្ត ។ បន្ថែមពីនេះទៀត ក្រសួង យុត្តិធម៌ គប្បីធ្វើសិក្ខាសាលាឱ្យបានញឹកញាប់តាមដែលអាចធ្វើទៅបាន ដើម្បីបំផុសស្មារតីដល់អ្នក វិជ្ជាជីវៈទាំងឡាយ យល់ឱ្យបានប្រត្យក្ស និងអនុវត្តប្រកបដោយសង្គតិភាព អំពីនីតិវិធីក្នុងរឿងក្តីរដ្ឋប្បវេណី ជាពិសេស គឺពាក់ព័ន្ធនឹង នីតិវិធីដែលមានលក្ខណៈស្មុគស្មាញដូចជា នីតិវិធីនៃការជំនុំជម្រះសាជាថ្មីនេះ ជាដើម ។ ពិសេសជាងនេះទៅទៀត ទោះបីជាក្រសួងយុត្តិធម៌បានធ្វើការផ្សព្វ ផ្សាយរយៈពេលមួយឆ្នាំមុននឹងក្រមនីតិវិធីរដ្ឋប្បវេណីនេះ ត្រូវបានដាក់ឱ្យអនុវត្តក៏ដោយ ក៏ក្រសួងយុត្តិធម៌ ក៏ដូចជាស្ថាប័នពាក់ព័ន្ធ គប្បីយកចិត្តទុកដាក់បន្ថែម តាមរយៈការលើកទឹកចិត្តដល់បុគ្គល ដែលមានសមត្ថភាព និងសណ្តានចិត្តក្នុងការចែករំលែកចំណេះដឹងផ្នែករដ្ឋប្បវេណី និងតាមរយៈ ការផ្សព្វផ្សាយច្បាប់ឱ្យកាន់តែមានភាពទូលំទូលាយ ដើម្បីឱ្យអ្នកវិជ្ជាជីវៈ ដែលជាអ្នកអនុវត្តច្បាប់ ដោយផ្ទាល់ គោរពតាម

និងអនុវត្តស្របគ្នា ដែលញ៉ាំងឱ្យពួកគាត់អាចផ្តល់សេចក្តីសម្រេចជូនដល់ ប្រជាពលរដ្ឋ ដោយសុគតិគមនំ គឺ សុចរិត និងយុត្តិធម៌ ដែលចាកឆ្ងាយផុតពីឆន្ទាគតិ ទោសាគតិ ភយាគតិ និងមោហាគតិ ដែលជាអគតិធម៌ ទាំងបួន ទើបធ្វើឱ្យសង្គមកម្ពុជាទទួលបានភាពរីកចម្រើន លូតលាស់រហូតក្លាយទៅជានីតិរដ្ឋ ។

ជាចុងក្រោយក្រុមយើងខ្ញុំសង្ឃឹមយ៉ាងមុះមុតថា នឹងមានការចូលរួមពីសំណាក់ស្ថាប័នអនុវត្ត ច្បាប់ និងគ្រប់បណ្តាអ្នកច្បាប់ទាំងអស់ គប្បីចូលរួមទាំងអស់គ្នាក្នុងការពិភាក្សា ក៏ដូចជាតាក់តែងលិខិតបទដ្ឋាន គតិយុត្ត ក្នុងគោលបំណងសម្រួចនីតិវិធីនៃការជំនុំជម្រះសាជាថ្មី ឱ្យមានភាពល្អូនជាងមុន និងឆាប់រហ័ស ។

# ឯកសារយោង

# ឯកសារយោង

### ❖ លិខិតបទដ្ឋានគតិយុត្ត


- រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ១៩៩៣
- ក្រមរដ្ឋប្បវេណី នៃព្រះរាជាណាចក្រកម្ពុជា ប្រកាសឱ្យប្រើដោយព្រះរាជក្រមលេខ នស/ រកម/ ១២០៧/០៣០ ចុះថ្ងៃទី០៨ ខែធ្នូ ឆ្នាំ២០០៧ ។
- ក្រមនីតិវិធីរដ្ឋប្បវេណី នៃព្រះរាជាណាចក្រកម្ពុជា ប្រកាសឱ្យប្រើដោយព្រះរាជក្រមលេខៈ នស/រកម/ ០៧០៦/០២១ ចុះថ្ងៃទី០៦ ខែកក្កដា ឆ្នាំ២០០៦ ។
- ក្រមព្រហ្មទណ្ឌ នៃព្រះរាជាណាចក្រកម្ពុជា ប្រកាសឱ្យប្រើដោយព្រះរាជក្រមលេខ នស/ រកម/ ១១០៩/០២២ ចុះថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ២០០៩ ។
- ក្រមនីតិវិធីព្រហ្មទណ្ឌ នៃព្រះរាជាណាចក្រកម្ពុជា ប្រកាសឱ្យប្រើដោយព្រះរាជក្រមលេខ នស/រកម/ ០៨០៧/០២៤ ចុះថ្ងៃទី១០ ខែសីហា ឆ្នាំ២០០៧ ។


### ❖ សៀវភៅ


- សេចក្តីកំណត់ ចំពោះមាត្រានីមួយៗ នៃក្រមនីតិវិធីរដ្ឋប្បវេណី ឆ្នាំ២០០៧, ភ្នំពេញ៖ ក្រសួងយុត្តិធម៌
- សេចក្តីពន្យល់អំពីក្រមនីតិវិធីរដ្ឋប្បវេណី ភាគ១ នីតិវិធីបណ្តឹង ឆ្នាំ២០០៨., ភ្នំពេញ៖ ក្រសួងយុត្តិធម៌
- មេធាវី អ៊ីវ ប៉ូលី, ២០១១. មេរៀនសង្ខេបស្តីពីនីតិវិធីរដ្ឋប្បវេណី, ភ្នំពេញ៖ គណៈមេធាវីនៃព្រះរាជាណាចក្រកម្ពុជា។
- មេធាវី យឹម សារី, ២០១៨. មេរៀនសង្ខេបស្តីពី,នីតិវិធីបណ្តឹង និងបណ្តឹងឧបាស្រ័យទៅតុលាការជាន់ខ្ពស់, ភ្នំពេញ៖ គណៈមេធាវីនៃព្រះរាជាណាចក្រកម្ពុជា។
- សាស្ត្រាចារ្យ អៀប សុធានី ២០២៣. វិធីសាស្ត្រគតិយុត្ត(Legal Methodology). ភ្នំពេញ៖ សាកលវិទ្យាល័យ ភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច ។
- វិភាគទានច្បាប់. កម្រងមេរៀនសង្ខេបរដ្ឋប្បវេណីនិងនីតិវិធីរដ្ឋប្បវេណី,ឆ្នាំ២០១៥, ភ្នំពេញ
- បណ្ឌិត ហាប់ ផល្លី ២០១៧. វិធីសាស្ត្រ និងការសរសេរបែបសិក្សា. ភ្នំពេញ៖ សាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច ។

- ❖ **ឯកសារធ្វើបទបង្ហាញ**

– Kazuyuki, Higashio., Ryo, Yukawa. និង Jun, Uchiyama. ២០១៨. ការជំនុំជម្រះសាជាថ្មី បទបង្ហាញនៅក្នុងសិក្ខាសាលាស្តីពីបញ្ហានានាដែលមាននៅក្នុងរឿងក្តីរដ្ឋប្បវេណី, សាលាដំបូង និង អយ្យការអមសាលាដំបូងរាជធានីភ្នំពេញ, ១៧ មករា ។

# ឧបសម្ព័ន្ធ

# បញ្ជីឧបសម្ព័ន្ធ

## ឧបសម្ព័ន្ធទី ១ ៖ គំរូពាក្យបណ្ដឹង និងពាក្យសុំ

- ពាក្យបណ្ដឹងទាមទារឱ្យជំនុំជម្រះសាជាថ្មី
- ពាក្យសុំឱ្យជំនុំជម្រះសាជាថ្មីចំពោះដីកាសម្រេច
- ពាក្យបណ្ដឹងជំទាស់
- ពាក្យសុំដកពាក្យបណ្ដឹង

## ឧបសម្ព័ន្ធទី ២ ៖ គំរូដីកាសម្រេច សាលក្រម និងសាលដីកា

- ដីកាសម្រេចលើកចោលបណ្ដឹងទាមទារឱ្យជំនុំជម្រះសាជាថ្មី
- ដីកាសម្រេចច្រានចោលបណ្ដឹងទាមទារឱ្យជំនុំជម្រះសាជាថ្មី
- ដីកាសម្រេចចាប់ផ្ដើមជំនុំជម្រះសាជាថ្មី
- សាលក្រម

# ឧបសម្ព័ន្ធទី ១

# ព្រះរាជាណាចក្រកម្ពុជា

## ជាតិ សាសនា ព្រះមហាក្សត្រ

## ពាក្យបណ្តឹងទាមទារឲ្យជំនុំជម្រះសាជាថ្មី

**ដើមចោទ** ៖ឈ្មោះ និងអាសយដ្ឋាន

អ្នកតំណាងដោយអាណត្តិ "ដើមចោទ" ៖ មេធាវី

**ចុងចម្លើយ** ៖ឈ្មោះ និងអាសយដ្ឋាន

**សូមគោរពចូលមក**

**ឯកឧត្តមប្រធានសាលាដំបូងរាជធានីភ្នំពេញ**

**កម្មវត្ថុ** ៖សំណើសុំទាមទារឲ្យជំនុំជម្រះសាជាថ្មី

**យោង** ៖-មាត្រា ៣០៧ និងមាត្រា ៣១២ នៃក្រមនីតិវិធីរដ្ឋប្បវេណី

-សំណុំរឿងរដ្ឋប្បវេណីលេខ ........ ចុះថ្ងៃទី ០៩ ខែ ឧសភា ឆ្នាំ ២០១៤

សេចក្តីដូចមានកំណត់ និងយោងខាងលើ ខ្ញុំ សូមជម្រាបជូន **ឯកឧត្តមប្រធាន** មេត្តាជ្រាបថា ៖

**ក-សញ្ញាណនៃសាលក្រមដែលជាកម្មវត្ថុនៃបណ្តឹងទាមទារឲ្យជំនុំជម្រះសាជាថ្មី**

សាលក្រមរដ្ឋប្បវេណីលេខ................ "ញ" ចុះថ្ងៃទី ១០ ខែ សីហា ឆ្នាំ ២០១៤ របស់សាលាដំបូងរាជធានីភ្នំពេញ

**ខ-សេចក្តីទាមទារឲ្យជំនុំជម្រះសាជាថ្មី**

១.ចាប់ផ្តើមជំនុំជម្រះសាជាថ្មីចំពោះសំណុំរឿងរដ្ឋប្បវេណីលេខ ........ ចុះថ្ងៃទី ០៩ ខែ ឧសភា ឆ្នាំ ២០១៤ របស់សាលាដំបូងរាជធានីភ្នំពេញ

២.លុបចោលសាលក្រមរដ្ឋប្បវេណីលេខ............ "ញ" ចុះថ្ងៃទីថ្ងៃទី ១០ ខែ សីហា ឆ្នាំ ២០១៤ របស់សាលាដំបូងរាជធានីភ្នំពេញ

៣.បង្គាប់ឲ្យចុងចម្លើយ (Y) បង់ប្រាក់ចំនួន...........ឲ្យទៅដើមចោទ (X)

៤.ប្រាក់ប្រដាប់ក្តីជាបន្ទុករបស់ចុងចម្លើយ(Y)។

**គ-អង្គហេតុដែលត្រូវនឹងមូលហេតុនៃការជំនុំជម្រះសាជាថ្មី**

១.

២.

៣.

៤.

៥.

សេចក្តីដូចមានកំណត់ សូម **ឯកឧត្តមប្រធាន** មេត្តាអនុញ្ញាត ដោយក្តីអនុគ្រោះ។
សូម **ឯកឧត្តមប្រធាន** ទទួលនូវសេចក្តីគោរពដ៏ជ្រាលជ្រៅអំពីខ្ញុំ។

រាជធានីភ្នំពេញ, ថ្ងៃទី ២៥ ខែ វិច្ឆិកា ឆ្នាំ ២០១៨

**ហត្ថលេខា និងត្រា**

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

| [illegible] | |
|---|---|
| មកដល់ថ្ងៃទី [illegible] ម៉ោង [illegible] | |
| លេខ [illegible] តកក.រប | |
| អ្នកទទួល............. | ហត្ថលេខា............. |
| អ្នកប្រគល់............. | ហត្ថលេខា............. |
| បញ្ជូនទៅ............................ | |

## ពាក្យបណ្ដឹងសុំជំនុំជម្រះសាជាថ្មី

**ដើមចោទនៃការសុំជំនុំជម្រះសាជាថ្មី៖** ឈ្មោះ [redacted] ភេទស្រី អាយុ [redacted] ឆ្នាំ ជនជាតិខ្មែរ សញ្ជាតិខ្មែរ និងឈ្មោះ [redacted] ភេទប្រុស អាយុ ៦៣ ឆ្នាំ ជនជាតិខ្មែរ សញ្ជាតិខ្មែរ មានទីលំនៅបច្ចុប្បន្នភូមិកំពង់ក្ដី ឃុំកំពង់ចិនត្បូង ស្រុកស្ទោង ខេត្តកំពង់ធំ។
លេខទំនាក់ទំនង៖ [redacted]

**ចុងចម្លើយនៃការសុំជំនុំជម្រះសាជាថ្មី៖** ឈ្មោះ [redacted] ភេទស្រី អាយុ [redacted] ឆ្នាំ ជនជាតិខ្មែរ សញ្ជាតិខ្មែរ មានទីលំនៅបច្ចុប្បន្នភូមិកំពង់ក្ដី ឃុំកំពង់ចិនត្បូង ស្រុកស្ទោង ខេត្តកំពង់ធំ។

### សូមគោរពជូន
### ឯកឧត្តមប្រធាន តុលាការកំពូល

*សូមមេត្តាជ្រាប!*

**កម្មវត្ថុ:** ប្ដឹងសុំជំនុំជម្រះសាជាថ្មីលើសាលដីការដ្ឋប្បវេណីលេខ [redacted] ចុះថ្ងៃទី៣១ ខែសីហា ឆ្នាំ២០២១ នៅក្នុងសំណុំរឿងរដ្ឋប្បវេណីលេខ [redacted] ចុះថ្ងៃទី២១ ខែមករា ឆ្នាំ២០២១ របស់តុលាការកំពូល។

**យោង:**
- ក្រមនីតិវិធីរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា
- សំណុំរឿងរដ្ឋប្បវេណីលេខ [redacted] ចុះថ្ងៃទី២១ ខែមករា ឆ្នាំ២០២១ របស់តុលាការកំពូល។
- សាលដីការដ្ឋប្បវេណីលេខ [redacted] ចុះថ្ងៃទី៣១ ខែសីហា ឆ្នាំ២០២១ របស់តុលាការកំពូល។
- សាលដីការដ្ឋប្បវេណីលេខ [redacted] ចុះថ្ងៃទី០៩ ខែកញ្ញា ឆ្នាំ២០២០ របស់សាលាឧទ្ធរណ៍។
- សាលដីការដ្ឋប្បវេណីលេខ [redacted] ចុះថ្ងៃទី៣០ ខែតុលា ឆ្នាំ២០១៩ របស់តុលាការកំពូល។
- សាលដីការដ្ឋប្បវេណីលេខ [redacted] ចុះថ្ងៃទី០១ ខែកុម្ភៈ ឆ្នាំ២០១៩ របស់សាលាឧទ្ធរណ៍។
- សាលក្រមរដ្ឋប្បវេណីលេខ [redacted] ចុះថ្ងៃទី១៣ ខែកក្កដា ឆ្នាំ២០១៧ របស់សាលាដំបូងខេត្តកំពង់ធំ។
- ពាក្យស្នើសុំចុះបញ្ជីដីធ្លី និងទិន្នន័យចុះបញ្ជីដីធ្លីចុះថ្ងៃទី២៩ ខែធ្នូ ឆ្នាំ២០១០។
- លិខិតបញ្ជាក់របស់ប្រធានការិយាល័យរៀបចំដែនដីនគររូបនីយកម្មសំណង់ និងភូមិបាល ស្រុកស្ទោង ចុះថ្ងៃទី០១ ខែសីហា ឆ្នាំ២០១៧។

-វិញ្ញាបនបត្រសម្គាល់ម្ចាស់អចលនវត្ថុលេខ [redacted] ចុះថ្ងៃទី០១ ខែសីហា ឆ្នាំ២០១៦ ចេញដោយប្រធានមន្ទីររៀបចំដែនដី នគរូបនីយកម្ម សំណង់ និងសុរិយោដី ខេត្តកំពង់ធំ។

**I.អង្គហេតុ**

កាលពីអំឡុងឆ្នាំ២០១៧ ឈ្មោះ[redacted]បានដាក់ពាក្យបណ្ដឹងដែលមានខ្លឹមសារទាមទារ៖ ទី១. សុំគ្រប់គ្រងដី និងសុំបំបែកប្លង់ដីរួមមួយកន្លែងទំហំ ៥ ម៉ែត្រ គុណនឹង ១៧ ម៉ែត្រ មានព្រំប្រទល់ខាងជើងទល់នឹងដីឈ្មោះ [redacted] ខាងត្បូងទល់នឹងផ្លូវ, ខាងកើតទល់នឹងប្រឡាយអូរ និងខាងលិចទល់នឹងផ្លូវ មានទីតាំងស្ថិតនៅភូមិកំពង់ក្ដី ឃុំកំពង់ចិនត្បូង ស្រុកស្ទោង ខេត្តកំពង់ធំ, ទី២. សុំបំបែកប្លង់ដីរួម ដែលមានទីតាំងស្ថិតនៅភូមិកំពង់ក្ដី ឃុំកំពង់ចិនត្បូង ស្រុកស្ទោង ខេត្តកំពង់ធំ, ទី៣. សោហ៊ុយខាតបង់ពេលវេលាចំនួន $ ៥,០០០ (ប្រាំពាន់ដុល្លារអាមេរិក) និងទី៤. សុំទាមទារឱ្យចុងចម្លើយជាអ្នកទទួលបន្ទុកប្រាក់ប្រដាប់ក្ដី មកកាន់សាលាដំបូងខេត្តកំពង់ធំ។ ក្រោយមកតុលាការបានសម្រេចចេញសាលក្រមរដ្ឋប្បវេណីលេខ[redacted] ចុះថ្ងៃទី១៣ ខែកក្កដា ឆ្នាំ២០១៧ ដែលមានខ្លឹមសារសេចក្ដីសម្រេចបញ្ចប់ដូចខាងក្រោម៖

១- ប្រគល់ដីមួយកន្លែងទំហំ ៥ ម៉ែត្រ គុណនឹង ១៧ ម៉ែត្រ មានព្រំប្រទល់ខាងជើងទល់នឹងដី ឈ្មោះ ខាងត្បូងទល់នឹងផ្លូវ, ខាងកើតទល់នឹងប្រឡាយអូរ និងខាងលិចទល់នឹងផ្លូវ មានទីតាំងស្ថិតនៅភូមិកំពង់ក្ដី ឃុំកំពង់ចិនត្បូង ស្រុកស្ទោង ខេត្តកំពង់ធំ ឲ្យទៅឈ្មោះ[redacted]ភេទស្រី អាយុ៣៣ ឆ្នាំមុខរបរលក់សាច់ក្រក មានទីលំនៅភូមិកំពង់ក្ដី ឃុំកំពង់ចិនត្បូង ស្រុកស្ទោង ខេត្តកំពង់ធំ ជាម្ចាស់កម្មសិទ្ធិនៅពេលសាលក្រមចូលជាស្ថាពរ។

២- បង្គាប់ឲ្យប្រធានមន្ទីររៀបចំ ដែនដី នគរូបនីយកម្ម និងសុរិយោដីខេត្តកំពង់ធំ បំបែកប្លង់ដីទំហំ ៥ ម៉ែត្រ គុណនឹង ១៧ ម៉ែត្រ ចេញពីវិញ្ញាបនបត្រសម្គាល់ម្ចាស់អចលនវត្ថុលេខ[redacted]ចុះថ្ងៃទី ០១ ខែសីហា ឆ្នាំ២០១៦ ស្ថិតនៅភូមិកំពង់ក្ដី ឃុំកំពង់ចិនត្បូង ស្រុកស្ទោង ខេត្តកំពង់ធំ មានព្រំប្រទល់ខាងជើងទល់នឹងដីឈ្មោះ [redacted] ខាងត្បូងទល់នឹងផ្លូវ, ខាងកើតទល់នឹងប្រឡាយអូរ និងខាងលិចទល់នឹងផ្លូវ ទៅឲ្យឈ្មោះ[redacted]នៅពេលសាលក្រមចូលជាស្ថាពរ។

៣- បង្គាប់ឲ្យសហចុងចម្លើយឈ្មោះ [redacted] និងឈ្មោះ [redacted]សងសំណងខូចខាតឲ្យដើមចោទឈ្មោះ[redacted]ចំនួន $ ១០០០ (មួយពាន់) ដុល្លារអាមេរិក នៅពេលសាលក្រមចូលជាស្ថាពរ ការទាមទារលើសពីនេះត្រូវលើកចោល។

៤- រឹបអូសប្រាក់ប្រដាប់ក្ដីដែលដើមចោទបានបង់រួចហើយ។ ប្រាក់ប្រដាប់ក្ដីជាបន្ទុករបស់ចុងចម្លើយ។

ការសម្រេចសេចក្ដីនៅក្នុងសាលក្រមរបស់សាលាដំបូងខេត្តកំពង់ធំ បានប៉ះពាល់ដល់ផលប្រយោជន៍របស់យើងខ្ញុំយ៉ាងធ្ងន់ធ្ងរបំផុត ដោយយើងខ្ញុំមិនសុខចិត្ត និងបានដាក់ពាក្យបណ្ដឹងឧទ្ធរណ៍ ប្ដឹងលើសេចក្ដី



សម្រេចទាំងមូល។ ក្រោយមកសាលាឧទ្ធរណ៍ បានបញ្ចប់ការទាញហេតុផលផ្ទាល់មាត់ និងបានសម្រេចសេចក្តីតាមសាលដីការដ្ឋប្បវេណី [redacted] ចុះថ្ងៃទី០១ ខែកុម្ភៈ ឆ្នាំ២០១៩ ដែលមានខ្លឹមសារនៃសេចក្តីសម្រេចបញ្ចប់ដូចខាងក្រោម៖

១- លុបចោលសាលក្រមរដ្ឋប្បវេណីលេខ [redacted] ចុះថ្ងៃទី១៣ ខែកក្កដា ឆ្នាំ២០១៧ របស់សាលាដំបូងខេត្តកំពង់ធំ ចោលជាអាសារបង់។

២- ច្រានចោលការទាមទាររបស់ដើមចោទឈ្មោះ [redacted] តាមពាក្យបណ្តឹងចុះថ្ងៃទី២១ ខែមេសា ឆ្នាំ២០១៧។

៣- ប្រាក់ប្រដាប់ក្តីជាបន្ទុករបស់ដើមចោទ។

ក្រោយមកឈ្មោះ [redacted] មិនសុខចិត្តក៏បានប្តឹងសាទុក្ខលើសេចក្តីសម្រេចទាំងមូលរបស់សាលាឧទ្ធរណ៍។ តុលាការកំពូលបានបញ្ចប់ការទាញហេតុផលផ្ទាល់មាត់ និងបានសម្រេចសេចក្តីតាមសាលដីការដ្ឋប្បវេណីលេខ [redacted] ចុះថ្ងៃទី៣០ ខែតុលា ឆ្នាំ២០១៩ ដែលមានខ្លឹមសារនៃសេចក្តីសម្រេចបញ្ចប់ដូចខាងក្រោម៖

១- ទទួលពាក្យបណ្តឹងសាទុក្ខលេខ [redacted] ចុះថ្ងៃទី១៣ ខែកុម្ភៈ ឆ្នាំ២០១៩ របស់ឈ្មោះ [redacted]

២- បដិសេធសាលដីការដ្ឋប្បវេណីលេខ [redacted] ចុះថ្ងៃទី០១ ខែកុម្ភៈ ឆ្នាំ២០១៩ របស់សាលាឧទ្ធរណ៍ ទាំងមូល។

៣- បង្វិលសំណុំរឿងលេខ [redacted] ចុះថ្ងៃទី២១ ខែឧសភា ឆ្នាំ២០១៩ របស់តុលាការកំពូល ទៅសាលាឧទ្ធរណ៍ ដើម្បីជំនុំជម្រះសារជាថ្មីឡើងវិញ។

៤- ប្រាក់ប្រដាប់ក្តីជាន់តុលាការកំពូលជាបន្ទុករបស់ចុងចម្លើយ។

៥- សាលដីកានេះជំនុំជម្រះជាសាធារណៈ នៅថ្ងៃទី២២ ខែតុលា ឆ្នាំ២០១៩ និងប្រកាសជាសាធារណៈ នៅថ្ងៃទី៣០ ខែតុលា ឆ្នាំ២០១៩។

សាលាឧទ្ធរណ៍បានបើកការជំនុំជម្រះសារជាថ្មីឡើងវិញ ដោយបញ្ចប់ការទាញហេតុផលដោយផ្ទាល់មាត់ នៅថ្ងៃទី១៣ ខែសីហា ឆ្នាំ២០២០ និងបានសម្រេចសេចក្តីតាមរយៈសាលដីការដ្ឋប្បវេណី [redacted] ចុះថ្ងៃទី០៨ ខែសីហា ឆ្នាំ២០២០ ដែលមានខ្លឹមសារនៃសេចក្តីសម្រេចបញ្ចប់ដូចខាងក្រោម៖

១- ច្រានចោលការទាមទាររបស់ដើមចោទឈ្មោះ [redacted]

២- ប្រាក់ប្រដាប់ក្តីជាបន្ទុករបស់ដើមចោទឈ្មោះ [redacted]

សាលដីកានេះប្រកាសជាសាធារណៈនៅសាលសវនាការ នៅថ្ងៃទី០៨ ខែកញ្ញា ឆ្នាំ២០២០។



មេធាវីតំណាងដោយអាណត្តិរបស់ឈ្មោះ [redacted] ពាក្យប្តឹងសាទុក្ខលើកទី២ លើសាលដីកាខាងលើ ហើយតុលាការកំពូលបានជំនុំជម្រះលើសំណុំរឿងនេះ និងបានសម្រេចចេញសាលដីការដ្ឋប្បវេណី [redacted] ចុះថ្ងៃទី៣១ខែសីហា ឆ្នាំ២០២១ ដែលមានខ្លឹមសារនៃសេចក្តីសម្រេចបញ្ចប់ដូចខាងក្រោម៖

១. **ទទួល** បណ្តឹងសាទុក្ខលេខ[redacted]ចុះថ្ងៃទី១៤ ខែមករា ឆ្នាំ២០២១ របស់មេធាវី [redacted] អ្នកតំណាងដោយអាណត្តិឲ្យដើមចោទឈ្មោះ[redacted]

២. **បដិសេធ** សាលដីការដ្ឋប្បវេណីលេខ [redacted] ចុះថ្ងៃទី០៩ ខែកញ្ញា ឆ្នាំ២០២០ របស់សាលាឧទ្ធរណ៍ទាំងមូល។

៣. **ប្រគល់ដីទំនាស់** ដែលមានទំហំ ABCDA ដែលមានប្រវែង និងព្រំប្រទល់៖ ខាងជើងមានប្រវែង ១៧.៨៨ ម៉ែត្រ មានព្រំជាប់ក្បាលដីលេខ ៤០៥, ខាងត្បូងមានប្រវែង ១៧.២៥ ម៉ែត្រ មានព្រំជាប់ផ្លូវគ្រួសក្រហម, ខាងលិចមានប្រវែង ៤ ម៉ែត្រ មានព្រំជាប់ផ្លូវបេតុង និងខាងកើតមានប្រវែង ៦.០១ ម៉ែត្រមានព្រំជាប់អូរតាមលិខិតលេខ [redacted]ជនសស/កធ ចុះថ្ងៃទី១៩ ខែកញ្ញា ឆ្នាំ២០១៨ របស់មន្ទីររៀបចំដែនដី នគរូបនីយកម្ម សំណង់ និងសុរិយោដី ខេត្តកំពង់ធំ ដែលមានភ្ជាប់គំនូសបង្ហាញប្លង់ទីតាំងដីទំនាស់មានទីតាំងស្ថិតនៅភូមិកំពង់ក្តី ឃុំកំពង់ចិនត្បូង ស្រុកស្ទោង ខេត្តកំពង់ធំ ឲ្យទៅឈ្មោះ[redacted]ភេទស្រី អាយុ[redacted]ឆ្នាំ កាន់កាប់ជាកម្មសិទ្ធិតទៅ។

៤. **បង្គាប់ឲ្យ** ឈ្មោះ[redacted]និងឈ្មោះ[redacted]ធ្វើនីតិវិធីចុះបញ្ជីបំបែកក្បាលដីចេញពីវិញ្ញាបនបត្រសម្គាល់ម្ចាស់អចលនវត្ថុលេខ [redacted] ចុះថ្ងៃទី០១ ខែសីហា ឆ្នាំ២០១៦ ឲ្យឈ្មោះ[redacted]

៥. **បង្គាប់ឲ្យ** សហចុងចម្លើយឈ្មោះ[redacted] និងឈ្មោះ[redacted]សងសំណងការខូចខាតឲ្យដើមចោទឈ្មោះ លាង ហ៊ោហ៊ាង ចំនួន ៤ ០០០ ០០០ (បួនលាន) រៀល ឲ្យឈ្មោះ[redacted]

៦. **ប្រាក់ប្រដាប់ក្តី** ជាបន្ទុករបស់ភាគីសហចុងចម្លើយឈ្មោះ [redacted] និងឈ្មោះ[redacted]

**II. អង្គច្បាប់**

**ឯកឧត្តមប្រធាន** ជាទីគោរព!

ចំពោះការសម្រេចរបស់តុលាការកំពូលតាមរយៈសាលដីការដ្ឋប្បវេណីលេខ[redacted]ចុះថ្ងៃទី៣១ ខែសីហា ឆ្នាំ២០២១ ដែលមានខ្លឹមសារនៃដីកាសម្រេចខាងលើនេះ គឺពុំមានភាពត្រឹមត្រូវតាមគតិច្បាប់ឡើយ ព្រមទាំងបានធ្វើឲ្យយើងខ្ញុំបាត់បង់នូវផលប្រយោជន៍ និងរងនូវភាពអយុត្តិធម៌ជាខ្លាំង។ ហេតុនេះដើម្បីជាអំណះ



អំណាងបញ្ជាក់អំពីអង្គច្បាប់ ដែលយើងខ្ញុំមានសិទ្ធិក្នុងការធ្វើបណ្តឹងសុំជំនុំជម្រះសាជាថ្មីក្នុងសំណុំរឿងនេះ យើងខ្ញុំសូមជម្រាបជូន **ឯកឧត្តមប្រធាន** មេត្តាជ្រាបដូចតទៅ៖

**ចំណុចទី១.** ការដែលតុលាការកំពូលសម្រេចបដិសេធលើសាលដីការដ្ឋប្បវេណី[redacted] ចុះថ្ងៃទី០៩ ខែកញ្ញា ឆ្នាំ២០២០ របស់សាលាឧទ្ធរណ៍ ដោយយល់ឃើញថា វិញ្ញាបនបត្រសម្គាល់ម្ចាស់អចលនវត្ថុលេខ[redacted]ចុះថ្ងៃទី០១ ខែសីហា ឆ្នាំ២០១៦ ត្រូវបានចេញក្រោយលិខិតធ្វើអំណោយផ្តាច់ រវាងទាយកឈ្មោះ[redacted]និងបដិគាហកឈ្មោះ[redacted]ចុះថ្ងៃទី១០ ខែតុលា ឆ្នាំ២០១៣ ដែលជាហេតុនាំឱ្យឈ្មោះ[redacted]សិទ្ធិលើដីទំនាស់នោះ គឺមិនត្រឹមត្រូវទេ ព្រោះតុលាការកំពូលមិនបានពិចារណាទៅលើអតិភាពកម្មសិទ្ធិនៃការធ្វើប្រទានកម្មនោះទេ។ ជាក់ស្តែងម្តាយរបស់យើងខ្ញុំឈ្មោះ [redacted] បានធ្វើប្រទានកម្មអំណោយអចលនវត្ថុខាងលើមកឱ្យយើងខ្ញុំជាកូនបង្កើតតាំងពីឆ្នាំ២០១០ នៅពេលដែលគាត់នៅមានស្មារតីគ្រប់គ្រាន់។ ក្រោយមកនៅកំឡុងខែធ្នូ ឆ្នាំ២០១០ នៅពេលដែលរដ្ឋចុះមកធ្វើការចុះបញ្ជីដីធ្លីមានលក្ខណៈជាប្រព័ន្ធនោះ គឺយើងខ្ញុំទាំងពីរនាក់បងប្អូនដែលមានឈ្មោះ[redacted] និងឈ្មោះ [redacted] បានរៀបចំដាក់ពាក្យស្នើសុំចុះបញ្ជីដីធ្លីនៅពេលនោះតែម្តង ដោយបានបំពេញបែបបទស្នើសុំតាមទម្រង់នីតិវិធីសុរិយោដី មានការបិតប្រកាសផ្សាយនៅក្នុងឆ្នាំ២០១២ រហូតដល់តែទទួលបានវិញ្ញាបនបត្រសម្គាល់ម្ចាស់អចលនវត្ថុខាងលើនេះនៅក្នុងឆ្នាំ២០១៦ ដោយយើងខ្ញុំមិនបានបោះបង់ ឬមិនបំពេញលក្ខខណ្ឌក្នុងការទទួលអំណោយនេះនោះទេ។

**ចំណុចទី២.** នៅក្នុង សំអាងហេតុត្រង់ចំណុចទី៣ ក្នុងសាលដីការបស់តុលាការកំពូលខាងលើ ដែលក្រុមប្រឹក្សាយល់ថា៖ [...]លិខិតអំណោយផ្តាច់នេះ ត្រូវបានយកទៅបង្កើតកិច្ចសន្យាហ៊ីប៉ូតែក ចុះថ្ងៃទី០៣ ខែកុម្ភៈ ឆ្នាំ២០១៧ ជាមួយស្ថាប័នមីក្រូហិរញ្ញវត្ថុ អិលអូអិលស៊ី (ខេមបូឌា) ភីអិលស៊ី ដោយមានការចូលរួមផ្តិតមេដៃរបស់ចុងចម្លើយឈ្មោះ[redacted]លើកិច្ចសន្យានោះ អាចបញ្ជាក់ឲ្យឃើញថាចុងចម្លើយឈ្មោះ[redacted] ទទួលស្គាល់ដើមចោទជាម្ចាស់កម្មសិទ្ធិលើដីទំនាស់ តាមរយៈលិខិតអំណោយនេះហើយ។ ដូច្នេះដើមចោទគឺជាអ្នកមានសិទ្ធិលើដីទំនាស់នេះ គឺជាការយល់ឃើញពុំត្រឹមត្រូវទេ ព្រោះឈ្មោះ[redacted] បានផ្តិតមេដៃលើកិច្ចសន្យានោះមែន ប៉ុន្តែមិនមែនមានន័យថាឈ្មោះ [redacted] ទទួលស្គាល់លិខិតអំណោយពីម្តាយឈ្មោះ [redacted] មកឈ្មោះ [redacted]នោះទេ គឺផ្តិតដោយមនោសញ្ចេតនាទឹកចិត្តអាណិត ស្រឡាញ់ ចំពោះឈ្មោះ[redacted]ដែលជាកូនចញ្ចឹមតែប៉ុណ្ណោះ ព្រោះប្រសិនបើឈ្មោះ[redacted] មិនផ្តិតមេដៃអមលើកិច្ចសន្យាដើម្បីធានាទេ នោះស្ថាប័នមីក្រូហិរញ្ញវត្ថុ អិលអូអិលស៊ី (ខេមបូឌា) ភីអិលស៊ី និងមិនព្រមផ្តល់ប្រាក់កម្ចីឲ្យដើមចោទ។ ការផ្តិតនេះគ្រាន់ជាការធានាឲ្យឈ្មោះ[redacted] មានលទ្ធភាពដើម្បីខ្ចីប្រាក់ពីធនាគារយកមកប្រើប្រាស់ ប៉ុន្តែបែរជាឈ្មោះ [redacted] ឯកសារផ្តិតមេដៃអមលើកិច្ចសន្យាខ្ចីប្រាក់នោះ យកមកប្រើប្រាស់ក្នុងចេតនាទុច្ចរិតទាមទារយកដីនេះធ្វើជាកម្មសិទ្ធិរបស់ខ្លួនឡើងវិញ។ កន្លងមកឈ្មោះ [redacted] បាន



ធ្វើលិខិតបដិសេធមិនទទួលស្គាល់ការផ្តិតមេដៃជានានោះវិញ ដោយបានបង្ហាញឆន្ទៈត្រឹមត្រូវថាដីដែលបានយកទៅបង្កើតកិច្ចសន្យាហ៊ីប៉ូតែកខាងលើនេះគឺមិនមែនជាដីរបស់ឈ្មោះ [redacted] នោះទេ ប៉ុន្តែវាជាដីរបស់យើងខ្ញុំ។

**ចំណុចទី៣. ចំពោះ *សំអាងហេតុក្រង់ចំណុចទី៤* ក្នុងសាលដីការបស់តុលាការកំពូលខាងលើ ដែល**ក្រុមប្រឹក្សាយល់ថា៖ [...]ការធ្វើអំណោយតាមរយៈលិខិត ចុះថ្ងៃទី១០ ខែតុលា ឆ្នាំ២០១៣ គឺស្របតាមឆន្ទៈរបស់ទាយកឈ្មោះ [redacted] ហើយដើមចោទបានគ្រប់គ្រង និងកាន់កាប់ជាប់រហូតមកដល់សព្វថ្ងៃ។ ហេតុនេះ ដើមចោទមានសិទ្ធិលើដីទំនាស់នេះ។

ចំពោះការយល់ឃើញបែបនេះ គឺពុំត្រឹមត្រូវតាមអង្គហេតុ និងអង្គច្បាប់នោះទេ។ ជាក់ស្តែង យើងខ្ញុំសូមបញ្ជាក់ថា ការធ្វើអំណោយពីម្តាយឈ្មោះ [redacted] ទៅឲ្យឈ្មោះ [redacted] នៅក្នុងឆ្នាំ២០១៣ ដែលការធ្វើអំណោយនេះគឺមិនត្រឹមត្រូវតាមគតិច្បាប់នោះទេ ព្រោះដីនេះម្តាយយើងខ្ញុំបានធ្វើអំណោយមកឱ្យយើងខ្ញុំក្នុងឆ្នាំ២០១០ ហើយយើងខ្ញុំបាននាំគ្នាទៅចុះបញ្ជីដីធ្លីមានលក្ខខណៈជាប្រព័ន្ធតាមនីតិវិធីច្បាប់ នេះបានបញ្ជាក់ឱ្យឃើញថាម្តាយរបស់យើងខ្ញុំគាត់មិនមានដី និងមិនមានសិទ្ធិចាត់ចែងនៅលើដីនេះទៀតនោះទេ ព្រោះនៅពេលដែលគាត់បានធ្វើអំណោយមកឱ្យយើងខ្ញុំរួច គាត់មិនបានបង្ហាញឆន្ទៈក្នុងការទាមទារទៅវិញ ឬមានការឯកភាពប្រគល់ក្រលប់ពីយើងខ្ញុំដែរ។ ចំពោះការធ្វើអំណោយមកឲ្យឈ្មោះ [redacted] នៅក្នុងឆ្នាំ២០១៣ នេះ គឺមានវិការៈដោយហេតុថានៅពេលនោះម្តាយរបស់យើងខ្ញុំកំពុងមានវ័យចាស់ជរាខ្លាំង និងពុំមានស្មារតីគ្រប់គ្រាន់ វង្វេងទៅហើយ ប៉ុន្តែហេតុអ្វីបានជាគាត់បែរជាធ្វើអំណោយដីដែលគាត់បានចែកឲ្យយើងខ្ញុំហើយនោះ ទៅប្រគល់ឲ្យដើមចោទឈ្មោះ [redacted] ទៀត មួយវិញទៀតការរស់នៅលើដីនោះរបស់ដើមចោទគឺគ្រាន់តែជាការអាស្រ័យផលតែប៉ុណ្ណោះ មិនមែនរស់នៅក្នុងនាមជាម្ចាស់កម្មសិទ្ធិឡើយ។

ជាមួយគ្នានេះ នៅក្នុងសំណុំរឿងរដ្ឋប្បវេណីលេខ [redacted] ចុះថ្ងៃទី២១ ខែមករា ឆ្នាំ២០២១ របស់តុលាការកំពូល គឺតុលាការមិនបានបញ្ចូលសេចក្តីវិនិច្ឆ័យលើចំណុចសំខាន់មួយចំណុចគឺ **"លិខិតធ្វើអំណោយផ្តាច់ ចុះថ្ងៃទី២៩ ខែតុលា ឆ្នាំ២០១០"** ។ លិខិតនេះមានសារៈសំខាន់បំផុតនៅក្នុងរឿងក្តីនេះ ដោយលិខិតធ្វើអំណោយផ្តាច់នេះ បានបញ្ជាក់ថា ឈ្មោះ [redacted] បានធ្វើអំណោយផ្តាច់ចំពោះដីដែលជាកម្មវត្ថុនៃវិវាទនេះ មកឱ្យយើងខ្ញុំតាំងពីថ្ងៃទី២៩ ខែតុលា ឆ្នាំ២០១០ មកម្ល៉េះ ហើយយើងខ្ញុំក៏បានទទួលយកដីនេះចាប់ពីពេលចុះលិខិតអំណោយផ្តាច់នេះដែរ ដោយមានផ្តិតស្នាមមេដៃដើម្បីបញ្ជាក់ភស្តុតាងអំពីការបង្ហាញឆន្ទៈទទួលយកដីនេះផងដែរ។ ចំណុចនេះ បានបញ្ជាក់ឱ្យឃើញថា អំណោយ (ប្រទានកម្ម) លើដីវិវាទនេះ ត្រូវបានអនុវត្តការប្រគល់ពីឈ្មោះ [redacted] មកឱ្យយើងខ្ញុំរួចស្រេចហើយ។ លើសពីនេះទៀត ក្រោយទទួលអំណោយ យើងខ្ញុំក៏បានកាន់កាប់ និងបានចុះបញ្ជីសុរិយោដី ដើម្បីក្លាយជាកម្មសិទ្ធិករលើដីនេះត្រឹមត្រូវតាមច្បាប់ តាំងពីឆ្នាំ២០១០ មកម្ល៉េះ ដោយ

មានទិន្នន័យចុះបញ្ជីដីធ្លីចុះថ្ងៃទី២៩ ខែធ្នូ ឆ្នាំ២០១០ ជាភស្តុតាងស្រាប់។ ហើយ ការចុះបញ្ជីនេះ ក៏ត្រូវវាស់វែង និងបានបិទផ្សាយជាសាធារណៈស្ថាពរ តាំងពីថ្ងៃទី៣០ ខែមីនា ឆ្នាំ២០១២ រួចហើយ ដោយមិនមានបុគ្គលណាម្នាក់មកតតាំង ឬជំទាស់ឡើយ។ យោងអនុក្រឹត្យស្តីពីនីតិវិធីនៃការកសាងប្លង់សុរិយោដី និងសៀវភៅគោលបញ្ជីដីធ្លី មាត្រា១២ ក្នុងអំឡុងពេលបិទផ្សាយជាសាធារណៈ ជនណាដែលមានឈ្មោះក្នុងបញ្ជី ឬអ្នកដែលមានផលប្រយោជន៍លើក្បាលដីណាមួយដែលចាត់ទុកថា ឯកសារនៃការវិនិច្ឆ័យមិនជាក់លាក់ ឬមិនពេញលេញអាចផ្តល់ដំណឹងដល់គណៈកម្មការរដ្ឋបាលនូវការជំទាស់របស់ខ្លួន។ ជាក់ស្តែង ក្នុងអំឡុងពេលបិទផ្សាយរហូតដល់បញ្ចប់ការបិទផ្សាយជាសាធារណៈ មិនមានការជំទាស់ពីបុគ្គលណាម្នាក់ឡើយ។ យោងសារាចរណែនាំអនុវត្តនីតិវិធីនៃការកសាងប្លង់សុរិយោដី និងសៀវភៅគោលបញ្ជីដីធ្លី (ការចុះបញ្ជីដីធ្លីមានលក្ខណៈជាប្រព័ន្ធ) ដំណាក់កាលទី៤ -ក្រោយពីអភិបាលខេត្ត-ក្រុង និងរដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់បានចុះហត្ថលេខាសម្រេចយល់ព្រមហើយ ឯកសារនៃការវិនិច្ឆ័យត្រូវបានបញ្ចប់ជាស្ថាពរ និងត្រូវបានចាត់ទុកជាឯកសារផ្លូវការតាមផ្លូវច្បាប់ ចំពោះក្បាលដីដែលមិនទាក់ទងនឹងវិវាទ- ។ យោងលិខិតបញ្ជាក់លេខ ៥៤/១៧ ចុះថ្ងៃទី១ ខែសីហា ឆ្នាំ២០១៧ របស់ការិយាល័យភូមិបាលស្រុកស្ទោង បានបញ្ជាក់ផងដែរថា ដីនេះ បាន វាស់វែង និងបិទផ្សាយជាសាធារណៈស្ថាពរ តាំងពីថ្ងៃទី៣០ ខែមីនា ឆ្នាំ២០១២ ដោយមិនមានជនណាមកជំទាស់ឡើយ។ មានន័យថា ឯកសារចុះបញ្ជីដីវិវាទនេះ ត្រូវបានចាត់ទុកជាឯកសារផ្លូវការតាមផ្លូវច្បាប់នៅថ្ងៃទី៣០ ខែមីនា ឆ្នាំ២០១២។ ដូចនេះ ចំពោះដីវិវាទនេះបានក្លាយជាកម្មសិទ្ធិស្របច្បាប់របស់យើងខ្ញុំតាំងពីឆ្នាំ២០១២ មកម្ល៉េះ ហើយម្តាយរបស់យើងខ្ញុំឈ្មោះ[redacted]បាត់បង់សិទ្ធិកាន់កាប់ ឬបាត់បង់អត្ថិភាពជាកម្មសិទ្ធិករតាំងពីថ្ងៃដែលគាត់បានធ្វើអំណោយមកឱ្យយើងខ្ញុំក្នុងឆ្នាំ២០១០ មកម្ល៉េះ។ ម្យ៉ាងវិញទៀត ក្រោយពេលធ្វើអំណោយឱ្យយើងខ្ញុំហើយ ឈ្មោះ [redacted] មិនបានធ្វើសកម្មភាពទាមទារដីនេះពីយើងខ្ញុំវិញ ឬបង្ហាញសកម្មភាពលុបចោលចំពោះអំណោយ (ប្រទានកម្ម)ដីនេះពីយើងខ្ញុំទេ។ យោងក្រមរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា មាត្រា៥៧០ ទោះបីជាបានធ្វើការសន្យាប្រទានកម្មក៏ដោយ ប្រសិនបើមិនបានធ្វើជាលាយលក្ខណ៍អក្សរស្តីអំពីប្រទានកម្មទេ ភាគីនៃកិច្ចសន្យា អាចលុបចោលកិច្ចសន្យា ដោយដកការបង្ហាញឆន្ទៈនៃការធ្វើប្រទានកម្មវិញបាន។ ប៉ុន្តែ **ចំពោះផ្នែកដែលបានអនុវត្តហើយ មិនអាចដកការបង្ហាញឆន្ទៈនៃការធ្វើប្រទានកម្មវិញបានឡើយ។** ហេតុនេះ ឈ្មោះ [redacted]មិនមានសិទ្ធិកាន់កាប់ដីនេះ ឬមានអត្ថិភាពនៃកម្មសិទ្ធិលើដីនេះ ដែលនាំឱ្យគាត់មិនមានសិទ្ធិចាត់ចែងដីនេះស្របច្បាប់ទៅឱ្យតតិយជនណាម្នាក់ឡើយ។ បានសេចក្តីថា ការធ្វើអំណោយលើដីវិវាទទៅឱ្យឈ្មោះ[redacted] ក្នុងឆ្នាំ២០១៣ ជាសកម្មភាពផ្ទុយច្បាប់ ព្រោះថា នៅក្នុងឆ្នាំ ២០១៣ ឈ្មោះ[redacted] មិនមានសិទ្ធិចាត់ចែងលើដីនេះទេ។ គួរកត់សម្គាល់ថា តាំងពីពេលដែលម្តាយរបស់យើងខ្ញុំបានធ្វើអំណោយដីឲ្យយើងខ្ញុំរួចមក ម្តាយរបស់យើងខ្ញុំ ពុំដែលបានធ្វើលិខិតផ្តាច់អំណោយនោះវិញឡើយ ដែលមានន័យថាការធ្វើអំណោយដីពីម្តាយយើងខ្ញុំ មកឲ្យយើងខ្ញុំនោះ នៅតែមានសុពលភាព ដែលយើងខ្ញុំមានសិទ្ធិស្នើសុំចុះបញ្ជីដីដោយស្របច្បាប់។





## III. សន្និដ្ឋាន

សេចក្តីដូចដែលយើងខ្ញុំបានជម្រាបជូនក្នុងអង្គហេតុ និងអង្គច្បាប់ខាងលើ បានបង្ហាញឲ្យឃើញយ៉ាងច្បាស់ថា ចំពោះការធ្វើអំណោយដីពីម្តាយរបស់យើងខ្ញុំ ឲ្យទៅឈ្មោះ[redacted]គឺមានវិការៈយ៉ាងធ្ងន់ធ្ងរ ដែលនាំឲ្យតុលាការមានការភាន់ច្រលំលើអង្គហេតុ និងនាំឲ្យមានការភាន់ច្រឡំទៅលើអង្គច្បាប់ ទើបសេចក្តីសម្រេចនេះបានធ្វើឲ្យយើងខ្ញុំដែលជាម្ចាស់កម្មសិទ្ធិលើដីទំនាស់ ដែលមានវិញ្ញាបនបត្រសម្គាល់ម្ចាស់អចលនវត្ថុត្រឹមត្រូវ ស្របច្បាប់ បែរជាត្រូវបាត់បង់ដីរបស់ខ្លួនយ៉ាងអយុត្តិធម៌ជាទីបំផុត។

ដូចនេះដើម្បីជាប្រយោជន៍ និងទទួលបានភាពយុត្តិធម៌ដល់ការសម្រេចសេចក្តី ដោយសារតែយើងខ្ញុំមានភស្តុតាងថ្មីជា **ទិន្នន័យចុះបញ្ជីដីធ្លីចុះថ្ងៃទី២៩ ខែធ្នូ ឆ្នាំ២០១០ និងមានការចុះហត្ថលេខាទទួលស្គាល់ពីមន្រ្តីគ្រប់គ្រងការងារតំបន់វិនិច្ឆ័យ ចុះថ្ងៃទី២០ ខែមករាឆ្នាំ២០១១ ឈ្មោះ** [redacted]ដែលជាឯកសារភស្តុតាងថ្មីដែលយើងខ្ញុំទើបតែស្នើសុំបានពីមន្ទីររៀបចំដែនដី នគរូបនីយកម្ម សំណង់ និងសុរិយោដីខេត្តកំពង់ធំ ក្នុងពេលថ្មីៗនេះ ហើយនេះជាភស្តុតាងថ្មីគប្បីឲ្យតុលាការកំពូលធ្វើការពិចារណា និងសម្រេចបង្វិលសំណុំរឿងនេះទៅជំនុំជម្រះសាជាថ្មី តាមគតិច្បាប់។

តាមរយៈឯកសារទិន្នន័យចុះបញ្ជីដីធ្លីនេះ គឺពិតជាបានបញ្ជាក់ថា យើងខ្ញុំពិតជាបានបំពេញនីតិវិធីក្នុងការស្នើសុំចុះបញ្ជីកម្មសិទ្ធិដី ក្នុងការបង្ហាញឆន្ទៈទទួលអំណោយដីពីម្តាយដោយស្របច្បាប់ និងត្រឹមត្រូវ តាំងពីទទួលបានដីពីម្តាយក្នុងអំឡុងឆ្នាំ២០១០មកម្លេះ ដែលនេះសបញ្ជាក់ថាដីដែលម្តាយរបស់យើងខ្ញុំបានធ្វើអំណោយខាងលើទៅឲ្យឈ្មោះ[redacted]នៅឆ្នាំ២០១៣ គឺជាការផ្ទេរដោយមានវិការៈ ព្រោះដីនេះម្តាយរបស់យើងខ្ញុំបានធ្វើអំណោយឲ្យយើងខ្ញុំរួចទៅហើយ ដោយគាត់មិនមានសិទ្ធិក្នុងការចាត់ចែង ហើយគាត់ក៏មិនមានលិខិត ឬឯកសារណាមួយដែលបានបញ្ជាក់ថាដកហូតអំណោយនេះពីយើងខ្ញុំនោះដែរ ជាងនេះទៅទៀតនៅអំឡុងឆ្នាំ២០១៣ នោះ ម្តាយរបស់យើងខ្ញុំមានវ័យចាស់ជរា និងពុំមានស្មារតីគ្រប់គ្រាន់ក្នុងការធ្វើអំណោយឲ្យឈ្មោះ[redacted]ពិតៗ។

យើងខ្ញុំសូមបញ្ជាក់ផងដែរថា ចំពោះមូលហេតុការដែលយើងខ្ញុំ ទើបតែទទួលបានវិញ្ញាបនបត្រសម្គាល់ម្ចាស់កាន់អចលនវត្ថុ នៅឆ្នាំ២០១៦ នោះ គឺដោយសារតែមានការយឺតយ៉ាវក្នុងការចុះបញ្ជីដីរបស់មន្ទីររៀបចំដែនដី នគរូបនីយកម្ម សំណង់ និងសុរិយោដីខេត្តកំពង់ធំ តែប៉ុណ្ណោះ ហើយប្រសិនបើយើងខ្ញុំពុំបានបំពេញនីតិវិធីចុះកម្មសិទ្ធិដីតាំងពីអំឡុងឆ្នាំ២០០៩ ពិតមែនទេ នោះមកដល់ឆ្នាំ២០១៦ នេះក៏មន្ទីររៀបចំដែនដី នគរូបនីយកម្ម សំណង់ និងសុរិយោដីខេត្តកំពង់ធំ មិនបានចេញវិញ្ញាបនបត្រសម្គាល់ម្ចាស់អចលនវត្ថុឲ្យយើងខ្ញុំឡើយ។



ដូច្នេះកាលដែលក្រុមប្រឹក្សាជំនុំជម្រះ បានចេញសាលដីការជួប្បវេណីលេខ[redacted] ចុះថ្ងៃទី៣១ ខែសីហា ឆ្នាំ២០២១ ដោយសំអាងតែលើការអះអាង ដែលមិនត្រឹមត្រូវ ផ្ទុយពីការពិតនោះ បានធ្វើឱ្យយើងខ្ញុំទទួលរងនូវភាពអយុត្តិធម៌ ប៉ះពាល់ដល់សិទ្ធិយើងខ្ញុំជាម្ចាស់កម្មសិទ្ធិ និងផលប្រយោជន៍ស្របច្បាប់យើងខ្ញុំទាំងពីយ៉ាងធ្ងន់ធ្ងរបំផុត។

IV. **សំណូមពរ:** សុំឲ្យតុលាការកំពូលសម្រេច បង្វិលសំណុំរឿងរដ្ឋប្បវេណីលេខ.៣៧ ចុះថ្ងៃទី២១ ខែមករា ឆ្នាំ២០២១ របស់តុលាការកំពូល ទៅជំនុំជម្រះសាជាថ្មី។

អាស្រ័យដូចបានជម្រាបជូនខាងលើសូម **ឯកឧត្តមប្រធាន** មេត្តាទទួលយកនូវពាក្យបណ្តឹងសុំជំនុំជម្រះសាជាថ្មីរបស់យើងខ្ញុំ និងមានចំណាត់តាមនីតិវិធីច្បាប់ដោយក្តីអនុគ្រោះ។

សូម **ឯកឧត្តមប្រធាន** មេត្តាទទួលនូវការគោរពដ៏ខ្ពង់ខ្ពស់បំផុតអំពីយើងខ្ញុំ។

ថ្ងៃច័ន្ទ ១៥រោច ខែពិសាខ ឆ្នាំខាល ចត្វាស័ក ព.ស. ២៥៦៦

ខេត្តកំពង់ធំ, ថ្ងៃទី៣០ ខែឧសភា ឆ្នាំ២០២២

**ស្នាមមេដៃស្តាំ**



**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

## <u>ពាក្យសុំឲ្យជំនុំជម្រះសាជាថ្មីចំពោះដីកាសម្រេច</u>

**ដើមចោទ** ៖ឈ្មោះ និងអាសយដ្ឋាន

អ្នកតំណាងដោយអាណត្តិ "ដើមចោទ" ៖ មេធាវី

**ចុងចម្លើយ** ៖ឈ្មោះ និងអាសយដ្ឋាន

**<u>សូមគោរពចូលមក</u>**

**ឯកឧត្តមប្រធានសាលាដំបូងរាជធានីភ្នំពេញ**

**<u>កម្មវត្ថុ</u>** ៖សំណើសុំទាមទារឲ្យជំនុំជម្រះសាជាថ្មី

**<u>យោង</u>** ៖-មាត្រា ៣០៧ និងមាត្រា ៣១៧ នៃក្រមនីតិវិធីរដ្ឋប្បវេណី

-សំណុំរឿងរដ្ឋប្បវេណីលេខ ........ ចុះថ្ងៃទី ០៩ ខែ ឧសភា ឆ្នាំ ២០១៤

សេចក្តីដូចមានកំណត់ និងយោងខាងលើ ខ្ញុំ សូមជម្រាបជូន **ឯកឧត្តមប្រធាន** មេត្តាជ្រាបថា ៖

**ក-សញ្ញាណនៃដីកាសម្រេចដែលជាកម្មវត្ថុនៃបណ្តឹងទាមទារឲ្យជំនុំជម្រះសាជាថ្មី**

ដីកាសម្រេចរដ្ឋប្បវេណីលេខ................ "ញ" ចុះថ្ងៃទី ១០ ខែ សីហា ឆ្នាំ ២០១៤ របស់សាលាដំបូងរាជធានីភ្នំពេញ

**ខ-សេចក្តីទាមទារឲ្យជំនុំជម្រះសាជាថ្មី**

១.

២.

**គ-អង្គហេតុដែលត្រូវនឹងមូលហេតុនៃការជំនុំជម្រះសាជាថ្មី**

១.

២.

សេចក្តីដូចមានកំណត់ សូម **ឯកឧត្តមប្រធាន** មេត្តាអនុញ្ញាត ដោយក្តីអនុគ្រោះ។

សូម **ឯកឧត្តមប្រធាន** ទទួលនូវសេចក្តីគោរពដ៏ជ្រាលជ្រៅអំពីខ្ញុំ។

រាជធានីភ្នំពេញ, ថ្ងៃទី ២៥ ខែ មករា ឆ្នាំ ២០១៥

**ហត្ថលេខា និងត្រា**

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

# ពាក្យបណ្តឹងជំទាស់

ខ្ញុំបាទឈ្មោះ................ កើតនៅឆ្នាំ............ ជនជាតិ............ សញ្ជាតិ........... មានទីលំនៅបច្ចុប្បន្ន ...............................................................................................................។

**សូមគោរពចូលមក**

**ឯកឧត្តមប្រធាន**...........................

**កម្មវត្ថុ៖** សុំប្តឹងជំទាស់លើដីកាសម្រេចលេខ............... ចុះថ្ងៃទី.......... ខែ.......... ឆ្នាំ........... របស់ ........................។

**យោង៖** -មាត្រា.............. ក្រមនីតិវិធីរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា។

-ដីកាសម្រេចលេខ........... ចុះថ្ងៃទី.......... ខែ.............. ឆ្នាំ............. ។

តបតាមកម្មវត្ថុនិងយោងខាងលើ ខ្ញុំបាទ/នាងខ្ញុំសូមគោរពជូន **ឯកឧត្តមប្រធាន** អោយបានជ្រាបថា៖ កាលពីថ្ងៃទី......... ខែ......... ឆ្នាំ........... តុលាការឧទ្ធរណ៍បានចេញសេចក្តីសម្រេចលើសំណុំរឿងលេខ......... ចុះថ្ងៃទី....... ខែ......... ឆ្នាំ...........។ ការសម្រេចសេចក្តីខាងលើនេះបានធ្វើអោយប៉ះពាល់ដល់ប្រយោជន៍ខ្ញុំបាទ/នាងខ្ញុំយ៉ាងធ្ងន់ធ្ងរ និងផ្តល់នូវភាពអយុត្តិធម៌ដល់រូបខ្ញុំបាទ/នាងខ្ញុំដែលជាជនរងគ្រោះ។

អាស្រ័យហេតុដូចបានជម្រាបជូនខាងលើនេះ ខ្ញុំបាទ/នាងខ្ញុំស្នើសុំ **ឯកឧត្តមប្រធាន** មេត្តាទទួលនិងចាត់ការតាមនីតិវិធីច្បាប់។

សូម **ឯកឧត្តមប្រធាន** មេត្តាទទួលនូវការគោរពដ៏ខ្ពង់ខ្ពស់អំពីខ្ញុំបាទនាងខ្ញុំ។

រាជធានីភ្នំពេញ ថ្ងៃទី....... ខែ....... ឆ្នាំ............

**ស្នាមមេដៃស្តាំ**

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

## ពាក្យសុំដកពាក្យបណ្ដឹង

ខ្ញុំបាទ/នាងឈ្មោះ........................... មានអាសយដ្ឋានផ្ទះលេខ.................. ផ្លូវលេខ.........ភូមិ ........................ ឃុំ/សង្កាត់........................។

**សូមគោរពជូន**

**ឯកឧត្តមប្រធាន**...........................

**កម្មវត្ថុ៖** សំណើសុំដកពាក្យបណ្ដឹងរដ្ឋប្បវេណីលេខ............... ចុះថ្ងៃទី....... ខែ........... ឆ្នាំ២០........។

**យោង៖** សំណុំរឿងរដ្ឋប្បវេណីលេខ ............. ចុះថ្ងៃទី......... ខែ........... ឆ្នាំ.........។

តបតាមកម្មវត្ថុ និងយោងខាងលើ សូម **ឯកឧត្តមប្រធាន** ជ្រាបថា៖ កាលពីថ្ងៃទី......... ខែ........... ឆ្នាំ ..........បានដាក់ពាក្យប្ដឹង ឈ្មោះ............... ភេទ........ អាយុ.......... ឆ្នាំ............. កាន់អត្តសញ្ញាណប័ណ្ណសញ្ញាតិខ្មែរលេខ.................. មានទីលំនៅបច្ចុប្បន្ននៅភូមិ.......... ឃុំ/សង្កាត់............. ស្រុក/ខណ្ឌ.............. ខេត្ត/ក្រុង.................។ បន្ទាប់ពីតុលាការចេញដីកាកោះក្នុងនីតិវិធីត្រៀម កូនបំណុលក៏យល់ព្រមសង្គ្រោះតាមកិច្ចតាមកិច្ចសន្យាខ្ចីបរិភោគឡើងវិញបន្ទាប់ពីបានពីឯកភាពគ្នាទាំងស្រុង ហេតុដូច្នេះទើបខ្ញុំបាទ សម្រេចចិត្តសុំដកពាក្យបណ្ដឹងដើម្បីបញ្ចប់នីតិវិធី។

អាស្រ័យដូចបានជម្រាបជូនខាងលើសូម **ឯកឧត្តមប្រធាន** មេត្តាសម្រេចតាមសំណូមពររបស់ខ្ញុំបាទ/នាងដូចមានក្នុងកម្មវត្ថុខាងលើ ដោយក្ដីអនុគ្រោះ។

សូម **ឯកឧត្តមប្រធាន** មេត្តាទទួលនូវសេចក្ដីគោរពដ៏ខ្ពង់ខ្ពស់អំពីខ្ញុំ។

រាជធានីភ្នំពេញ ថ្ងៃទី....... ខែ....... ឆ្នាំ............

**ស្នាមមេដៃស្ដាំ**

# ឧបសម្ព័ន្ធទី ២

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**សាលាដំបូងរាជធានីភ្នំពេញ**

**លេខ:**[redacted]

# <u>ដីកាសម្រេចលើកចោលពាក្យបណ្តឹង</u>

យើង[redacted]ចៅក្រមនៃសាលាដំបូងរាជធានីភ្នំពេញ។

-បានឃើញ**មាត្រា២១៩** នៃក្រមនីតិវិធីរដ្ឋប្បវេណី នៃព្រះរាជាណាចក្រកម្ពុជា ដែលប្រកាសឱ្យប្រើតាមព្រះរាជក្រម នស/រកម/០៧០៦/០២១ ចុះថ្ងៃទី០៦ ខែកក្កដា ឆ្នាំ២០០៦។

-បានឃើញសំណុំរឿងរដ្ឋប្បវេណីលេខ ១២៦២ ចុះថ្ងៃទី២២ ខែកក្កដា ឆ្នាំ២០១៩ របស់សាលាដំបូងរាជធានីភ្នំពេញ។

-បានឃើញដីកាកោះ ចុះថ្ងៃទី២៤ ខែកក្កដា ឆ្នាំ២០១៩ របស់សាលាដំបូងរាជធានីភ្នំពេញ។

-បានឃើញរបាយការណ៍អំពីការបញ្ជូន ចុះថ្ងៃទី២៦ ខែកក្កដា ឆ្នាំ២០១៩។

**-<u>ដើមចោទ:</u>** ឈ្មោះ [redacted] ភេទប្រុស កើតថ្ងៃទី២១ ខែវិច្ឆិកា ឆ្នាំ១៩៩១ សញ្ជាតិខ្មែរ ទីលំនៅបច្ចុប្បន្នផ្ទះលេខ២៣៥៩A ផ្លូវបេតុង ក្រុមទី១ ភូមិបឹងឈូក សង្កាត់គីឡូម៉ែត្រលេខ៦ ខណ្ឌឫស្សីកែវ រាជធានីភ្នំពេញ។

**-<u>ចុងចម្លើយ:</u>** ឈ្មោះ [redacted] ភេទស្រី កើតថ្ងៃទី១៤ ខែឧសភា ឆ្នាំ១៩៨៦ សញ្ជាតិខ្មែរ មុខរបរលក់ដូរ ទីលំនៅបច្ចុប្បន្នភូមិអង្គរជ័យ ឃុំអង្គរជ័យ ស្រុកអង្គរជ័យ ខេត្តកំពត។

**<u>ខ្លឹមសារនៃការទាមទាររបស់ដើមចោទ:</u> ប្ដឹងសុំលះលែងប្តីប្រពន្ធ** ប្ដឹងសុំឈប់រស់នៅជាសហនីតិសង្វាស។

## <u>សំអាងហេតុ</u>

ដើមចោទបានអវត្តមានដោយគ្មានមូលហេតុ បន្ទាប់ពីដើមចោទបានទទួលដីកាកោះឱ្យចូលមកក្នុងកាលបរិច្ឆេទនៃនីតិវិធីត្រៀមសម្រាប់ការទាញហេតុផលរួចមកកាលថ្ងៃទី២៦ ខែកក្កដា ឆ្នាំ២០១៩ ។ ហេតុនេះគប្បីតុលាការចាត់ទុកថា ដើមចោទបានដកពាក្យបណ្ដឹងរបស់ខ្លួនវិញតាម**មាត្រា ២១៩** នៃក្រមនីតិវិធីរដ្ឋប្បវេណី។

## <u>ហេតុដូច្នេះសម្រេច</u>

**១**-លើកចោលពាក្យបណ្ដឹងរបស់ដើមចោទឈ្មោះ[redacted]ចុះថ្ងៃទី២២ ខែកក្កដា ឆ្នាំ២០១៩ ជាអាសាបង់។

**២**-ប្រាក់ប្រដាប់ក្ដីជាបន្ទុករបស់ដើមចោទ ។

ថ្ងៃសុក្រ ៣កើត ខែមិគសិរ ឆ្នាំកុរ ឯកស័ក ព.ស២៥៦៣
រាជធានីភ្នំពេញ ,ថ្ងៃទី២៩ ខែវិច្ឆិកា ឆ្នាំ២០១៩

**ចៅក្រម**

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

---

**សាលាឧទ្ធរណ៍**
ដីកាសម្រេចលេខ: [redacted]
ចុះថ្ងៃទី០៥ ខែវិច្ឆិកា ឆ្នាំ២០១៨

## ដីកាសម្រេចច្រានចោល
## បណ្តឹងទាមទារឲ្យជំនុំជម្រះសាជាថ្មី

- បានឃើញមាត្រា ៣១៤ និងមាត្រាពាក់ព័ន្ធនៃក្រមនីតិវិធីរដ្ឋប្បវេណី

- បានឃើញសំណុំរឿងជំនុំជម្រះសាជាថ្មីលេខ [redacted] ចុះថ្ងៃទី១០ ខែឧសភា ឆ្នាំ២០១៨ ដែលមាន៖

### ដើមចោទនៃបណ្តឹងទាមទារឲ្យជំនុំជម្រះសាជាថ្មី៖

ឈ្មោះ [redacted] ហៅ គុយ ភេទប្រុស អាយុ៦០ឆ្នាំ ជាតិខ្មែរ មានអាសយដ្ឋានបច្ចុប្បន្ន៖ នៅភូមិម្លូង ឃុំព្រែកឡៅ ស្រុកពញាឮ ខេត្តកណ្តាល។ (ចុងចម្លើយក្នុងសំណុំរឿងអង្គសេចក្តី)

### ចុងចម្លើយនៃបណ្តឹងទាមទារឲ្យជំនុំជម្រះសាជាថ្មី៖

ឈ្មោះ [redacted] ភេទប្រុស អាយុ៥១ឆ្នាំ ជាតិខ្មែរ និងប្រពន្ធឈ្មោះ [redacted] មានអាសយដ្ឋានបច្ចុប្បន្ន៖ នៅផ្ទះលេខ១៣A សង្កាត់បឹងកក់១ ខណ្ឌទួលគោក រាជធានីភ្នំពេញ។ (ដើមចោទក្នុងសំណុំរឿងអង្គសេចក្តី)

-បានឃើញសាលដីការដ្ឋប្បវេណីលេខ [redacted] ចុះថ្ងៃទី [redacted] ឆ្នាំ២០១៨ របស់តុលាការកំពូល។

-បានឃើញពាក្យបណ្តឹង ចុះថ្ងៃទី១៨ ខែមេសា ឆ្នាំ២០១៨ របស់ឈ្មោះ [redacted] ហៅ [redacted] ទាមទារឲ្យជំនុំជម្រះសាជាថ្មី ចំពោះសាលដីការដ្ឋប្បវេណីលេខ [redacted] ចុះថ្ងៃទី១៣ ខែមីនា ឆ្នាំ២០១៨ របស់តុលាការកំពូល។

### មូលហេតុនៃការទាមទារឲ្យជំនុំជម្រះសាជាថ្មី

តាមពាក្យបណ្តឹង ចុះថ្ងៃទី១៨ ខែមេសា ឆ្នាំ២០១៨ របស់ឈ្មោះ [redacted] ហៅ [redacted] បានទាមទារសុំឲ្យជំនុំជម្រះសាជាថ្មី លើសាលដីការដ្ឋប្បវេណីលេខ [redacted] ចុះថ្ងៃទី១៣ ខែមីនា ឆ្នាំ២០១៨ ដែលមានឈ្មោះ [redacted] ជាដើមចោទ និងឈ្មោះ [redacted] ជាចុងចម្លើយ ត្រូវបានតុលាការកំពូលលើកមកជំនុំជម្រះ កាលពីថ្ងៃទី១៣ ខែមីនា ឆ្នាំ២០១៨ តាមសាលដីការដ្ឋប្បវេណីលេខ [redacted] ចុះថ្ងៃទី១៣ ខែមីនា ឆ្នាំ២០១៨ របស់តុលាការកំពូល។ កាលពីថ្ងៃទី០៨ ខែកក្កដា ឆ្នាំ២០១០ ដើមចោទឈ្មោះ [redacted]

និងឈ្មោះ [redacted]ថា កាលពីឆ្នាំ១៩៩២ ខ្លួនបានទិញដីមួយកន្លែង បន្ទាប់មកខ្លួនបានឱ្យឈ្មោះ [redacted] មករស់នៅ និងចាំដី ព្រមទាំងជួយមើល និងចិញ្ចឹមត្រី។ នៅឆ្នាំ១៩៩៧ រដ្ឋអំណាចបានចេញប្លង់ឲ្យខ្លួនលើកទី១ ទៅតាមកំណត់ហេតុលើប័ណ្ណកម្មសិទ្ធិលេខ [redacted] បន្ទាប់មកនៅឆ្នាំ១៩៩៩ ក្រោយពីបានចេញលុយរៀបចំស្រះនៅខាងក្រោយ និងថែរក្សាដីខាងក្រោយ ខ្លួនសុំការគ្រប់គ្រងកាន់កាប់ដីទី២ ដែលនៅខាងក្រោយនេះតាមរយៈការចេញប្លង់ដែលចេញដោយអាជ្ញាធរ និងអាជ្ញាធរមានសមត្ថកិច្ច ដែលមានកំណត់ហេតុលើប័ណ្ណកម្មសិទ្ធិលេខ [redacted]។ នៅឆ្នាំ២០០៩ ខ្លួនចង់បានដីនេះយកមកប្រកបអាជីវកម្មខ្លួនឯងវិញ ក៏ប៉ុន្តែឈ្មោះ [redacted] ហៅ [redacted] ដែលនៅចាំដីបានសុំប្រកបអាជីវកម្មនៅលើដីនេះរយៈពេល ២ឆ្នាំទៀត ទើបចេញពីដីរបស់ខ្លួន។ លុះដល់ខែកក្កដា ឆ្នាំ២០១០ ខ្លួនបានដាស់តឿនទៅដល់ឈ្មោះ [redacted] ពីរឿងដែលបានសន្យាជាមួយខ្លួនក្នុងការចេញពីដីនេះ ដោយខ្លួននឹងធ្វើលិខិតបែងចែកមរតកឱ្យនៅពេលលក់ដីបានឱ្យទៅឈ្មោះ [redacted] នេះ ឈ្មោះ [redacted] បានឯកភាព និងមកចាត់ចែងក្នុងការរៀបចំឯកសារនេះជាមួយប្រពន្ធខ្លួន ក៏ប៉ុន្តែនៅពេលមករៀបចំឯកសារ ឈ្មោះ [redacted] បានសុំប្រពន្ធខ្លួនឱ្យពន្យាពេល២ខែ ដើម្បីដើររកទិញដី។ ក្រោយពីបាន២ខែមក ប្រពន្ធខ្លួនបានទូរស័ព្ទទៅឈ្មោះ [redacted] ប៉ុន្តែឈ្មោះ [redacted] បានឆ្លើយថាឲ្យធ្វើតាមដំណើរ និងធ្វើតាមច្បាប់។ បន្ទាប់ពីព្រឹកថ្ងៃទី០៥ ខែកក្កដា ឆ្នាំ២០១០ ដោយបានឮពាក្យនេះ ខ្លួនក៏បានចេញដំណើរទៅដីខ្លួន ដើម្បីសួរនាំពីករណីនៃពាក្យដែលថាធ្វើតាមដំណើរ និងតាមច្បាប់ តើឈ្មោះ [redacted] ចង់កំណត់យ៉ាងដូចម្ដេច ឈ្មោះ [redacted] បានប្រើពាក្យសម្លេងធំ និងលើករឿងផ្សេងៗដែលពុំសមស្របមកលើខ្លួនជាម្ចាស់ដី និងជាឪពុកមាជីដូនមួយ ហើយបានរៀបរាប់ចំមនុស្សមួយចំនួន ដែលមានសមាសភាពជាអ្នកដទៃនៃគ្រួសារគេចូលរួមស្ដាប់ និងបង្ហាញរូបភាពជាលក្ខណៈគម្រាម ហើយឈ្មោះ [redacted] បានប្រាប់ខ្លួនថា គឺមិនចេញពីដីនេះទេ ឲ្យអនុវត្តតាមច្បាប់ទៅ។

<u>មូលហេតុនៃពាក្យបណ្ដឹងសុំជំនុំជម្រះសាជាថ្មី</u>

តាមការចង្អុលបង្ហាញ និងយោងទៅតាមមាត្រា ៣០៧ និងមាត្រា ៣១២ នៃក្រមនីតិវិធីរដ្ឋប្បវេណី។

តាមរយៈនៃពាក្យបណ្ដឹងខាងលើនេះ ខ្ញុំសូមជម្រាប ឯកឧត្តម មេត្តាជ្រាបថា ពាក្យដែលគាត់បានលើកឡើងនៅក្នុងពាក្យបណ្ដឹងនោះ គឺជាពាក្យមិនត្រឹមត្រូវទេ ព្រោះថា គាត់លើកឡើងដើម្បីបំភាន់តុលាការតែប៉ុណ្ណោះ ដីនេះកាលពីដំបូងឡើយ ខ្ញុំបាទសូមបញ្ជាក់ថាដីរបស់គាត់កាន់កាប់នោះ គឺជាដីនៅខាងមុខដែលមានប័ណ្ណសំគាល់សិទ្ធិកាន់កាប់អចលនវត្ថុលេខ [redacted] ហើយដីនោះដើមឡើយគាត់ឱ្យខ្ញុំបាទនៅជួយមើលដីឲ្យគាត់ពិតប្រាកដ ចំណែកដីនៅខាងក្រោយគឺខ្ញុំបាទបានខ្ចីពីរដ្ឋអំណាចដែលមានលិខិតស្នើសុំខ្ចីដីដាំឈូក ចុះថ្ងៃទី០៧ ខែសីហា ឆ្នាំ១៩៩៤ ដែលមានការទទួលស្គាល់ពីរដ្ឋអំណាចមូលដ្ឋានត្រឹមត្រូវ ហើយក្រោយមកទើបខ្ញុំបាទស្នើសុំជីកដីស្រះចិញ្ចឹមត្រីសម្រាប់ដោះស្រាយជីវភាពដោយមានការឯកភាព និងទទួលដឹងឮពីរដ្ឋអំណាចតាមលំដាប់ថ្នាក់ទាំងអស់។ ឯកឧត្តម ជាទីគោរព ដីខាងក្រោយនេះ ខ្ញុំបាទបានសុំសិទ្ធិគ្រប់គ្រង ប្រើប្រាស់ ចាត់ចែង និងអាស្រ័យផលលើដីនេះតាមច្បាប់អស់រយៈពេលជាង២៥ឆ្នាំ មកហើយ បើគិតទៅតាមច្បាប់កិរិយានៃការកាន់កាប់របស់ខ្ញុំបាទ គឺមានលក្ខណៈសុចរិតទៀងត្រង់ និងបានទទួលស្គាល់ជាសាធារណៈ ដោយពុំមានការគំរាមកំហែងពីអ្នកណាម្នាក់ឡើយ ព្រោះខ្ញុំបាទមានសាក្សីជាច្រើនអ្នកទទួលស្គាល់ ដូចជាឈ្មោះ [redacted] គឺសុទ្ធបញ្ជាក់ថា ខ្ញុំបាទពិតជាបានមករស់នៅលើដីនេះរហូតមកដល់សព្វថ្ងៃ និងមានហេតុផលច្បាស់លាស់ ព្រមទាំងមានលិខិតទើបតែបញ្ជាក់ នៅថ្ងៃទី០៩ ខែមីនា

ឆ្នាំ២០១៨ នេះបញ្ជាក់ស្រាប់។ ចំណែកឯប័ណ្ណសំគាល់សិទ្ធិកាន់កាប់ដែល ឯកឧត្តម យល់ឃើញថា ជាកម្មសិទ្ធិជាប្លង់ត្រឹមត្រូវតាមលក្ខណៈច្បាប់នោះ គឺជាប្លង់ដែលកើតឡើងមានលក្ខណៈមិនប្រក្រតីទៅវិញទេ ព្រោះថា ប្លង់នេះមិនមានកំណត់ហេតុ ពុំមានប្រវត្តិដី និងស្នាមផ្តិតមេដៃពីអ្នករស់នៅជិតខាងឡើយ ជាពិសេសជាងនេះទៅទៀតអំពីទំហំដីខុសពីទំហំដែលដើមចោទបានទាមទារ ព្រមទាំងកាលបរិច្ឆេទមិនស្របតាមសេចក្តីសម្រេចនៃច្បាប់ភូមិបាលដែលត្រូវបិទផ្សាយជាសាធារណៈ យ៉ាងហោចណាស់រយៈពេល ១ខែ យ៉ាងតិចបំផុត។ ដូច្នេះរឿងនេះគឺមានការភាន់ច្រឡំអំពីអង្គហេតុដែលឲ្យតុលាការរកភាពយុត្តិធម៌ជូនខ្ញុំបាទមិនបានច្បាស់លាស់ ព្រោះថាដីគាត់នៅខាងមុខ គឺមានប្លង់លេខ [redacted] ចុះថ្ងៃទី២៩ ខែមីនា ឆ្នាំ១៩៩៩ ចំណែកដីដែលមានទំនាស់មានប្លង់លេខ ក [redacted] គឺជាប្លង់មិនត្រឹមត្រូវតាមច្បាប់ អាស្រ័យហេតុនេះ សូម ឯកឧត្តម មេត្តាជ្រាបនិងសូមចាត់វិធានការស្វែងរកភាពយុត្តិធម៌ឲ្យខ្ញុំបាទផង ដោយសុំឲ្យពិនិត្យលើរដ្ឋបាលនៃការចុះវាស់វែងធ្វើប្លង់នេះក្នុងការចុះបញ្ជីសុរិយោដី និងភាពមិនប្រក្រតី ព្រមទាំងមានខុសពីទំហំដីនៃកម្មវត្ថុបណ្តឹង ដែលនាំឲ្យមានការភាន់ច្រឡំ និងឯកសាររដ្ឋបាលទាំងអស់មុនចុះបញ្ជី មុនចុះហត្ថលេខាផ្នែករដ្ឋបាលចុះលេខ រក្សាទុកសម្រាប់រដ្ឋបាល និងរក្សាទុកជាសាធារណៈជនជាគោល ហើយរាល់លិខិតស្នាមផ្សេងៗដែលរដ្ឋបាលមិនទទួលស្គាល់ទេដូចជាមេឃុំ ចៅសង្កាត់ពុំអនុញ្ញាតចុះហត្ថលេខានោះ ម្យ៉ាងទៀតរាល់ពត៌មានដែលមិនប្រក្រតីទាំងឡាយណាមិនច្បាស់លាស់ខុសនឹងនីតិវិធី ព្រោះវត្ថុ និងឯកសារទាំងនោះ ដែលបានក្លាយជាភស្តុតាងសម្រាប់សាលក្រម និងសាលដីកាត្រូវបានក្លែង ឬកែប្រែដោយមានការបន្លំ។ ដោយផ្អែកទៅតាមមាត្រា ៣០៧ កថាខណ្ឌទី១ ចំណុច “ច”។

អាស្រ័យដូចបានជម្រាបជូនខាងលើ សូមឯកឧត្តមមេត្តា ទទួលសំណុំរឿងជំនុំជម្រះសាជាថ្មីឡើងវិញ ដើម្បីចាត់ពិនិត្យអង្កេតទៅលើប្លង់ដែលមានទំនាស់នេះឡើងវិញដោយក្តីអនុគ្រោះ។

- ក្រោយពីបានស្តាប់របាយការណ៍របស់ចៅក្រមទទួលបញ្ជា
- ក្រោយពីបានពិភាក្សាត្រឹមត្រូវតាមច្បាប់ហើយ

## សំអាងហេតុ

១-យល់ឃើញថា បណ្តឹងទាមទារសុំឲ្យជំនុំជម្រះសាជាថ្មី របស់ឈ្មោះ [redacted] ចុះថ្ងៃទី១៨ ខែមេសា ឆ្នាំ២០១៨ ធ្វើឡើងស្របតាមមាត្រា ៣០៩ នៃក្រមនីតិវិធីរដ្ឋប្បវេណី តុលាការកំពូលអាចលើកយកបណ្តឹងនេះមកពិនិត្យ និងពិចារណាបាន។

២-យល់ឃើញថា ឈ្មោះ [redacted] បានលើកឡើងនូវមូលហេតុនៃការសុំឲ្យជំនុំជម្រះសាជាថ្មីរបស់ខ្លួនថា ពាក្យបណ្តឹងរបស់ឈ្មោះ [redacted] ជាពាក្យមិនត្រឹមត្រូវ គឺលើកឡើងបំភាន់តុលាការចំណែកប័ណ្ណសំគាល់សិទ្ធិកាន់កាប់ [redacted] ជាប្លង់កើតឡើងមិនប្រក្រតី មិនត្រឹមត្រូវតាមច្បាប់ប៉ុន្តែការអះអាងនេះពុំមានភស្តុតាងណាមួយបញ្ជាក់ទេ ម្យ៉ាងទៀត ចំណុចនេះ តុលាការកំពូលក៏បានសម្អាងហេតុនៅក្នុងសាលដីការដ្ឋប្បវេណីលេខ [redacted] ចុះថ្ងៃទី១៣ ខែមីនា ឆ្នាំ២០១៨ របស់តុលាការកំពូល រួចហើយដែរ។ លើសពីនេះទៀត តាមមាត្រា ៣០៧.២.ក នៃក្រមនីតិវិធីរដ្ឋប្បវេណី ត្រូវទាមទារឲ្យមានសាលក្រម

ឬសាលដីកាស្តាពរ ដែលផ្តន្ទាទោសអំពីអត្ថិភាពនៃលិខិតក្លែង តែពេលនេះ ដើមចោទនៃបណ្តឹងសុំឲ្យជំនុំជម្រះសាជាថ្មី ពុំមានឯកសារណាមួយបញ្ជាក់ទេ។

៣-យល់ឃើញថា បណ្តឹងសុំឲ្យជំនុំជម្រះសាជាថ្មី ចុះថ្ងៃទី១៨ ខែមេសា ឆ្នាំ២០១៨ របស់ឈ្មោះ [redacted] ពុំមានមូលហេតុនៃការជំនុំជម្រះសាជាថ្មីណាមួយដូចមានចែងក្នុងមាត្រា ៣០៧ និងមាត្រា ៣០៨ នៃក្រមនីតិវិធីរដ្ឋប្បវេណីទេ ហេតុនេះតាមមាត្រា ៣១៤ នៃក្រមនីតិវិធីរដ្ឋប្បវេណី តុលាការត្រូវច្រានចោលការទាមទារឲ្យជំនុំជម្រះសាជាថ្មី។

<u>ហេតុដូច្នេះ</u>

<u>សម្រេច</u>

១-ច្រានចោលការទាមទារសុំឲ្យជំនុំជម្រះសាជាថ្មី ចុះថ្ងៃទី១៨ ខែមេសា ឆ្នាំ២០១៨ របស់ឈ្មោះ

២-ប្រាក់ប្រដាប់ក្តីជាបន្ទុករបស់ដើមចោទ។

ដីកាសម្រេចនេះ ធ្វើនៅថ្ងៃទី០៥ ខែវិច្ឆិកា ឆ្នាំ២០១៨។

| | |
|---|---|
| ឯកឧត្តម | ប្រធាន |
| លោក | ចៅក្រម |
| លោក | ចៅក្រម |
| លោក | ចៅក្រម |
| លោកស្រី | ចៅក្រម |
| លោកស្រី | ក្រឡាបញ្ជី |

---

ច្បាប់ចម្លងត្រឹមត្រូវតាមច្បាប់ដើម ។

ថ្ងៃពុធ ១៤រោច ខែអស្សុជ ឆ្នាំច សំរិទ្ធិស័ក.ព.ស២៥៦២

ត្រូវនឹងថ្ងៃទី០៧ ខែវិច្ឆិកា ឆ្នាំ២០១៨

ក្រឡាបញ្ជី

បានឃើញ

រាជធានីភ្នំពេញ ថ្ងៃទី០៧ ខែវិច្ឆិកា ឆ្នាំ២០១៨

ប្រធានក្រុមប្រឹក្សាជំនុំជំរះ

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**<u>ដីកាសម្រេចចាប់ផ្តើមជំនុំជម្រះសាជាថ្មី</u>**

**យើង Z ចៅក្រមនៃសាលាដំបូងរាជធានីភ្នំពេញ**

-បានឃើញសំណុំរឿងជំនុំជម្រះសាជាថ្មីលេខ ១០ ចុះថ្ងៃទី ២៥-១១-២០១៤

-បានឃើញសំណុំរឿងរដ្ឋប្បវេណីលេខ........ ចុះថ្ងៃទី ០៩-ឧសភា-២០១៤

-បានឃើញពាក្យបណ្តឹងទាមទារឲ្យជំនុំជម្រះសាជាថ្មី ចុះថ្ងៃទី ២៥-១១-២០១៤

-បានឃើញសាលក្រមរដ្ឋប្បវេណីលេខ ........... "ញ" ថ្ងៃទី ១០ ខែ សីហា ឆ្នាំ ២០១៤ របស់តុលាការកំពូល

-បានឃើញមាត្រា ៣០៧, មាត្រា ៣១២, មាត្រា ៣១៥, មាត្រា ២១៦ នៃក្រមនីតិវិធីរដ្ឋប្បវេណី

-បានឃើញកំណត់ហេតុនៃការសាកសួរចុងម្លើយនៃបណ្តឹងទាមទារឲ្យជំនុំជម្រះសាជាថ្មី របស់តុលាការកំពូល

**ដើមចោទ ៖** ឈ្មោះ X អាយុ ៥០ ឆ្នាំ ភេទស្រី សញ្ជាតិខ្មែរ មានអាសយដ្ឋានស្ថិតនៅផ្ទះគ្មានលេខ ផ្លូវលំ ក្រុម១ ភូមិ២ សង្កាត់៣ ខណ្ឌ៤ រាជធានីភ្នំពេញ។

**ចុងចម្លើយ ៖**ឈ្មោះ Y អាយុ ៤០ ឆ្នាំ សញ្ជាតិខ្មែរ មាអាសយដ្ឋាន ស្ថិតនៅផ្ទះលេខ ១០ ផ្លូវលេខ ៣១០ ក្រុម ១ ភូមិ ២ សង្កាត់ ៣ ខណ្ឌ ៥ រាជធានីភ្នំពេញ។

**សេចក្តីទាមទារឲ្យជំនុំជម្រះសាជាថ្មី ៖**

១.

២.

៣.

៤.

**អង្គហេតុដែលជាមូលហេតុនៃការទាមទារឲ្យជំនុំជម្រះសាជាថ្មី ៖**

១.

២.

៣.

៤.

## សំអាងហេតុ

១.

២.

៣.

៤.

## សេចក្តីសម្រេចបញ្ចប់

ចាប់ផ្តើមជំនុំជម្រះសាជាថ្មីចំពោះសំណុំរឿងរដ្ឋប្បវេណីលេខ ........ ចុះថ្ងៃទី ០៩ ខែឧសភា ឆ្នាំ ២០១៤ របស់សាលាដំបូងរាជធានីភ្នំពេញ

ទុកសិទ្ធិឲ្យភាគីប្តឹងជំទាស់ក្នុងរយៈពេល ០១ (មួយ) សប្តាហ៍ គិតចាប់ពីថ្ងៃបានទទួលការបញ្ជូនដីកាសម្រេចនេះ។

រាជធានីភ្នំពេញ, ថ្ងៃទី ២៦ ខែ ធ្នូ ឆ្នាំ ២០១៤

**ចៅក្រម**

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**សាលក្រម**

**តាងនាមប្រជារាស្ត្រខ្មែរ**

**សាលាដំបូងរាជធានីភ្នំពេញ**

បានបញ្ចប់ការទាញហេតុផលដោយផ្ទាល់មាត់ជាសាធារណៈ នៅថ្ងៃទី ១០ ខែ កុម្ភៈ ឆ្នាំ ២០១៥ និងបានប្រកាសសាលដីកាជាសាធារណៈនៅថ្ងៃទី ១៥ ខែ កុម្ភៈ ឆ្នាំ ២០១៥

-បានឃើញសំណុំរឿងជំនុំជម្រះសាជាថ្មីលេខ ១០ ចុះថ្ងៃទី ២៥-១១-២០១៤

-បានឃើញសំណុំរឿងរដ្ឋប្បវេណីលេខ........ ចុះថ្ងៃទី ០៩-ឧសភា-២០១៤

-បានឃើញពាក្យបណ្តឹងទាមទារឲ្យជំនុំជម្រះសាជាថ្មី ចុះថ្ងៃទី ២៥-១១-២០១៤

-បានឃើញសាលក្រមរដ្ឋប្បវេណីលេខ ........... "ញ" ថ្ងៃទី ១០ ខែ សីហា ឆ្នាំ ២០១៤ របស់តុលាការកំពូល

-បានឃើញមាត្រា ៣០៧, មាត្រា ៣១២, មាត្រា ៣១៥, មាត្រា ២១៦ នៃក្រមនីតិវិធីរដ្ឋប្បវេណី

-បានឃើញកំណត់ហេតុនៃការសាកសួរចុងម្លើយនៃបណ្តឹងទាមទារឲ្យជំនុំជម្រះសាជាថ្មី របស់តុលាការកំពូល

**ចៅក្រមជំនុំជម្រះ**

លោក Z ជាចៅក្រមនៃសាលាដំបូងរាជធានីភ្នំពេញ

**ក្រឡាបញ្ជី**

លោកស្រី B

**ដើមចោទ ៖** ឈ្មោះ X អាយុ ៥០ ឆ្នាំ ភេទស្រី សញ្ជាតិខ្មែរ មានអាសយដ្ឋានស្ថិតនៅផ្ទះគ្មានលេខ ផ្លូវលំ ក្រុម១ ភូមិ២ សង្កាត់៣ ខណ្ឌ៤ រាជធានីភ្នំពេញ។

**អ្នកតំណាងដោយអាណត្តិ** "ដើមចោទ" ៖ មេធាវី

**ចុងចម្លើយ ៖**ឈ្មោះ Y អាយុ ៤០ ឆ្នាំ សញ្ជាតិខ្មែរ មាអាសយដ្ឋាន ស្ថិតនៅផ្ទះលេខ ១០ ផ្លូវលេខ ៣១០ ក្រុម ១ ភូមិ ២ សង្កាត់ ៣ ខណ្ឌ ៥ រាជធានីភ្នំពេញ។

## អង្គហេតុ និងចំណុចវិវាទ

១.ការអះអាងរបស់ដើមចោទ

១.១ សេចក្តីទាមទារឲ្យជំនុំជម្រះសាជាថ្មី ៖

ក.

ខ.

១.២ អង្គហេតុដែលជាមូលហេតុនៃការទាមទារឲ្យជំនុំជម្រះសាជាថ្មី ៖

ក.

ខ.

១.៣ ភស្តុតាង

ក.

ខ.

២.ការអះអាងរបស់ចុងចម្លើយ

២.១

២.២

២.៣

៣.ចំណុចវិវាទ

៣.១

៣.២

៣.៣

## សំអាងហេតុ

១.

២.

៣.

៤.

៥.

# សេចក្តីសម្រេចបញ្ចប់

១.លុបចោលសាលក្រមរដ្ឋប្បវេណីលេខ............ "ញ" ចុះថ្ងៃទីថ្ងៃទី ១០ ខែ សីហា ឆ្នាំ ២០១៤ របស់សាលាដំបូងរាជធានីភ្នំពេញ

២.បង្គាប់ឲ្យចុងចម្លើយ (Y) បង់ប្រាក់ចំនួន..........ឲ្យទៅដើមចោទ (X)

៣.ប្រាក់ប្រដាប់ក្ដីជាបន្ទុករបស់ចុងចម្លើយ(Y)។

សាលដីកានេះប្រកាសជាសាធារណៈនៅថ្ងៃទី ១៥ ខែ កុម្ភៈ ឆ្នាំ ២០១៥ ចំពោះមុខភាគី និងអ្នកតំណាងដោយអាណត្តិរបស់ភាគី។ ទុកសិទ្ធិឲ្យភាគីប្ដឹងឧទ្ធរណ៍ក្នុងរយៈពេល ០១ (មួយ) ខែ គិតចាប់ពីថ្ងៃបានទទួលអនុសារៈសាលក្រមនេះ។

រាជធានីភ្នំពេញ, ថ្ងៃទី ១៥ ខែ កុម្ភៈ ឆ្នាំ ២០១៥

**ចៅក្រម**